ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- សារសំខាន់នៃប្រវត្តិសាស្ត្រសម្រាប់អ្នកសិក្សាវ័យក្មេង
- សិស្សានុសិស្សនៅវិទ្យាល័យព្រៃញ្ញៅ ទទួលចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤៣ ខែមីនា ឆ្នាំ២០២០

ស្វែងរកការពិត
ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
លេខ ២៤៣ ខែមីនា ឆ្នាំ២០២០

## មាតិកា

**សំបុត្រ**
- សារសំខាន់នៃប្រវត្តិសាស្ត្រសម្រាប់..........១

**ផ្នែកឯកសារ**
- ប្រធានសន្តិសុខស្រុកពាមជរ................. ៥
- តែ សួរ ៖ គិញ ដកស្រង់ចេញពីចម្លើយ .... ១២

**ផ្នែកប្រវត្តិសាស្ត្រ**
- គាំ ឡូនៈ អតីតកងទ័ពជើងទឹកឈរជើង.......១៦
- បូជាភ្លើង.................................. ២២
- មុខរបរដំដែកនៅស្រុកអន្លង់វែង ........... ៣០
- យិន នាន ចែករំលែកបទពិសោធន៍........ ៣២
- ឡុង អួន ចែករំលែកបទពិសោធន៍..........៣៤

**ផ្នែកច្បាប់**
- សាលក្រមសំណុំរឿង០០២/០២ ........... ៣៧

**ផ្នែកវេទិកាសាធារណៈ**
- សិស្សានុសិស្សនៅវិទ្យាល័យព្រៃញ្ញៅ ...... ៤៣

**ផ្នែកស្រាវជ្រាវរកគ្រួសារ**
- កុក សារឿនៈ អនុសេនីយ៍ឯក ..............៤៨
- គង់ បំរើន ៖ បុគ្គលិកប្រៃសណីយ៍ ...........៥០
- ឡឿ គីមសៀ ៖ វរសេនីយ៍ទោ...............៥២
- យស់ ព្រឹម ៖ វរសេនីយ៍ឯក................. ៥៦
- បញ្ជីឈ្មោះអ្នកដែលបានស្លាប់ ..........៥៨



ឡឿ គីមសៀ (នៅខាងឆ្វេង)
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** ស៊ាង ចិន្តា, ហេង ហ្សាយ, សួត វិចិត្រ, មីន សាណាស់, ប៉ាង ពីវ័ន្ត, វេនី ខកហ្គៀល, វ៉ាន់ថាន់ ពៅដារ៉ា និងឡុង ដានី **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង ពៅង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org



# សារសំខាន់នៃប្រវត្តិសាស្ត្រ
## សម្រាប់អ្នកសិក្សាវ័យក្មេង

**សោម ប៊ុនថន**




សួត វិចិត្រ (រូបទី២រាប់ពីឆ្វេង) បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដឹកនាំក្រុមនិស្សិតផ្នែកប្រវត្តិសាស្ត្រមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទស្សនកិច្ចផ្ទះរបស់ ប៉ុល ពត នៅលើភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខែមីនា ឆ្នាំ២០២០។ (សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្រមានសារសំខាន់ណាស់សម្រាប់មនុស្សជាតិ និងសម្រាប់ការឈានឆ្ពោះទៅមុខរបស់ប្រទេស។ ការយល់ដឹងពីប្រវត្តិសាស្ត្រនឹងអាចឲ្យមនុស្សដោះស្រាយនូវរាល់បញ្ហាដែលបានកើតឡើង និងរស់នៅក្នុងសុខសន្តិភាព។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងជាច្រើនជាមួយសិស្ស និងនិស្សិតវ័យក្មេងដែលមានបំណងសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម។ នៅខែមីនា ឆ្នាំ២០២០ នេះ មាននិស្សិតវ័យក្មេង១៥នាក់មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានធ្វើការស្រាវជ្រាវលើប្រធានបទបីខុសៗគ្នាទាក់ទងនឹងប្រវត្តិសាស្ត្រនៃខ្មែរក្រហម ដែលជាផ្នែកមួយនៃកិច្ចការស្រាវជ្រាវរបស់សាលា និងមានការគាំទ្រពីគម្រោងប្រវត្តិសាស្ត្រភូមិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ និស្សិតវ័យក្មេងទាំងនេះ ក៏បានចូលរួមក្នុងកម្មវិធី



ទេសភាពបឹងអន្លង់វែង ឬ បឹងតាម៉ុក នៅរដូវវស្សា។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទស្សនកិច្ចសិក្សាស្តីអំពីសន្តិភាពទៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដែលរៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងគោលបំណង ប្រមែប្រមូលព័ត៌មានដើម និងជួបប្រជាជននៅក្នុងសហគមន៍ ដែលភាគច្រើន គឺជាអតីតកម្មាភិបាល និងយោធាខ្មែរក្រហម។ ក្នុងអំឡុងពេលចុះទៅស្រាវជ្រាវ និស្សិតវ័យក្មេងទាំងនេះ ក៏បានជួប និងស្តាប់ការធ្វើបទបង្ហាញរបស់បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)» និងប្រវត្តិសាស្ត្ររបស់សហគមន៍អន្លង់វែង។ និស្សិតវ័យក្មេងទាំងនេះក៏បានឈ្វេងយល់បន្ថែមពីគោលបំណងនៃកម្មវិធីទស្សនកិច្ចសិក្សាអំពី «សន្តិភាព» នេះ ដែល



ក្រុមនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកប្រវត្តិសាស្ត្រ កំពុងសម្ភាសន៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែង អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម។ ខែមីនា ឆ្នាំ២០២០។ (សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)







ទេសភាពស្រុកអន្លង់វែងនៅរដូវប្រាំងមើលពីពយ តាម៉ុក លើកំពូល ភ្នំដងរែក។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នឹងលើកកម្ពស់ឲ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីរបបខ្មែរក្រហម និងជំរុញឲ្យមានការពិភាក្សាររវាងអ្នករស់រានមានជីវិតពីរបបនេះ និងក្មេងជំនាន់ក្រោយ។ បន្ទាប់មក ក្រុមនិស្សិតវ័យក្មេងទាំងនេះ បានទស្សនាខ្សែភាពយន្តឯកសារចំនួនបីគឺ «កុមារកម្ពុជា» ដែលបង្ហាញពីកុមារកំព្រានៅក្នុងប្រទេសកម្ពុជាបន្ទាប់របបខ្មែរក្រហម ដួលរលំ។ «គុកទួលស្លែង» ដែលបង្ហាញអំពីការកាប់សម្លាប់ និងអំពើឃោរឃៅរបស់ខ្មែរក្រហម ប្រព្រឹត្តមកលើអ្នកទោស និង «កុំស្មានបងភ្លេច» ដែលលើកឡើងអំពីសម័យកាលរីកលូតលាស់របស់តន្ត្រីខ្មែរ ចាប់តាំងពីអំឡុងទសវត្សរ៍ឆ្នាំ៦០មក, ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងសិល្បៈករខ្មែរ, ការបាត់បង់តន្ត្រី និងសិល្បៈករខ្មែរ នៅអំឡុងរបបខ្មែរក្រហម។

ខ្សែភាពយន្តឯកសារទាំងបីមានទំនាក់ទំនងគ្នា និងបានឆ្លុះបញ្ចាំងអំពីដំណើរវិវឌ្ឍន៍របស់ប្រទេសកម្ពុជា ក្រោយសម័យអាណានិគមនិយមបារាំង, សម័យសង្គមរាស្ត្រនិយមដែលជាមោទកភាព និងជាសុបិនល្អសម្រាប់ប្រជាជនខ្មែរគ្រប់រូបកាលពីជំនាន់នោះ, សម័យសង្គ្រាម, អំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហមដែលដឹកនាំដោយប៉ុល ពត, សម័យកាលនៃការបង្រួមបង្រួម ការស្តារឡើងវិញ សន្តិភាព ការផ្សះផ្សា និងការអភិវឌ្ឍន៍រហូតមកទល់សព្វថ្ងៃ។




រូបខាងឆ្វេង៖ និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកប្រវត្តិសាស្ត្រជាមួយនឹងលោក មា ជ្រេន មគ្គុទេសក៍សហគមន៍អន្លង់វែងនៅទីតាំងប្រវត្តិសាស្ត្រ ផ្នូររបស់ ប៉ុល ពត។

និស្សិតវ័យក្មេងទាំងនេះ ក៏បានទៅទស្សនកិច្ចនៅទីតាំងប្រវត្តិសាស្ត្រទាំង១៤កន្លែង នៅក្នុងស្រុកអន្លង់វែង រួមមាន៖ ១) កន្លែងដុតខ្មោច ប៉ុល ពត, ២) កន្លែងកាត់ទោស ប៉ុល ពត, ៣) ផ្ទះកណ្តាលលើភ្នំដងរែក, ៤) កន្លែងកែច្នៃគ្រាប់លើភ្នំ២០០, ៥) ផ្ទះ ប៉ុល ពត និង ខៀវ សំផន, ៦) ឃ្លាំងដាក់សម្ភារនៅជើងភ្នំ, ៧) កន្លែងដុតខ្មោច សុន សេន, ៨) ស្រែគំរូ, ៩) ទីតាំងការដ្ឋានដឹកជញ្ជូនរបស់ តាម៉ុក, ១០) បឹងអន្លង់វែង, ១១) សារមន្ទីរ តាម៉ុក, ១២) អតីតទីតាំងមន្ទីរពេទ្យ តាម៉ុក, ១៣) អតីតទីតាំងសាលារៀន តាម៉ុក និង ១៤) ស្ពាន តាម៉ុក ដែលទីតាំងទាំងនេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអភិរក្សទុកជាទីតាំងប្រវត្តិសាស្ត្ររបស់ជាតិ។ និស្សិតវ័យក្មេងទាំងនេះក៏បានជួបជាមួយប្រជាជនក្នុងសហគមន៍ និងបានសួរសំណួរផ្សេងៗទាក់ទងនឹងរឿងរ៉ាវក្នុងរបបខ្មែរក្រហមថែមទៀត។ ព័ត៌មានដែលទទួលបានពីប្រជាជននៅក្នុងសហគមន៍, ពីទីតាំងប្រវត្តិសាស្ត្រ, ពីខ្សែភាពយន្តឯកសារ និងពីការធ្វើបទបង្ហាញ គឺជាព័ត៌មានដើម ដែលអាចជួយដល់ក្រុមនិស្សិតវ័យក្មេងទាំងនេះ មានគំនិតកាន់តែច្រើន និងទូលំទូលាយក្នុងការសរសេររឿងរ៉ាវប្រវត្តិសាស្ត្រចេញពីតំបន់អន្លង់វែង ដើម្បីធ្វើជាឯកសារយោងសម្រាប់សាលា និងសម្រាប់បោះពុម្ពផ្សាយ។ តាមរយៈកិច្ចការស្រាវជ្រាវរបស់និស្សិតវ័យក្មេងទាំងនេះ នឹងធ្វើឲ្យប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងតំបន់អន្លង់វែង និងតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងធ្វើឲ្យប្រវត្តិនេះកាន់តែមានសារសំខាន់។





# ប្រធានសន្តិសុខស្រុកពាមជរ

## តំបន់២៤ ភូមិភាគបូព៌ា ដកស្រង់ចេញពីឯកសារ D៤១៧៣២

ដារ៉ារដ្ឋ មេត្តា



កងកុមារ និងយុវជន នៅតាមមន្ទីរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) កំពុងជីករណ្តៅដាំដើមដូង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ម៉ុម ចក់ ភេទប្រុស អាយុ៣៧ឆ្នាំ (ក្នុង១៩៧៨) មានទីកន្លែងកំណើតភូមិពញាលាង ឃុំក្រសាំងទង ស្រុកកោះជ័យ តំបន់២៤។ ខ្ញុំបានរៀនបានត្រឹមថ្នាក់ទី១០ នៅសាលាវត្តកណ្តាលក្នុង ស្ថិតនៅក្នុងឃុំក្រសាំងទង ស្រុកកោះជ័យ។ ក្រោយមកខ្ញុំក៏ឈប់រៀនមកជួយធ្វើស្រែឪពុកម្តាយ និងឡើងត្នោត។ នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំបានទាក់ទងជាមួយឈ្មោះ ពូម៉ែង គឺជាអតីតខ្មែរឥស្សរៈ (បច្ចុប្បន្ន ប្រធានសេដ្ឋកិច្ចតំបន់២៤) ព្រោះគ្រួសាររបស់ខ្ញុំខ្វះខាតលុយកាក់, អង្ករ និងគោសម្រាប់ទឹម។ ពូម៉ែង បានឧបត្ថម្ភដល់គ្រួសារខ្ញុំ ហើយបានអប់រំខ្ញុំឲ្យស្អប់ពួកសក្តិភូមិ និងកុម្មុយនីស្តខ្មែរក្រហមដែលរឹតត្បិតសិទ្ធិសេរីភាព។

នៅឆ្នាំ១៩៧០ ក្រោយកើតមានរដ្ឋប្រហារ ពូម៉ែង និង បងវ៉ើន (អតីតអនុលេខាស្រុកពាមជរ) ចូលមកគ្រប់គ្រងនៅគណៈស្រុកពាមជរ, ពូសួន (ប្រធានសន្តិសុខតំបន់២៤), តាហែម (ប្រធានរណសិរ្សតំបន់២៤)។ នៅខែមេសា ពូម៉ែង បានមកទទួលខ្ញុំ ហើយឲ្យខ្ញុំបង្កប់ខ្លួននៅក្នុងបដិវត្តន៍ដែលមានតួនាទីជាប្រធាន



កងចល័ត នៅតាមសហករណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) កំពុងកាស់គល់ឈើដើម្បីរានដីធ្វើស្រែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្គត់ផ្គង់នៅមន្ទីរស្រុកពាមជរ។ មិត្តយុត បានចាត់តាំងជាប្រធានយោធាស្រុកពាមជរ និងសមាជិកស្រុក មិត្តព្រឿង ឲ្យទទួលលេខាឃុំស្វាយភ្លោះ, មិត្តគែស និង មិត្តប៊ិន ឲ្យទទួលសេដ្ឋកិច្ចស្រុកពាមជរ។

នៅក្នុងឆ្នាំ១៩៧១ ពូម៉េង និង បងវ៉ែន បានដកខ្ញុំពីប្រធានផ្គត់ផ្គង់ឲ្យមកទទួលអនុប្រធាននីរសារស្រុកពាមជរ ហើយបានឲ្យខ្ញុំទាក់ទងជាមួយឈ្មោះ សាំង ដែលជាប្រធាននីរសារ។ ភារកិច្ចខ្ញុំដែលជានីរសារគឺ ពូម៉េង ណែនាំឲ្យយកសំបុត្រឡើងចុះតាមឃុំនីមួយៗ ទាំងផ្លូវការ និង ក្រៅផ្លូវការ, ទាក់ទងជាមួយពូឈូក នៅខាងតំបន់២៤ និងពង្រីកកម្លាំងនៅក្នុងជួរនីរសារ។ កម្លាំងដែលគាត់ឲ្យខ្ញុំទាក់ទងតាមភូមិមាន ឡេ (លេខាឃុំព្រែកក្របៅ), ស៊ិាន (លេខាឃុំអង្គរអង់), ឆាយ (លេខាឃុំស្វាយភ្លោះ), អឿន (លេខាឃុំកោះចេក), ប៊ុនថន (លេខាឃុំសំបួរ), ម៉ៅ (ប្រធានឃុំកោះរកា), ឡេង (លេខាឃុំកោះកុង), កាន (លេខាឃុំកោះសំពៅ), ស៊ិន់ (លេខាឃុំតាហ៊ីុយ)។

នៅក្នុងឆ្នាំ១៩៧២ ពូម៉េង និង បងវ៉ែន បានសរសេរសំបុត្រឲ្យខ្ញុំទៅណែនាំកម្លាំងទៅតាមឃុំដើម្បីហាមឃាត់មិនឲ្យប្រជាជនចាប់ត្រីតាមឡូត៍បុបឹង។ កន្លែងណាដែលមានត្រីច្រើនត្រូវបានហាមមិនឲ្យចាប់ទេ ឲ្យចាប់កន្លែងមានត្រីតិច កន្លែងណាមានត្រីច្រើនគឺទុកឲ្យកងទ័ពវៀតណាមចាប់ហូប។ ខ្ញុំបានបំផុសឲ្យប្រជាជនស្រឡាញ់កងទ័ពវៀតណាម និងជួយឧបត្ថម្ភដល់កងទ័ពវៀតណាមដែលបានមកបោះទីតាំងនៅក្នុងទឹកដីខ្មែរ។

នៅក្នុងឆ្នាំ១៩៧៣ ពូម៉េង បានចាត់តាំងខ្ញុំ និង បងរ៉ែត ឲ្យទាក់ទងជាមួយ ពូឈូក ដោយឲ្យខ្ញុំយកសំបុត្ររបស់គាត់ឲ្យ ពូឈូក។ ខ្លឹមសារសំបុត្រនោះ ពូម៉េង បានប្រាប់ ពូឈូក ពីការកសាងកម្លាំងនៅក្នុងស្រុកពាមជរ។ ចុងឆ្នាំ១៩៧៣ ពូម៉េង បានចាត់តាំងខ្ញុំឲ្យទៅណែនាំ បងឡេ, បងស៊ិាន ឲ្យធ្វើសកម្មភាពដឹកនាំប្រជាជនមិនឲ្យទប់ទឹកទុកធ្វើស្រូវ ហើយសាបស្រូវក្នុងទឹកឲ្យរលួយខូច។

នៅក្នុងឆ្នាំ១៩៧៤ ពូម៉េង បានដកខ្ញុំចេញពីនីរសារឲ្យទៅទទួលអនុប្រធានឃោសនាក្នុងស្រុកពាមជរ ហើយណែនាំខ្ញុំឲ្យធ្វើសកម្មភាពទាក់ទងជាមួយបងខេង (ប្រធានឃោសនាការ) ដែលត្រូវជាប្អូនប្រុសរបស់ពូម៉េង។ ពីរខែក្រោយមក ពូម៉េង បានចុះមកចាត់តាំងដោយហៅខ្ញុំ, បងខេង និង មិត្តសា មកប្រជុំ ហើយប្រគល់ភារកិច្ចឲ្យ បងខេង ដើរឃោសនាតាមឃុំ ធ្វើសកម្មភាពវាយប្រហារបដិវត្តន៍ ដែលមិនអាចមានលទ្ធភាពដោះស្រាយជីវភាពប្រជាជនបាន និងឃោសនាប្រជាជនឲ្យលះបង់ទ្រព្យសម្បត្តិរួមដាក់ជាឯកជន។ ក្រៅពីនេះមុខសញ្ញានីមួយៗត្រូវកសាងកម្លាំងបន្តទៀត ដើម្បីបង្កប់ខ្លួនធ្វើការតស៊ូជាមួយបដិវត្តន៍ដណ្ដើមរដ្ឋអំណាចពីបដិវត្តន៍វិញនៅថ្ងៃអនាគតខាងមុខ។ នៅចុងឆ្នាំ១៩៧៤ ពេលប្រជាជនកើតមានជំងឺគ្រុនចាញ់។ ពូម៉េង បានណែនាំឲ្យខ្ញុំទាក់ទងជាមួយ បងសារី នៅខាងផ្នែកពេទ្យ ហើយបានណែនាំបងសារី កុំឲ្យយកថ្នាំល្អៗទៅព្យាបាលប្រជាជន យកតែថ្នាំណាគុណភាពអន់ដែលផលិតបានដោយខ្លួនឯងទៅព្យាបាល ដើម្បីធ្វើឲ្យប្រជាជនមានទំនាស់ជាមួយបដិវត្តន៍។ ពេលខ្ញុំត្រឡប់មកកាន់ការដ្ឋានវិញ ចំពេលស្រូវទុំ ខ្ញុំមិនបានឲ្យកម្លាំងទុកដាក់ស្រូវឲ្យបានស្រួលបួលនោះទេ គឺធ្វើឲ្យស្រូវត្រូវទឹកភ្លៀង និងជ្រូកស៊ីអស់ប្រមាណជាង១០បាវ។ ម្យ៉ាងទៀត នៅពេលដែលយោធាត្រូវការកម្លាំងជួយដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវ ខ្ញុំក៏មិនឲ្យកម្លាំងនោះទៅដែរដោយយកលេសថាខ្វះនេះខ្វះនោះ។

នៅដើមឆ្នាំ១៩៧៥ មុនពេលរំដោះ ជនជាតិវៀតណាមឈ្មោះ ហាញ៉ា បានអញ្ជើញ ពូម៉េង, ពូហ៊ុម, បងខេង, បងយ៉េង, ពូលាក់ និងឃីន(អនុលេខាស្រុកបាភ្នំ), ឈួន (លេខាស្រុកពាមរក៍), កន (អនុប្រធានការដ្ឋាន



គុកទួលស្លែង ឬ មន្ទីរសន្តិសុខស-២១ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌល ឯកសារកម្ពុជា)

៣គោនរបស់ស្រុកពាមជរ), ផន (ជំនួយការសេនាធិការយោធាតំបន់២៤), សុក (ប្រធានពាណិជ្ជកម្មស្រុកកោះជ័យ) និង មិត្តប៊ុនថន ទៅជួបដោយខ្ញុំជាអ្នកបើកកាណូត។ យើងធ្វើដំណើរតាមមាត់ទន្លេតូច ទៅដល់ទីតាំងប្រជុំនៅកោះសាកូ ក្នុងទឹកដីវៀតណាម។ ការជួបគ្នានេះក្នុងគោលបំណងរឹតចំណងមិត្តភាពរវាងកម្ពុជា និងវៀតណាម និងដឹកនាំពាណិជ្ជកម្មពីកម្ពុជាទៅវៀតណាម។ មួយសប្តាហ៍បន្ទាប់ពីត្រឡប់មកពីប្រជុំវិញ ពូម៉េង បានហៅកម្លាំងគាត់ទាំងអស់នៅតាមឃុំមកប្រជុំនៅមន្ទីរស្រុករួមមានៈ គឺហៅ ម៉ៅ, បងឡេ, បងកាន, បងស៊ិន់, បងស៊ាន, បងឆាយ, បងអឿន, ប៊ុនថន, បងខេង និងខ្ញុំ។ ខ្លឹមសារនៅក្នុងការប្រជុំ ពូម៉េង ស្នើសុំគោនៅគ្រប់ឃុំទាំងអស់ចំនួន៥០០ក្បាល នៅក្នុងស្រុកពាមជរ ជាថ្នូរវៀតណាមជួយខាងយោធា វាយរំលំបដិវត្តន៍ខាងមុខ។ កន្លះខែក្រោយមក តាមភូមិនីមួយៗ បានយកគោមកដាក់នៅកន្លែងខ្ញុំជាបន្តបន្ទាប់ ហើយ ពូម៉េង បានចាត់តាំងកម្លាំងរបស់ដែលអប់រំបានចំនួន ៣នាក់ឲ្យដឹកគោទាំងនោះម្តង៥០ក្បាល ទៅ ១០០ក្បាល ឲ្យ ហាញ៉ា នៅតាមព្រំដែន។ ក្នុងរយៈពេលកន្លះខែ កម្លាំងរបស់ ពូម៉េង ដឹកគោឲ្យវៀតណាមបានចំនួន ៥០០ក្បាលតាមច្រកទន្លេតូច។

នៅឆ្នាំ១៩៧៦ ក្រោយពី ពូម៉េង បានឡើងទៅជួប ពូឈូក ពូម៉េងបាន ហៅ បងខេង បងម៉ៅ ,បងឡេង, បងកាន, បងស៊ិន់, ស៊ាន, បងឆាយ, បងអឿន, ប៊ុនថន, បងគា, ជាតិ, មិត្តយុត និងខ្ញុំទៅប្រជុំនៅមន្ទីស្រុក។ ចំណែកខ្លឹមសារ ពូឈូក បានដាក់ផែនការក្នុងការធ្វើរដ្ឋប្រហារបដិវត្តន៍នៅក្នុងតំបន់២៤ នៅខែតុលា ហើយត្រូវត្រៀមស្បៀងឲ្យបានគ្រប់គ្រាន់, ត្រៀមកម្លាំងឈ្លបឲ្យបាន១២នាក់នៅក្នុង១ឃុំ ត្រៀមកម្លាំងនៅពេលមានរដ្ឋអំណាចថ្មី។ នៅខែសីហា ពូម៉េង បានហៅបងសាវី, មិត្តយុត, មិត្តជាតិ, បងគា និងខ្ញុំ មកប្រជុំនៅមន្ទីស្រុកពាមជរ។ ពូម៉េង បានលើកឡើងថា ផែនការធ្វើរដ្ឋប្រហារមិនបានសម្រេចទេ។ បងឈូក ត្រូវបានចាប់ខ្លួនព្រមទាំងខ្សែរបស់យើងនៅតាមតំបន់ និងយោធាមួយចំនួនទៀតដែលជាអ្នកដឹកនាំ។ នៅក្នុងតំបន់ ២៤ មានតែស្រុកពាមជរតែមួយប៉ុណ្ណោះ ដែលអង្គការមិនទាន់សង្ស័យ ហើយនៅមាន តាជ័យ ដែលជាអនុប្រធានស្រុក២៤។ ចំណែកការសម្ងាត់ត្រូវប្រុងប្រយ័ត្នឲ្យមែនទែន ហើយបន្តធ្វើសកម្មភាព។

នៅខែមករា ឆ្នាំ១៩៧៧ តាចាន់បានដក ពូម៉េង ឲ្យទៅទទួលប្រធានសេដ្ឋកិច្ចតំបន់២៤។ បងសាវ៉ាន ត្រូវបានចាត់តាំងជាលេខាស្រុកពាមជរ, បងឆានជាអនុ, បងហ៊ាន សមាជិក, បងសំអាន សមាជិក ហើយខ្ញុំ និងបងសាវ៉ានជាប្រធានសន្តិសុខស្រុកពាមជរ ហើយឲ្យបងគាជាអនុវិញ។ នៅក្នុងឆ្នាំ១៩៧៧ ស្រុកពាមជរបានទទួលប្រជាជនមកពីព្រំដែនតំបន់ ២៣ ចំនួន ៥០គ្រួសារ មកនៅតាមឃុំ។ ពេលនោះបងសាវ៉ាន និង បងសំអាន បានណែនាំខ្ញុំ និងបងគា ឲ្យធ្វើសកម្មភាពបំផុសប្រជាជនថ្មី និងប្រជាជនចាស់ឲ្យមានទំនាស់ជាមួយគ្នា ។ នៅខែកក្កដា ឆ្នាំ១៩៧៧ បងសាវ៉ាន បងសំអាត បានហៅបងសាវី, មិត្តយុត, មិត្តជាតិ, បងខេង, មិត្តសាមាន, បងគា និងខ្ញុំមកប្រជុំនៅមន្ទីរស្រុកពាមជរ។ បងសាវ៉ានបានផ្សាយពីផែនការឲ្យដឹងថា ត្រូវប្រមូលកម្លាំងចល័តនារីនៅតាមឃុំ, កម្លាំងទាំងអស់ត្រូវត្រៀមលក្ខណៈសម្បត្តិដើម្បីមានសភាពការណ៍កើតឡើង គឺយើងមានម្ចាស់ការជាមុនស្រេច។ តាមផែនការចាត់តាំងត្រូវឲ្យមានប្រធាននារីស្រុក ដើម្បីចុះធ្វើសកម្មភាពនៅតាមភូមិ

ឃុំជាមួយយោធានារីៗ ក្រោយពីប្រជុំចប់ បងសាវ៉ាន និងបងសំអាត បានប្រមូលកម្លាំងចល័តនៅតាមឃុំទាំងអស់បាន១៥០នាក់ រៀបចំកងទ័ពមួយកងអនុសេនាធំៗ

នៅខែមករា ឆ្នាំ១៩៧៨ ខាងប្រធាននារីស្រុកបានរាយការណ៍ថា ចាប់ប្រជាជន២នាក់ មិនព្រមអនុវត្តរបបឯកជន មកដាក់នៅក្នុងសន្តិសុខរបស់ខ្ញុំៗ ខែកុម្ភៈ បងសាវ៉ាន បានហៅកម្លាំងនៅតាមមូលដ្ឋានទាំងអស់ និងមន្ទីរជុំវិញស្រុក ទាំងអស់មកប្រជុំនៅក្នុងមន្ទីរ ស្រុកពាមជរ គឺមានឈ្មោះ បងកាក់, មិត្តយុត, មិត្តជាតិ, មិត្តសាមាន, បងសាវី, បងខេង, បងគា, បងឡេង, បងកាន, បងម៉ៅ, បងអឿន, បងឆាយ, បងស៊ាន, បងស៊ិន់, បងសំអាន, បងប៊ុនថន ខ្ញុំ និង បងយ៉េង (លេខាស្រុកបាភ្នំ)ៗ នៅពេលប្រជុំ បងសាវ៉ាត បានលើកឡើងអំពីផែនការថ្មីត្រៀមធ្វើរដ្ឋប្រហារវាយផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីកសាងបក្សថ្មីមួយ និងកែប្រែរបបសង្គមឲ្យទៅជារបបឯកជនៗ ផែនការដែលត្រូវធ្វើនៅខែឧសភា ឆ្នាំ១៩៧៨ ខាងមុខមនេះៗ

ខែមេសា ឆ្នាំ១៩៧៨ បងយ៉េង បានហៅខ្ញុំ និងមិត្តជាតិ ទៅជួបគាត់នៅមន្ទីរស្រុកពាមជរ ហើយគាត់បានណែនាំខ្ញុំថា ឥឡូវប្អូនឯងទាំងពីរនេះត្រូវនាំអង្ករ២៥បាវ ឲ្យកម្លាំងយោធារបស់បង សាវ៉ានៗ បងយ៉េង ក៏បានចាត់តាំង៣០នាក់ បង្កប់ទុកនៅក្នុងស្រុកពាមរក៍ ដើម្បីជាកម្លាំងសម្រាប់ធ្វើរដ្ឋប្រហារៗ នៅខែមេសា ឆ្នាំ១៩៧៨ បងយ៉េង បានហៅកម្លាំងនៅជុំវិញមន្ទីរទាំងអស់មកប្រជុំនៅមន្ទីរស្រុកពាមជរ នៅម៉ោង៧ព្រឹកៗ មានឈ្មោះ បងសំអាត, បងខេង, មិត្តយុត, បងសាវី, មិត្តជាតិ, មិត្តសាមាន, បងគា, នារីមឿន និងខ្ញុំៗ បងយ៉េង បានណែនាំមកគឺត្រូវធ្វើរដ្ឋប្រហារ នៅក្នុងភូមិភាគបូព៌ា ដែលកម្លាំងយើង គឺជាកម្លាំងយោធារបស់ភូមិភាគ សហការជាមួយកងទ័ពវៀតណាម តាមផ្លូវជាតិលេខ៧មុនគេៗ ក្រោយប្រជុំខ្ញុំបានចាត់ឲ្យមិត្តសែមចុះ ទៅឃុំអង្គអង់ ជាមួយកម្លាំងនារីរ៉ា, មិត្តសានទៅឃុំព្រែកក្របៅជាមួយនារីមឿន, បងគា ចុះទទួលនៅឃុំកោះចេក និងឃុំសំបួរ ជាមួយកម្លាំងនារីមួន ដើម្បីត្រៀមធ្វើរដ្ឋប្រហារៗ នៅពាក់កណ្តាលខែឧសភា បងយ៉េត បានទៅជួបបងសាវ៉ានៗ នៅទីនោះបានរយៈពេល៣យប់ បងយ៉េន បានត្រឡប់មកវិញ ហើយបានហៅមិត្តសំអាន, មិត្តយុត, បងខេង, បងសាវី, បងគា, មិត្តសាមាន, មិត្តជាតិ នឹងខ្ញុំមកប្រជុំម្តងទៀតៗ បងយ៉េងមានមតិថា ផែនការយើងធ្វើនៅផ្លូវជាតិលេខ៧នេះ ឥឡូវមកមិនដល់ផ្លូវជាតិលេខ១១ទេ ព្រោះមានកងទ័ពអង្គការវាយកាត់ជាចំៗជាកង់ៗ និងព័ទ្ធជុំវិញអស់ហើយៗ តាមផែនការពីបង សាវ៉ាន យើងត្រូវត្រៀមធ្វើរដ្ឋប្រហារនៅខែសីហា ឆ្នាំ១៩៧៨ ខាងមុខៗ លើកនេះគឺយើងយកកម្លាំងប្រជាជន និងកងទ័ពរួមគ្នាធ្វើតែម្តង ដោយនៅស្រុកណា ស្រុកនោះធ្វើ តំបន់ណា តំបន់នោះធ្វើ ឲ្យព្រមគ្នាតែម្តងៗ ក្រោយពីប្រជុំចប់ កម្លាំងនៅត្រៀមដូចមុនដដែល ដោយឡែកតែកម្លាំងកងចល័តដែលយកមកចម្រុះជាមួយយោធានារី នោះដកទៅឲ្យកាប់ព្រៃវិញឯកម្លាំងយោធានៅត្រៀមដដែលៗ ដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអង្គការចាប់ខ្លួនតែម្តងៗ

កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ម៉ុម ចក់ ពិតប៉ុណ្ណាណានោះទេៗ

# វិចិត្រសាលសិល្បៈ សហសម័យវិទ្យាស្ថានស្លឹករឹត









វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថាន ស្លឹករឹត ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែល ដែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីសិល្បៈ និងវប្បធម៌ តាមរយៈការតាំងពិព័រណ៍ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានាៗ វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់ និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួនៗ

សម្រាប់សិស្ស-និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍មកទស្សនានៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) និងវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត, សូមទាក់ទងមកកាន់ **ស៊ាង ចិន្តា** អ្នកសម្របសម្រួល តាមរយៈ ទូរសព្ទលេខ ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!

# តែ សួរ ៖ គិញ

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D00១៩២

*ដារ៉ារដ្ឋ មេត្តា*



កម្មកររោងចក្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) កំពុងរៀបចំបត់ និង ចងក្រណាត់ ក្រមា ស្បៃមុង ដែលផលិតបាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ តែ សួរ អាយុ៣៦ឆ្នាំ។ ខ្ញុំមានតួនាទីជានារី អនុប្រធានកងធំ អង្គភាពកាត់ដេររដ្ឋ។ ខ្ញុំរៀបការរួចហើយ។ ខ្ញុំមានស្រុកកំណើតនៅភូមិ ត្បូងក្រពើ ឃុំត្បូងក្រពើ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ខ្ញុំរៀនត្រឹមថ្នាក់ទី១០ នៅសាលាភូមិអូរ។ ក្រោយមកខ្ញុំក៏បានឈប់រៀននៅក្នុងឆ្នាំ១៩៥២ និងត្រឡប់មកផ្ទះរស់នៅជាមួយឪពុកម្តាយ។ ខ្ញុំបានទៅធ្វើជាកម្មករកៅស៊ូនៅក្នុងស្រុកមេមត់ ខេត្តកំពង់ចាម រហូតដល់ឆ្នាំ១៩៥៦។ បន្ទាប់ពីខ្ញុំឈប់ធ្វើជាកម្មករកៅស៊ូ ខ្ញុំសម្រេចចិត្តធ្វើជាគិញ ដោយគិតថាអាចជួយបម្រើដល់ប្រទេសជាតិ។ ខ្ញុំបានចូលធ្វើជាគិញតាមរយៈឈ្មោះ យឿ (មេប៉ូលីស) ដែលតែងតែអប់រំខ្ញុំអំពីសភាពការណ៍របស់ខ្មែរក្រហមដែលកើតមាននៅក្នុងប្រទេស។ បងយឿ បានចាត់តាំងខ្ញុំ, ខែម និង សយ ធ្វើដំណើរទៅទីរួមស្រុកក្រចេះដើម្បីទាក់ទងជាមួយឈ្មោះ សៅ (គិញ) ដែលជាអតីតគ្រូបង្រៀនធ្វើការនៅក្នុងស្រុកស្នួល។ យើងទាំង៣នាក់ និងឈ្មោះ សៅ បានយល់គ្នា នឹងធ្វើជាគិញតាមដានខ្មែរក្រហមចាប់តាំងពីពេលនោះមក។

នៅឆ្នាំ១៩៥៧ យើងចាប់បានខ្មែរក្រហមម្នាក់ឈ្មោះ ស៊ីវ និងកសាងបានកម្លាំងម្នាក់ឈ្មោះ ចាន់ បូរ៉ែត។ បន្ទាប់មក យឿ បានផ្តាំ សៅ ឲ្យខ្ញុំទៅជួបគាត់នៅសាលាស្រុកមេមត់។ ខ្ញុំបានជួបបង យឿ នៅសាលាស្រុក



ស្វែងរកការពិត-ផ្នែកឯកសារ លេខ២៤៣ ខែមីនា ឆ្នាំ២០២០

និងឈ្មោះ ស សាវ៉ាន់ (អតីតកុម្មង់ដូរប៉ូលីស)។ បង យឿ ចង់ឲ្យខ្ញុំធ្វើជាប៉ូលីសប្រចាំនៅមេមត់វិញ។ មួយអាទិត្យក្រោយមក ស សាវ៉ាន់ បានហៅខ្ញុំមកបំពេញកិច្ចការ និងបំពាក់ឯកសណ្ឋានប៉ូលីសឲ្យខ្ញុំ ថែមទាំងបានប្រគល់ការងារឲ្យខ្ញុំទាក់ទងមនុស្សតាមឃុំ និងជ្រើសរើសទាហានថ្មីតាមផែនការរបស់ស័ក្តិពីរ ប្រាក់ ស៊ីមន ដែលជាគណៈមេបញ្ជាការទាហាន ខេត្តកំពង់ចាម ដើម្បីត្រៀមផែនការនៅឆ្នាំ១៩៦០។ ក្នុងការជ្រើសរើសទាហានថ្មី ខ្ញុំបានទំនាក់ទំនងមេឃុំបង្កោល, មេឃុំមាស និង មេឃុំត្រមូង។ មេឃុំទាំងនេះសុទ្ធតែបានយល់ព្រមក្នុងការជ្រើសរើសទាហានថ្មី។ សកម្មភាពនេះបក្ខពួកខ្ញុំនៅតែអនុវត្តបន្តដល់ឆ្នាំ១៩៦៨ ព្រមទាំងមានផែនការកសាងកម្លាំង និងបង្កប់តាមមូលដ្ឋានភូមិឃុំជនបទទៀតផង។ ស សាវ៉ាន់ បានណែនាំខ្ញុំបន្ថែមឲ្យទាក់ទងជាមួយឈ្មោះ ស ប៊ុនី ដែលជាមេគិញនៅក្នុងស្រុកមេមត់ទៀត។ បីថ្ងៃក្រោយមក ស ប៊ុនី បានហៅខ្សែគិញតាមភូមិឃុំ មកប្រជុំនៅផ្ទះរបស់គាត់ផ្ទាល់។ ការប្រជុំនោះ គឺការដាក់ផែនការកសាងកម្លាំង ដោយមានសមាជិក១៣នាក់ចូលរួម។ នៅក្នុងឆ្នាំ១៩៦៨ បង ស សាវ៉ាន់ បានអប់រំខ្ញុំជាញឹកញាប់ថា ដើម្បីអនាគតរបស់យើង និងប្រទេសជាតិយើង គឺត្រូវចូលខ្មែរសេរី។ បន្ទាប់មកបង កែវ សង្វារ អតីតចៅហ្វាយស្រុកមេមត់ បានអប់រំខ្ញុំបន្ថែមទៀតឲ្យខ្ញុំចូលជាមួយខ្មែរសេរី ដែលស្ថិតនៅក្រោមការចាត់តាំងរបស់គាត់ផ្ទាល់។

នៅឆ្នាំ១៩៦៩ ខ្ញុំមករស់នៅខេត្តសៀមរាប ដើម្បីទាក់ទងជាមួយខ្មែរសេរី តាមការចាត់តាំងរបស់ កែវ សង្វារ។ ខ្ញុំបានជួបជាមួយ ថង (មេប៉ូលីស) លើកដំបូងហើយបានពិភាក្សាគ្នា ដើម្បីយល់គ្នាទៅវិញទៅមកពីការទាក់ទងភ្ជាប់ខ្សែ ដើម្បីងាយស្រួលធ្វើសកម្មភាពរួមគ្នា។

នៅក្នុងឆ្នាំ១៩៧០ ក្រុមខ្ញុំកសាងបានកម្លាំងបាន៦នាក់គឺ ១) ស៊ិវត (ប្រធានភូមិអន្លង់វិល) ២) វ៉ឺ (ប្រធានភូមិទទឹងថ្ងៃ), ៣) លួត (អតីតប្រជាជនភូមិថ្លុកត្របែក), ៤) ភាវ (ប្រធានសហករណ៍ភូមិពាន់ស្តាន), ៥) ហេង (ប្រជាជននៅភូមិអន្លង់វិល) និង ៦) ឆុន (អនុប្រធានសហករណ៍ភូមិអូរលើ)។



កម្មករនៅរោងចក្រផលិតជ័រកៅស៊ូ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) កំពុងរុញរទេះកៅស៊ូក្រែប។ (ហ៊ុនណា បីយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្មកររោងចក្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) កំពុងកូរជ័រកៅស៊ូ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្មករនៅរោងចក្រផលិតជ័រកៅស៊ូក្រែបភូមិភាគបូព៌ា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) កំពុងចងក្រៀកឡាំងកៅស៊ូ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយមកឈ្មោះ ឈឺវ គឺជាប្រធានឃុំសង្កើយបានចាត់តាំងខ្ញុំជាគណៈភូមិចងរោង។ ក្នុងការចាត់តាំងនេះមានមនុស្ស៤នាក់ គឺខ្ញុំជាប្រធានភូមិ, ឈន់ អនុភូមិ, សៃ សមាជិកទី១ភូមិ និង ឆាន់ សមាជិកទី២ភូមិ។ ខ្ញុំនៅតែបន្តសកម្មភាពអប់រំ, កសាងកម្លាំង និងប្រឆាំងជាមួយបដិវត្តន៍។ ខ្ញុំបានធ្វើសកម្មភាពបំផុសប្រជាជនឲ្យលក់គោក្របី កុំទុកចិត្តខ្មែរក្រហមច្រើនពេកនាំពិបាកថែរក្សាគោក្របី ព្រោះយើងធ្វើការងាររួមហើយ។

នៅក្នុងឆ្នាំ១៩៧២ ខ្ញុំបានជួបជាមួយ ឈឺវ ហើយគាត់បានឲ្យខ្ញុំទាក់ទងជាមួយឈ្មោះ ម៉ូវ ប្រម (ប្រធានសហករណ៍ភូមិអូរក្រោម) និង ពាន់ (កម្មករឃុំចាស់រស់នៅក្នុងភូមិអូរក្រោម) ដើម្បីកសាងកម្លាំងប្រចាំឆ្នាំ និងអនុវត្តផែនការនៅក្នុងឆ្នាំ១៩៧២។ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានមកនៅឃុំសង្កើយដើម្បីទាក់ទងការងារពី ឈឺវ។ ឈឺវ ប្រាប់ខ្ញុំថានឹងរៀបចំកម្លាំងយោធាថ្មីបង្កប់នៅខាងក្នុង ដែលជាកម្លាំងស្លូលប្រឆាំងជាមួយបដិវត្តន៍។ ឈឺវ បានឲ្យខ្ញុំរង់ចាំគាត់បន្តិច ហើយក្រោយមកខ្ញុំបានឃើញមនុស្សបីនាក់ដើរចូលមករកគាត់ មានឈ្មោះ សែម នារីបដិវត្តន៍ប្រចាំស្រុកជីក្រែង ខេត្តសៀមរាប, សុខ នារីបដិវត្តន៍ ប្រចាំឃុំប៉ុស្សី និង សឿន នារីបដិវត្តន៍នៅយោធាស្រុកជីក្រែង។ ពេលនោះ បងសែម បានលើកឡើងថាតាមការណែនាំរបស់ បងឃួន (ខាងភូមិភាគ) ផែនការនៅឆ្នាំ១៩៧៤ខាងមុខ គឺស្រុកជីក្រែករបស់យើងត្រូវជ្រើសរើសយោធាឲ្យបានមួយវរសេនាតូច។

នៅចុងឆ្នាំ១៩៧៤ បងឃួន បានផ្លាស់ប្តូរកងវរសេនាតូច៥៦៦ ឲ្យទៅជាកងវរសេនាតូចលេខ៧០៧វិញ និងបានប្តូរប្រធានវរសេនាតូចឈ្មោះ គ្រី ចេញ ហើយយកឈ្មោះ រ៉ុង (យោធានារីខាងមណ្ឌលគិរី) មកជំនួសវិញ។ ក្រោយពីផ្លាស់លេខវរ និងប្រធានវរមក នៅដើមឆ្នាំ១៩៧៥ អង្គភាព៧០៧ ត្រូវបានបញ្ជូនមកសមរភូមិភ្នំពេញដែលមានមុខព្រួញ នៅភូមិធំ និងផ្លូវលំបាសិត។ បន្ទាប់ពីអង្គភាពខ្ញុំចូលដល់ក្រុងភ្នំពេញហើយ ខ្ញុំទៅមុខព្រួញនៅទួលគោក។

នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំទទួលផែនការ និងធ្វើសកម្មភាពតាមការលើកឡើងរបស់បង ឃួន ឲ្យដុតផ្ទុះឆេះអស់ជាច្រើនកន្លែង ជាពិសេស ឆេះឃ្លាំងផ្សារចាស់ ធ្វើឲ្យខូចឡានដឹកធំៗ (២៥គ្រឿង), ខូចម៉ូតូ (៥០គ្រឿង), ដឹកខោអាវ១០ឡានយកទៅចោលនៅព្រែកព្នៅ, យកសារធាតុគីមីលាយជាមួយស្ករ (១០០បាវ) ឲ្យខូចគុណភាព និងធ្វើឲ្យខូចម៉ាស៊ីនការណូត៨គ្រឿង។

នៅខែកុម្ភៈ ឆ្នាំ១៨៧៦ បងគុណ (ខាងភូមិភាគ) បានទៅចូលរួមក្រុមខ្ញុំដែរ ក្នុងនោះមានខ្ញុំនិងមនុស្សចូលរួមចំនួន១៦នាក់ទៀត។ ក្នុងការប្រជុំនោះគឺលើកផែនការសម្ងាត់ទៅក្នុងឆ្នាំ១៩៧៦។ តាមការណែនាំរបស់បងឃួន ការធ្វើរដ្ឋប្រហារផ្តួលរំលំបដិវត្តន៍ គឺកំណត់យកថ្ងៃ១៧ មេសា ដែលជាថ្ងៃបុណ្យខួបនៅស្តាត ហើយបងឃួន បានចាត់តាំងកម្លាំងទទួលបាយទឹកកងទ័ពធ្វើរដ្ឋប្រហារ។ បន្ទាប់ពីផែនការនេះ បងគុណ បានចាត់តាំងខ្ញុំ និងបងហេង(ប្រធានកងធំកាត់ដេររដ្ឋ), សាន (ប្រធានក្រុមកាត់ដេររដ្ឋ) ឲ្យលាក់សម្ភារទុកនៅក្នុងឃ្លាំង ទុកគ្រឿងឡានគ្រប់ប្រភេទ (៤ឃ្លាំង), ប្រេងសាំងចម្រុះ(៩០ធុង), គ្រឿងម៉ូតូហុងដាប្រភេទ៩០ (៥០គ្រឿង), ម៉ាស៊ីនឡាន និង ម៉ាស៊ីនការណូតចម្រុះ (៨គ្រឿង), អង្ករ (១០០បាវ), អំបិល(១០០បាវ), ក្រណាត់ខោអាវ ក្រម៉ា (២ឃ្លាំង), ថ្នាំពេទ្យគ្រប់ប្រភេទ ២ឃ្លាំង, ចានឆ្នាំងគ្រប់ប្រភេទ(៣ឃ្លាំង), គ្រឿងកង់(៥០គ្រឿង), ស្រាជបគ្រប់ប្រភេទ និង ប៊ីយែ(១ឃ្លាំង) ។ ជាមួយគ្នានេះ បងគុណ ចាត់តាំងខ្ញុំឲ្យរកឡានដឹកអង្ករ ១៥បាវ និងកាំភ្លើង ២៥ដើម ទៅភ្នំបាសិត ដោយមានយ៉ា (កាត់ដេររដ្ឋ), ប៊ូ មឿន ប្រធានសហករណ៍កំពង់ខស យកទៅប្រគល់បន្តឲ្យកម្លាំងនៅក្នុងព្រៃនៅភ្នំបាសិត។ បង គុណ ដឹកអង្ករ១០០បាវ ទៅស្រុកចម្ការលើឲ្យកងទ័ពព្រៃតាមរយៈឈ្មោះ ឌួង។ ចំណែកឡានមួយទៀតដឹកថ្នាំពេទ្យទៅសៀមរាប។ យើងខ្ញុំបានរង់ចាំរដ្ឋប្រហារយ៉ាងស្ងៀមស្ងាត់។ រហូតដល់ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនបងឃួន និង បងគុណ។ នៅឆ្នាំ១៩៧៧ ដដែល ខ្ញុំបានភ្ជាប់ខ្សែរយៈជាមួយនារី ខន វិញ។ យើងបានអនុវត្តផែនការកម្ទេចសម្ភារប្រើប្រាស់ប្រចាំថ្ងៃ។ រហូតដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំតែម្តង។

*កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ តែ សួរ ពិតប្រាកដយ៉ាងណានោះទេ។*

# តាំ ឡូន៖

## អតីតកងទ័ពជើងទឹកឈរជើងនៅកោះតាង

ហូ ចុនា

ខ្ញុំឈ្មោះ តាំ ឡូន គឺជាអតីតកងទ័ពជើងទឹកនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំបានពិការភ្នែកម្ខាងនៅពេលប្រយុទ្ធនៅសមរភូមិ។ ក្រោយមកខ្ញុំត្រូវរបួសចំភ្នែកម្ខាងទៀតដែលធ្វើឲ្យខ្ញុំមើលមិនច្បាស់រហូតមកដល់សព្វថ្ងៃ។

កាលពីកុមារខ្ញុំបានចូលរៀនសូត្រ នៅសាលាវត្តប្រភ្នំ។ កាលនោះខ្ញុំរៀនភាសាបារាំងដែរ ដូច្នេះខ្ញុំអាចនិយាយភាសាបារាំងបានតិចតួច។ នៅឆ្នាំ១៩៦៩ ខ្ញុំបានរៀនដល់ថ្នាក់ទី៨ក៏ឈប់រៀន ព្រោះបងប្អូនប្រុសស្រីរបស់ខ្ញុំមួយចំនួនបានរៀបការប្តីប្រពន្ធ ដូច្នេះខ្ញុំត្រូវនៅជួយការងារឪពុកម្តាយ។ បន្ទាប់ពីខ្ញុំឈប់រៀនបានប្រហែលមួយឆ្នាំ ក៏មានរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ចេញពីតំណែង ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ មិនយូរប៉ុន្មានសម្តេចព្រះ នរោត្តម សីហនុ បានអំពាវនាវទៅដល់កូនចៅ និងជនរួមជាតិដែលស្រឡាញ់ និងគោរពព្រះអង្គឲ្យរត់ចូលព្រៃម៉ាគីដើម្បីតស៊ូ។ ខ្ញុំ និងប្រជាជននៅក្នុងភូមិ៦នាក់ ផ្សេងទៀត ក៏បានស្ម័គ្រចិត្តចូលធ្វើកងទ័ពខ្មែរក្រហម ដើម្បីផ្តួលរំលំរបប លន់ នល់ យកអំណាចថ្វាយព្រះអង្គវិញ។ ខ្ញុំត្រូវបានបញ្ចូលទៅក្នុងអង្គភាពយោធាខ្មែរក្រហមនៅថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៧០ ដោយដំបូងអង្គភាពរបស់ខ្ញុំនៅជាមួយអង្គភាពយោធារបស់វៀតកុង វៀតណាមខាងជើង (ក្នុងកងពលលេខ៧ ឬលេខ៩) បោះទីតាំងនៅក្នុងឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត និងមានជនជាតិវៀតណាមឈ្មោះ បែសើង ជាអ្នកគ្រប់គ្រង។ នៅក្នុងអង្គភាពបែសើង ក៏មានកងទ័ពជាជនជាតិខ្មែររាប់រយនាក់ឈរជើងនៅទីនោះដែរ។ នៅអំឡុងពេលនោះខ្ញុំបាន



តាំ ឡូន រស់នៅក្នុងភូមិក្រពើពីរ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ព និងទ្រឹស្តីជាក់ស្តែងពីសំណាក់គ្រូបង្វឹកជាជនជាតិយួនដែលគាត់អាចប្រើប្រាស់ភាសាខ្មែរបានតិចតួច។ ខ្ញុំបានហាត់រៀនពីរដងក្នុងមួយថ្ងៃ ដោយក្នុងរយៈពេលពីមួយអាទិត្យទៅពីរអាទិត្យ ទៅតាមពេលវេលាដែលអាចធ្វើទៅបាន។ នៅពេលដែលខ្ញុំទទួលបានការបំពាក់បំប៉នដែលអាចចេះប្រើកាំភ្លើងបានខ្លះថ្នាក់លើក៏ចាត់តាំងខ្ញុំឲ្យវាយចូលសមរភូមិដើម្បីជាការអនុវត្តផ្ទាល់។ បន្ទាប់ពីខ្ញុំចូលវាយសមរភូមិរួចខ្ញុំក៏បន្តការហាត់រៀនតទៅទៀត។ ចំពោះបច្ចេកទេសហ្វឹកហាត់ គ្រូបង្វឹកបង្ហាត់បានល្អគួរសមដែរ។ ខ្ញុំបានឈរជើង និងហាត់រៀននៅក្នុងអង្គភាពបែសើងរហូតដល់ឆ្នាំ១៩៧៣។ នៅរវាងឆ្នាំ១៩៧០-១៩៧៣ ខ្ញុំបានវាយជាមួយទាហានធីវគីមួយចំនួន ដូចជា នៅសមរភូមិម្តុំភ្នំស្រែ កំពង់ត្រាច តានី-ទូកមាស ផ្សាររដំបង និងវត្តកន្ទាយ ដោយបានប្រើប្រាស់យុទ្ធសាស្ត្រសង្គ្រាមឈ្លប។ ក្នុងការប្រើប្រាស់យុទ្ធសាស្ត្រនេះ ព្រោះតែកងកម្លាំងយើងមានតិចតួចនៅឡើយ។ កងកម្លាំងយើងបានត្រឹមតែលបលួចវាយឆ្មក់សត្រូវតែប៉ុណ្ណោះ ហើយប្រសិនបើសត្រូវតបតមកវិញ កងកម្លាំងយើងនឹងដកថយភ្លាមៗតែម្តង។ កាលដែលធ្វើសកម្មភាពខ្ញុំបានប្រើប្រាស់កាំភ្លើងអាកា (AK) ដល់ក្រោយមកខ្ញុំបានប្រើកាំភ្លើង M-79 ដែលខ្ញុំវាយដណ្តើមបានពីសត្រូវ។ កាំភ្លើង M-79 គឺជាប្រភេទកាំភ្លើងដែលផលិតនៅសហរដ្ឋអាមេរិក និងអាចបាញ់ក្នុងរយៈចម្ងាយ៣៥០ម៉ែត្រ។ កាលនោះ ទាហានធីវគីមានគ្រឿងសព្វាវុធទំនើបៗជាច្រើន ដូចជា រថក្រោះ កាំភ្លើងតូចធំ និងយន្តហោះ៥០គ្រឿង ដែលផ្ទុយពីកងកម្លាំងយើងមានត្រឹមតែគ្រឿងសព្វាវុធចាស់ៗ និងបេ៤០ (B40) តែប៉ុណ្ណោះ។ ហេតុការណ៍ទាំងនេះ បានធ្វើឲ្យខ្ញុំមិននឹកស្មានដល់ថាខ្ញុំអាចរួចរស់ជីវិតមកដល់សព្វថ្ងៃនេះទេ។

នៅចុងឆ្នាំ១៩៧៣ ខ្ញុំបានផ្លាស់ចេញពីអង្គភាពបែសើងដោយមកឈរជើងនៅក្នុងអង្គភាពកងពលទី៣ ដែលខ្មែរក្រហមទើបតែចាប់ផ្តើមបង្កើតឡើង។ អង្គភាពនេះស្ថិតនៅក្នុងភូមិភាគនិរតីដែលត្រូវបានរួមបញ្ចូលកងទ័ពមកពីតំបន់១៣ តំបន់២៥ និងតំបន់៣៣។ កាលនោះខ្ញុំនៅក្នុងកងពិសេសប្រចាំវរសេនាធំ ដោយមានឈ្មោះ មាញ់ គឺជាប្រធាន។ នៅពេលដែលខ្ញុំចូលក្នុងអង្គភាពដំបូងគឺខ្ញុំចាប់ផ្តើមវាយតែម្តង ដោយមិនចាំបាច់ហ្វឹកហាត់តទៅទៀតទេ។ ខ្ញុំបានវាយចូលទីក្រុងភ្នំពេញពីទិសខាងលិច ដោយចាប់ពីមុខព្រួញត្រពាំងក្រឡឹង ក្រាំងកាតន (ទំនប់ប្រាំពីរមករា) ព្រែកត្នោត និងភ្នំវល្លិជាដើម។ ក្រោយមកខ្ញុំបានដកមកវាយនៅខាងត្បូងខេត្តតាកែវ នៅតាមបណ្តោយផ្លូវជាតិលេខ២។ នៅអំឡុងពេលធ្វើសកម្មភាពប្រយុទ្ធខ្ញុំក៏បានរងរបួសគ្រាប់ធីធូពីខាងភាគីនៃកងកម្លាំង លន់ នល់ រហូតដល់ងងឹតភ្នែក។ កងកម្លាំង លន់ នល់ បានបាញ់ចេញពីលើផ្ទះថ្មមួយនៅពេលដែលខ្ញុំកំពុងវាយយកផ្សារកែវ ពេលនោះខ្ញុំឮសូរសំឡេងផាំង ហើយខ្ញុំក៏ចាប់ផ្តើមងងឹតសូន្យឈឹងតែម្តងដោយមិនដឹងថានរណាជាអ្នកសែងខ្ញុំមកព្យាបាលនៅមន្ទីរពេទ្យតាំងពីពេលណានោះទេ។ ក្រោយមកខ្ញុំបានមកសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យ១៩០ ក្នុងស្រុកគានី ខេត្តកំពត ហើយរបួសនេះវាបានធ្វើឲ្យប៉ះពាល់ដល់សរសៃប្រសាទ ដោយមិនអាចគ្រប់គ្រងស្មារតីបានឡើយ។ ពេលខ្លះខ្ញុំបានដើរចេញពីមន្ទីរពេទ្យដោយគ្មានអ្នកណាដឹងទាល់តែសោះ ហើយពេទ្យក៏បានព្យាយាមស្វែងរកដំណឹងខ្ញុំ ដើម្បីយកមកព្យាបាលរបួសបន្តទៀត។ លើសពីនេះទៀតខ្ញុំក៏មិនអាចនិយាយ និងស្តាប់បាននោះដែរ ព្រោះខ្ញុំបានបាក់ថ្គាមបណ្តាលឲ្យពិបាកក្នុងការធ្វើចលនាមាត់។ មិនត្រឹមតែប៉ុណ្ណោះ ខ្ញុំក៏មិនអាចហូបចុកបានឡើយ។ បញ្ហាទាំងអស់នេះវាបានអូសបន្លាយពេលវេលារបស់ខ្ញុំឲ្យសម្រាកព្យាបាលរបួសរហូតដល់ជិតមួយឆ្នាំ។ បន្ទាប់ពីចេញពីមន្ទីរពេទ្យរួចមក ខ្ញុំក៏បានផ្លាស់មករស់នៅក្នុងអង្គភាពពិការដែលមានទីតាំងស្ថិតនៅត្រពាំងអណ្តើក។ បួនខែក្រោយមកខ្ញុំក៏មានស្មារតីធម្មតាវិញ ហើយខ្ញុំក៏បានចាកចេញពីអង្គភាពពិការ ដោយទៅឈរជើងនៅកងពលទី៣ដដែល។ នៅពេលដែលត្រឡប់មកដល់អង្គភាពវិញ អង្គភាពក៏ចាប់ផ្តើមវាយសម្រុកចូលទីក្រុងភ្នំពេញសាជាថ្មីតាមមុខព្រួញកំបូល។

នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយបែកទីក្រុងភ្នំពេញក៏ពិតមែន ប៉ុន្តែខ្មែរក្រហមក៏មិនទាន់បានផ្តួលរបប លន់ នល់ បានទាំងស្រុងនោះដែរ ទើបខ្មែរក្រហមមានផែនការបញ្ជូនកងពលទី៣របស់ខ្ញុំ និងកងពលផ្សេងទៀតមកប្រចាំជើងទឹក ដោយយករថក្រោះ ៨គ្រឿងបើកឆ្លងកាត់ផ្លូវត្រពាំងអណ្តើកឆ្ពោះទៅកំពង់សោម។ មានកងទ័ពខ្លះជិះឡានយោធា ហើយខ្លះទៀតជិះរថក្រោះ។ ចំណែកកងពលខ្ញុំជិះរទេះភ្លើង ហើយបំបែកគ្នាត្រង់ចំណុចវាលរេញ។ បន្ទាប់មកកងកម្លាំងខ្ញុំចាប់ផ្តើមវាយជាមួយទាហាន លន់ នល់ នៅរោងចក្រប្រេងកាត។ ការណ៍ប្រយុទ្ធគ្នានេះបានប្រើរយៈពេល



ទីស្នាក់ការសហគមន៍ការពារធម្មជាតិនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ៗ ( សុខ វណ្ណៈ/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

អស់ពីរសប្តាហ៍ទើបអាចផ្តួលកម្លាំង លន់ នល់ ដែលនៅសេសសល់ៗ មិនយូរប៉ុន្មាន កងកម្លាំងខ្មែរក្រហមទាំងអស់បានមកជួបជុំគ្នានៅព្រលានយន្តហោះកងកេង ដែលស្ថិតនៅភូមិថ្មធំ ខេត្តព្រះសីហនុៗ ក្នុងការជួបជុំគ្នានេះ ខ្មែរក្រហមបានចាប់ផ្តើមរៀបចំទៅតាមវរៈ និងបានផ្លាស់ប្តូរឈ្មោះកងពលចាប់តាំងពីពេលនោះមកៗ ឈ្មោះកងពលទី៣ របស់ខ្ញុំបានផ្លាស់ទៅកងពល ១៦៤ ហើយខ្ញុំក៏បានផ្លាស់ទៅវរសេនាធំ ៦២ ដោយមាន តាមាញ ជាប្រធានដដែលៗ បន្ទាប់ពីរៀបចំរួចមក វរសេនាធំ ៦២របស់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅឈរជើងនៅកោះពស់វែកចាស់ កោះពស់វែកថ្មី កោះព្រីង និងកោះតាងៗ ចំណែកវរសេនាធំ ៦១ ឈរជើងប្រចាំនៅស្ទឹងហាវ ហើយវរសេនាធំ ៦៣ ឈរជើងប្រចាំនៅកោះចំពូច និងកោះចន្ទះៗ ក្នុងពេលនោះដែរខ្ញុំ និងកងទ័ពជាង ១០០នាក់ទៀត បានឈរជើងប្រចាំការនៅកោះតាងៗ ខ្ញុំបានឈរជើងនៅកោះតាងដែលជាកោះតូចមួយក្នុងចំណោមកោះ និងកូនកោះទាំង ៦៤ ដែលស្ថិតក្នុងដែនទឹកសមុទ្រប្រទេសកម្ពុជាៗ កោះនេះស្ថិតនៅប៉ែកនិរតី និងមានចម្ងាយប្រមាណ ៥៧គីឡូម៉ែត្រពីក្រុងព្រះសីហនុ និងជាកោះមួយស្ថិតនៅចន្លោះកណ្តាលពូលូវ៉ៃ និងក្រុងព្រះសីហនុៗ កោះតាងមានទំហំប្រមាណ ៥,៩គីឡូម៉ែត្រការ៉េ បណ្តោយប្រវែង ៦,៤គីឡូម៉ែត្រ និងទទឹងចន្លោះពី ០,១ ដល់ ៣,២គីឡូម៉ែត្រ) និងជាកោះដ៏ស្រស់ស្អាតមួយដែលគ្របដណ្តប់ទៅដោយកូនភ្នំ និងព្រៃឈើប្រមាណ៩០ភាគរយ ហើយមានឆ្នេរខ្សាច់ស្អាត និងទឹកសមុទ្រថ្លាៗ កោះនេះមានថ្មប៉ប្រះទឹកផ្កាថ្ម និងជីវចម្រុះជាច្រើនរស់នៅក្រោមទឹកសមុទ្រ ប៉ុន្តែមិនធ្លាប់មានប្រជាជនស៊ីវិលរស់នៅលើកោះតាងតាំងពីមុនរហូតមកដល់បច្ចុប្បន្នៗ កោះតាង គឺជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានកងទ័ពជើងទឹក នៃប្រទេសកម្ពុជាដែលបានបោះទីតាំងការពារដែនកោះ និងដែនទឹកសមុទ្រប្រទេសកម្ពុជា ចាប់តាំងពីរបបសង្គមរាស្ត្រនិយម, របបសាធារណរដ្ឋខ្មែរ, របបកម្ពុជាប្រជាធិបតេយ្យ, របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរាជរដ្ឋាភិបាលនាពេលបច្ចុប្បន្នៗ

រហូតដល់ខែឧសភា ឆ្នាំ១៩៧៥ ក៏បានកើតមានព្រឹត្តិការណ៍ចាប់កប៉ាល់ម៉ាយ៉ាហ្គេស ពីកោះ ពូលូវ៉ៃ បញ្ជូនមកកោះតាង ដែលជាកប៉ាល់ដឹកទំនិញចំណាស់មួយរបស់ក្រុមហ៊ុនឯកជនសហរដ្ឋអាមេរិក ដែលមានចំណុះ ១០,៤៨៤តោនៗ នៅខណៈពេលដែលកប៉ាល់ម៉ាយ៉ាហ្គេស បានធ្វើដំណើរមកប្រឈមជាមួយកោះពូលូវ៉ៃ របស់ប្រទេសកម្ពុជា កងទ័ពខ្មែរក្រហមដែលឈរជើងនៅកោះពូលូវ៉ៃ គឺជាកងទ័ពដែលមិនមានជំនាញខាងជើងទឹកបន្តិចនោះ បានបើកកប៉ាល់ប្រភេទប៉េ-សេ-អេហ្វ ចំនួន២គ្រឿង និងមានកងទ័ពប្រមាណជាង១០នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃបានចេញដំណើរទៅស្ទាក់ចាប់ក៏ប៉ាល់ម៉ាយ៉ាហ្គេស ដែលស្ថិតនៅចម្ងាយប្រមាណជាង១០គីឡូម៉ែត្រ ពីកោះពូលូវ៉ៃៗ កងទ័ពខ្មែរក្រហមបានបាញ់កាំភ្លើងអឹម-៧៩ ជាសញ្ញាឲ្យកប៉ាល់ម៉ាយ៉ាហ្គេសឈប់ បន្ទាប់មកខ្មែរក្រហមបានបញ្ជាឲ្យនាវិក បើកកប៉ាល់ម៉ាយ៉ាហ្គេស ចូលមកកោះពូលូវ៉ៃជាមួយកប៉ាល់ ប៉េ-សេ-អេហ្វ របស់ខ្លួនៗ បន្ទាប់ពីចតនៅកោះពូលូវ៉ៃមួយយប់ គឺនៅថ្ងៃទី១៣ ខែឧសភាក្នុងឆ្នាំដដែល ខ្មែរក្រហមបានបញ្ជូនកប៉ាល់ ម៉ាយ៉ាហ្គេសពីកោះពូលូវ៉ៃមកកាន់កោះតាងៗ នៅខណៈពេលចាប់កប៉ាល់ម៉ាយ៉ាហ្គេសនេះ កងទ័ពខ្មែរក្រហមក៏បានរាយ-ការណ៍តាមវិទ្យុទាក់ទងទៅកាន់ទីបញ្ជាការធំនៅកំពង់សោមៗ មុនដំបូងបញ្ជាការដ្ឋាននៅកំពង់សោមបានបញ្ជាឲ្យទុកកប៉ាល់ម៉ាយ៉ាហ្គេសនៅកោះពូលូវ៉ៃមួយយប់ បន្ទាប់មកត្រូវបញ្ជូនកប៉ាល់ម៉ាយ៉ាហ្គេស និងក្រុមនាវិកមកដល់កោះតាង និងបញ្ជូនបន្តមកកំពង់សោមៗ ប៉ុន្តែនៅពេលដែលបញ្ជូនកប៉ាល់ម៉ាយ៉ាហ្គេស និងក្រុមនាវិកមកដល់កោះតាងហើយ ខ្មែរក្រហមបានឡើងទៅយាមការពារនៅលើកប៉ាល់ម៉ាយ៉ាហ្គេសបានរយៈពេលមួយយប់មួយថ្ងៃក៏មានការប្រែប្រួល គឺព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៥ ខាងទីបញ្ជាការធំនៅកំពង់សោមក៏បានប្រាប់មកទៀតថា ត្រូវឲ្យកងទ័ពខ្មែរក្រហមចុះចេញពីលើកប៉ាល់ម៉ាយ៉ាហ្គេសទាំងអស់ ហើយបញ្ជាឲ្យកងទ័ពខ្មែរក្រហមយកក្រុមនាវិកទាំងអស់ចេញពីកប៉ាល់ និងដឹកមកទុកនៅកោះរ៉ុង (កោះរ៉ុងសន្លឹម)ៗ ចំណែកកប៉ាល់ម៉ាយ៉ាហ្គេសត្រូវទុកនៅកោះតាង គឺមិនចាំបាច់បញ្ជូនមកកំពង់សោមឡើយៗ



ក្មេងៗកំពុងងូតទឹកស្ទឹង ស្ថិតនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ៗ (សុខ វណ្ណៈ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីកងទ័ពខ្មែរក្រហមចាប់កប៉ាល់ម៉ាយ៉ាហ្គេស សកម្មភាពនេះបានបង្កឲ្យមានសង្គ្រាមរវាងកងទ័ពអាមេរិក និងកងទ័ពខ្មែរក្រហមដែលបណ្តាលឲ្យកងទ័ពខ្មែរក្រហមដែលចូលរួមប្រយុទ្ធនៅកោះតាង មិនបានដឹងចំនួនដែលបានស្លាប់ និងបាត់ខ្លួនប៉ុន្មាននាក់ឡើយៗ ចំណែកឯកងទ័ពអាមេរិកក៏មិនដឹងថាបានស្លាប់ប៉ុន្មាននាក់ដែរៗ ការប្រយុទ្ធគ្នានេះកងទ័ពអាមេរិកបានបាញ់ពន្លិចកប៉ាល់ខ្ញុំមួយគ្រឿង ប៉ុន្តែគ្មានកងទ័ពណាត្រូវរបួសឡើយៗ បន្ទាប់ពីបញ្ចប់សង្គ្រាមរវាងកងទ័ពអាមេរិកជាមួយកងទ័ពខ្មែរក្រហមរួចមក ស្រាប់តែមានទាហានវៀតណាមវាយចូលកោះពូលូវ៉ៃៗ ផ្លូវនៅកោះតាងត្រូវបានដាច់ដោយកងទ័ពអាមេរិកទម្លាក់គ្រាប់បែក នាំឲ្យពិបាកក្នុងការដឹកជញ្ជូនគ្រាប់សព្វាវុធប្រឆាំងជាមួយកងទ័ពវៀតណាមៗ បញ្ហានេះបានធ្វើឲ្យកងទ័ពវៀតណាមហ៊ុំព័ទ្ធចាប់បានកងទ័ពខ្មែរក្រហមចំនួន ៦០០នាក់ ពីកោះពូលូវ៉ៃ បញ្ជូនទៅហាទៀង ប្រទេសវៀតណាមៗ ក្នុងនោះក៏មានមេបញ្ជាការធំៗផងដែរៗ នាព្រឹកព្រលឹមកងទ័ពខ្មែរក្រហមទាំង៦០០នាក់នោះ ត្រូវបានទាហានវៀតណាមតម្រៀបជាជួរ ហើយបានធ្វើទារុណកម្មដោយក្នុងម្នាក់វាយបីធាងដូងជារៀងរាល់ព្រឹកៗ ដល់ពីរ



ស្វែងរកការពិត-ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ លេខ២៤៣ ខែមីនា ឆ្នាំ២០២០

បីខែក្រោយមកទើបធូរស្រាលបន្តិចៗ កាលដែលខ្ញុំ និងកងពលរបស់ខ្ញុំឈរជើងនៅកោះតាង កងទ័ពយើងបានចាប់ទូកនេសាទថៃជាច្រើនដែលបានឆ្លងកាត់ដែនសមុទ្រយើង ហើយទូកនេសាទនីមួយៗជាប្រភេទទូកប្រាំបីរយសេះ និងមួយពាន់ពីររយសេះ ហើយមានផ្ទុកមនុស្សយ៉ាងតិច ៣០នាក់ៗ បន្ទាប់ពីចាប់ទូកនេសាទរួចមកខ្ញុំក៏មិនដឹងដែរថាទូកនេសាទទាំងនោះត្រូវបានចាប់បញ្ជូនទៅកន្លែងណាផ្សេងទៀតដែរ។ លើសពីនេះទៀត កងទ័ពយើងក៏ចាប់បានជនអន្តោប្រវេសន៍យួន និងទាហានវៀតណាម ដែលបានបន្កប់ខ្លួននៅលើទូកពីកោះពូលូវ៉ៃ ហើយក៏បានបញ្ជូនមកកោះតាង ហើយពីកោះតាងបញ្ជូនទៅកងពលផ្សេងទៀតទៅតាមដំណាក់កាលនីមួយៗ។ កងទ័ពយើងបានចាប់ជនអន្តោប្រវេសន៍យួនជាច្រើននាក់ក្នុងមួយខែៗ។

នៅអំឡុងឆ្នាំ១៩៧៧ ខ្ញុំត្រូវបានថ្នាក់លើដកចេញពីវរសេនាធំ៦២ ដោយឲ្យទៅឈរជើងហាត់ពត់លត់ដំនៅស្ទឹងហាវដើម្បីធ្វើសំណង់នាវាៗ។ កាលនោះខ្ញុំគឺជាប្រធានកងវិស្វកម្មគ្រប់គ្រងកម្លាំង៦០នាក់ដែលជាកម្លាំងជាប់គុក ឬជាប់និន្នាការ។ ដល់ក្រោយមកថ្នាក់លើបានបញ្ជូនកម្លាំងកងទ័ពបន្ថែមទៀត។ នៅអំឡុងពេលដែលខ្ញុំធ្វើសំណង់នាវា ថ្នាក់លើក៏បានប្រគល់ឡានសម្រាប់ធ្វើសំណង់ចំនួន៤០គ្រឿងផងដែរ។ ចំណែកឡានទាំង៤០គ្រឿង មានតួនាទីដឹកថ្មពីភ្នំក្បែរស្ទឹងហាវ យកទៅចាក់ធ្វើទំនប់ដើម្បីបង្ហាំងនាវាៗ។ ការធ្វើសំណង់នាវានេះក៏មានអ្នកជំនាញការចិនបួនដប់នាក់ដែរ។ នៅពេលដែលមកដល់ដំបូងកងទ័ពដែលជាប់និន្នាការម្នាក់ៗមានសក់វែង ហើយខ្ញុំក៏បានចាត់វិធានការឲ្យតម្រង់ជួរកាត់សក់ឲ្យខ្លី។ ចំណែកអាហារហូបចុកកងទ័ពទាំងនោះក៏ទទួលបានសមល្មមដែរ។ មួយរយៈក្រោយមកខ្មែរក្រហមក៏បានចេញមាគ៌ាសង្គ្រោះ និងបន្ធូរបន្ថយទោសដល់កងទ័ពទាំងនោះ។ ចំណែកសំណង់នាវាត្រូវបានសាងសង់បានត្រឹមតែ ៧០ភាគរយប៉ុណ្ណោះ។ ខ្ញុំបានធ្វើការនៅខាងសំណង់វិស្វកម្មក្នុងរយៈពេលមិនបានប៉ុន្មានខែផង ក៏សាប់តែមានកងទ័ពវៀតណាមវាយចូលស្រុកនៅឆ្នាំ១៩៧៨។

នៅឆ្នាំ១៩៧៨ កងទ័ពវៀតណាមចាប់ផ្តើមវាយរំដោះប្រទេសកម្ពុជា ពីសំណាក់ខ្មែរក្រហមនៅតាមច្រកព្រំដែន ហើយកងកម្លាំងយើងក៏ចាប់ផ្តើមបែកខ្ញែកគ្នា។ ពេលនោះខ្ញុំបានជិះកាណូត ប៉េសេអេស (PCS) ដែលជាជ័យភណ្ឌរបស់អាមេរិក ដែលកងទ័ពខ្មែរក្រហមវាយដណ្តើមបានប៉ុន្មានគ្រឿងកាលពីឆ្នាំ១៩៧៥។ ខ្ញុំបានជិះកាណូតនេះទៅវាយនៅកោះរ៉ុង ខាងត្បូងកោះក្រចកសេះ។ ពេលនោះកាណូត ប៉េសេអេស ត្រូវបានកងទ័ពវៀតណាមបាញ់ធ្លុះ។ ខ្ញុំបានព្យាយាមផ្សារប្រហោងដែលធ្លុះនោះដែរ ប៉ុន្តែមិនអាចផ្សារជាប់ឡើយ។ ក្រោយមកខ្ញុំក៏បានសម្រេចចិត្តជិះកាណូតប៉េសេអេសនោះ មកពន្លិចចោលនៅជីផាត។ បន្ទាប់ពីពន្លិចកាណូតរួចហើយ កងទ័ពយើងបានរៀបចំកងថ្មើរជើងថ្មីដែលមានចំនួនកងទ័ព៦០ទៅ ៧០នាក់ៗ តទៅទៀត ខ្ញុំ និងកងទ័ពដទៃទៀតបានធ្វើដំណើរឆ្ពោះទៅតាតៃ ស្រុកអូរសោម។ មិនយូរប៉ុន្មានខ្ញុំបានផ្លាស់ទីបន្តទៅស្ទឹងមេទឹក រហូតដល់ខ្លងយៃ ប្រទេសថៃ។ មួយរយៈក្រោយមកអាជ្ញាធរថៃបានបញ្ជូនខ្ញុំមកអូរដា ស្រុកខ្សែម ក្នុងប្រទេសកម្ពុជាវិញ។ នៅពេលដែលខ្ញុំបានមកដល់អូរដា ខ្ញុំបានសុំអង្ករ តាជៀម ១០ការ៉ុង ដោយខ្ញុំបានប្រាប់គាត់ថា កងរបស់ខ្ញុំនឹងត្រូវធ្វើដំណើរទៅខេត្តប៉ៃលិន។ តាជៀម គឺជាជនជាតិភាគតិចដែលធ្លាប់រស់នៅក្នុងកងពលជាមួយខ្ញុំដែរ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងឆ្លងកាត់បឹងខ្លា បឹងត្រកួន បឹងបេង រហូតដល់ប៉ៃលិន។ បន្ទាប់ពីមកដល់ប៉ៃលិនខ្ញុំបានស្នើសុំ អ៊ី ឈាន នៅជាមួយ។ ខ្ញុំបានប្រាប់ អ៊ី ឈាន ថា «ការពិតទៅទិសដៅរបស់ខ្ញុំត្រូវទៅ ស្រុកសំឡូតនោះទេ ប៉ុន្តែដោយសារតែមិនទាន់មានបណ្តាញត្រឹមត្រូវ ដូច្នេះខ្ញុំសុំស្នាក់នៅជាមួយបងមួយរយៈសិន»។ ខ្ញុំបានរស់នៅក្នុងស្រុកប៉ៃលិនអស់រយៈបីទៅបួនខែ ហើយកងទ័ពវៀតណាមក៏ចាប់ផ្តើមវាយចូលព្រៃធំដោយបានប្រើប្រាស់ថ្នាំពុល។ កងទ័ពវៀតណាមបានចោះប្រហោងកំប៉ុងបី នៃកំប៉ុងនីមួយៗ ដើម្បីដាក់ព្យួរនៅលើដើមឈើក្នុងការបង្កើតក្លិនក្រអូបដូចម្សៅពេទ្យដែលនាំឲ្យកងទ័ពខ្មែរក្រហមពុលក្អួតស្លាប់ចំនួន៣០០នាក់។





រហូតដល់ឆ្នាំ១៩៨០ ខ្ញុំបានផ្លាស់មកអូររថក្រោះនៅស្រុកសំឡូតជាមួយមិត្តភក្តិចាស់របស់ខ្ញុំដោយនៅក្នុងវរសេនាធំ៥២ ក្នុងកងពល១០៨ ដោយមាន តាម៉ើត ជាប្រធាន។ ខ្ញុំបានតាំងទីលំនៅក្នុងស្រុកសំឡូត រហូតដល់ឆ្នាំ១៩៩៣ ដល់ក្រោយមកខ្ញុំបានផ្លាស់មករស់នៅក្នុងឃុំស្តៅ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។ ក្នុងឆ្នាំនោះដែរខ្ញុំបានទៅចូលរួមបោះឆ្នោតអ៊ុនតាក់នៅស្រុករតនៈមណ្ឌល។ មុននឹងទៅបោះឆ្នោតខ្ញុំទទួលបានការពន្យល់អំពីសារសំខាន់នៃការបោះឆ្នោតយ៉ាងដូចម្តេច និងអាចជ្រើសរើសថ្នាក់ដឹកនាំដែលខ្លួនស្រឡាញ់ ព្រោះវាគឺជារបបសេរីគ្មានការគៀបសង្កត់អ្វីឡើយ។ រហូតដល់ឆ្នាំ១៩៩៧ ខ្ញុំត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅវាយនៅស្រុកសំឡូត។ បន្ទាប់ពីវាយរួច ហើយខ្ញុំបានឡើងយន្តហោះជាមួយ តាសាញ ឆ្ពោះទៅខេត្តបាត់ដំបងវិញ ហើយបានសម្រាកនៅផ្ទះគាត់មួយយប់។ ក្រោយមកគាត់បានចាត់តាំងខ្ញុំឲ្យទៅឈរជើងនៅស្រុករុក្ខគិរី ដែលជាស្រុកមួយទើបតែបង្កើតថ្មីនៅក្នុងខេត្តបាត់ដំបង។ កាលដែលខ្ញុំនៅស្រុករុក្ខគិរី ខ្ញុំមានតួនាទីគ្រប់គ្រងដីធ្លីរបស់សមាហរណកម្ម មិនឲ្យប្រជាជនដែលរស់នៅតំបន់ផ្សេងទៀត មកយកជាកម្មសិទ្ធិបានឡើយ។ តួនាទីរបស់ខ្ញុំនាពេលនោះ គឺស្ថិតនៅក្នុងក្របខណ្ឌយោធា។ ខ្ញុំឈរជើងនៅស្រុករុក្ខគិរី អស់រយៈពេល១៥ឆ្នាំ។ ដល់ក្រោយមកខ្ញុំបានសម្រេចចិត្តមករស់នៅក្នុងភូមិក្រពើពីរ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ រហូតមកដល់សព្វថ្ងៃ។



ផ្លូវលំនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

**រេហ៊ី ហ្វ្រាយ**

(តពីលេខមុន)



ហ៊ីម ឡឺ និងកងការពារណាហ្ស៊ី (ជាភាសារអាល្លឺម៉ង់ SCHUTZSTAFEL ឬ ហ្សូតស្តាហ្វេល) នៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ ក្នុងឆ្នាំ១៩៤១។ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អូសឈ្វិចគឺជាប៉មបាបិល ដែលអាចឮគ្រប់ភាសារបស់អឺរ៉ុប។ ប៉ុន្តែភាសាចម្បងគឺភាសាអាល្លឺម៉ង់ ហើយប្រសិនបើយើងមិនយល់ភាសានោះទេយើងនឹងជួបបញ្ហាអាក្រក់។

នេះគឺជារឿងដ៏អាក្រក់បំផុតសម្រាប់ជនជាតិអ៊ីតាលីដែលមានមនុស្សតិចតួចណាស់ អាចនិយាយភាសាអាល្លឺម៉ង់បាន។ កងការពារណាហ្ស៊ីមិនបានខ្វល់ទេថាយើងមួយចំនួនមិនយល់ពីភាសារបស់ខ្លួន និងបានចាត់ទុកថា គឺជាការមិនស្តាប់បង្គាប់នៅពេលដែលយើងមិនបានធ្វើតាមបញ្ជា។ ខ្ញុំចាំថាមានស្ត្រីជនជាតិក្រិចដែលមានរាងតូចម្នាក់មកពីកោះរូដស៍ នាងបាននិយាយអំពីការវាយដំលើរូបរាងកាយរបស់នាង នៅពេលដែលនាងស្តាប់មិនយល់ពីអ្វីដែលគេបានបញ្ជា។ អ្នកដែលមិនយល់ពីបទបញ្ជាមិនដែលមានជីវិតរស់បានយូរនោះទេ ហើយជនជាតិក្រិច និងអ៊ីតាលីភាគច្រើនត្រូវបានសម្លាប់ដោយសារមូលហេតុទាំងនេះ។





ជនជាតិជ្វីហ្វនៅអឺរ៉ុបខាងជើងមានសំណាងជាងជនជាតិដទៃទៀត។ ដោយសារតែអ្នកទាំងនោះអាចនិយាយភាសាយីដឹស និងយល់អំពីបទបញ្ជា។ ដូច្នេះហើយទើបអ្នកទាំងនោះមិនងាយធ្លាក់ខ្លួនទៅជាជនរងគ្រោះដូចជាជនជាតិអ៊ីតាលី។ ខ្ញុំក៏មានចំណេះដឹងខ្លះអំពីភាសាយីដឹសដែរ ពីព្រោះឪពុកម្តាយរបស់ខ្ញុំតែងតែនិយាយភាសានេះនៅពេលដែលពួកគាត់មិនចង់ឲ្យកូនៗស្តាប់យល់អំពីអ្វីដែលពួកគាត់និយាយ។ ជាងនេះទៅទៀត ខ្ញុំធ្លាប់បានរៀនភាសាអាល្លឺម៉ង់នៅតាមសាលារៀនរបស់ខ្ញុំ។ ដូច្នេះហើយវាធ្វើឲ្យខ្ញុំមានប្រៀបជាងអ្នកដទៃ។

នៅក្នុងជំរំអូសឈ្វិច-បឺកខិណូ មនុស្សដែលមកពីសញ្ជាតិផ្សេងពីគ្នាមិនសូវមានទំនាក់ទំនងជាមួយគ្នាទេ។ ដូច្នេះ ហើយខ្ញុំក៏មិនមានឱកាសច្រើនដើម្បីស្តាប់ភាសាដែលនិយាយខុសគ្នាៗទាំងអស់នោះដែរ។ កន្លែងតែមួយគត់ដែលយើងអាចជួបអ្នកដែលមកពីក្រុមផ្សេងគ្នាបានគឺនៅក្នុងបន្ទប់ទឹក។ នៅទីនោះ ខ្ញុំព្យាយាមបង្កើតសន្ទនាខ្លះៗជាមួយក្មេងស្រីឯទៀត។

ក្រៅពីស្ត្រីដែលជាជនជាតិក្រិចនោះ ខ្ញុំក៏បានជួបរ៉ូស ដែលជាក្មេងស្រីតូចម្នាក់មកពីប្រទេសហូឡង់។ នាងនិយាយភាសាអាល្លឺម៉ង់ ប៉ុន្តែខ្ញុំស្តាប់នាងមិនសូវយល់ទេព្រោះតែរបៀបបញ្ចេញសំឡេងរបស់នាង។ ប៉ុន្តែសំណាងល្អដែលកងការពារណាហ្ស៊ីនៅតែយល់អំពីអ្វីដែលនាងនិយាយ ហើយនាងក៏បាននិយាយប្រាប់ខ្ញុំអំពីការដែលបានតែងតាំងឲ្យធ្វើជាប្លក់កូវ៉ា ដែលបានធ្វើឲ្យនាងទទួលអត្ថប្រយោជន៍បន្ថែមដូចជា មានអាហារល្អ សម្លៀកបំពាក់ល្អ និងមានសេរីភាពច្រើនជាងមុន។

### "តើអ្វីដែលបានជួយអ្នកឱ្យរួចជីវិត?"

មនុស្សជាច្រើនអ្នកមិនដែលជឿលើឱកាសនោះទេ ប៉ុន្តែប្រសិនបើខ្ញុំត្រូវឆ្លើយសំណួរថា តើអ្វីដែលបានជួយឲ្យខ្ញុំរួចជីវិត គឺខ្ញុំបានត្រឹមតែឆ្លើយថានោះគឺមកពីឱកាស។ ប្រសិនបើគ្មានឱកាសនោះទេអ្វីៗផ្សេងទៀតក៏មិនអាចជួយបានដែរ។ នៅក្នុងជំរំគឺគ្មានហេតុនិងផលទេ។ យើងមិនអាចដឹងបានទេថាយើងគួរតែនៅកន្លែងណា ឬក៏មិនគួរនៅកន្លែងណាដើម្បីឲ្យបានរួចជីវិត។ យើងអាចនឹងត្រូវកងការពារណាហ្ស៊ីសម្លាប់សម្រាប់ការលេងសើចសប្បាយរបស់ពួកគេក៏មាន។ អំពើល្អដែលកងការពារទាំងនោះធ្វើមកលើយើងក៏អាចមានន័យថាបន្ទាប់មកគឺជាសេចក្តីស្លាប់។ ឧទាហរណ៍ វេជ្ជបណ្ឌិត ម៉េនជីលី ត្រូវបានគេស្គាល់ថាតែងតែឲ្យស្ករគ្រាប់ទៅក្មេងណាដែលគាត់នឹងយកទៅធ្វើពិសោធន៍។



ហេនរីជ ហ៊ីម ឡឺ និងកងការពារណាហ្ស៊ី (ជាភាសារអាល្លឺម៉ង់ SCHUTZSTAFEL ឬ ហ្សូតស្តាហ្វេល) នៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ ក្នុងឆ្នាំ១៩៤១។ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### «តើអ្នកអាចសម្របខ្លួនបានដោយរបៀបណា?» មានសិស្សជាច្រើនបានសួរបែបនេះមកខ្ញុំ។ «ប្រសិនបើជាខ្ញុំ ខ្ញុំអាចនឹងស្លាប់»។

អ្នកអាចគិតបែបនេះបាន ប៉ុន្តែសេចក្តីស្លាប់គឺមិនងាយស្រួលដូចអ្វីដែលនិយាយនោះទេ។ ការរស់នៅអាចពិបាក ប៉ុន្តែយើងគ្មានជម្រើសផ្សេងទៀតឡើយ យើងនឹងខិតខំត្រដររស់នៅរហូតដល់ទីបញ្ចប់នៃជីវិតរបស់យើង។

ជាច្រើនយប់ បន្ទាប់ពីធ្វើការងាររហត់នៅពេលថ្ងៃ ខ្ញុំគិតថា ខ្ញុំមិនអាចបន្តជីវិតរស់ទៅថ្ងៃមុខបានទៀតទេ។ ប៉ុន្តែនៅពេលដែលខ្ញុំភ្ញាក់ឡើង ខ្ញុំក៏ក្លាយទៅជាកូនចៀមដែលចាំស្តាប់បង្គាប់ធ្វើការកិច្ចដែលគេបានបញ្ជាដូចកាលពីម្សិលមិញម្តងទៀត ដោយក្តីសង្ឃឹមថា ដរាបណាខ្ញុំធ្វើអ្វីដែលពួកគេបានបញ្ជា។ ពួកគេនឹងមិនបាញ់សម្លាប់ខ្ញុំទេ។



រូបដើរនៅជួរខាងមុខគេ រូបទី២រាប់ពីឆ្វេង៖ ហេនរីជ ហ៊ីមឡឺ (HEINRICH HIMMLER) អំឡុងពេលធ្វើទស្សនកិច្ចជាផ្លូវការនៅក្នុងជំរំស្តុត ថូហូ ក្នុងទីក្រុងដាំស្គ័នៃប្រទេសប៉ូឡូញ។ ហ៊ីមឡឺ គឺជាសមាជិកកងការពារណាហ្ស៊ី និងជាសមាជិកឈានមុខគេនៃបក្ស។ ហ៊ីមឡឺ ក៏នៅក្នុងចំណោមអ្នកដែលមានអំណាចបំផុតនៅក្នុងបក្ស និងក្នុងចំណោមអ្នកដែលទទួលខុសត្រូវធំបំផុតចំពោះការកាប់សម្លាប់រង្គាលនៅអឺរ៉ុប។
(សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដរាបណាដែលយើងនៅមានជីវិត យើងចង់រស់បន្តទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ។ យើងជាច្រើននាក់ត្រូវបានគេធ្វើទារុណកម្ម ប៉ុន្តែនៅតែមិនបោះបង់ចោលក្តីសង្ឃឹម។ ខ្ញុំក៏សង្ឃឹមដែរថា ខ្ញុំនឹងនៅតែត្រដររស់នៅក្នុងស្ថានភាពបែបនោះ ប៉ុន្តែយើងក៏មិនអាចដឹងបានដែរថា យើងនឹងធ្វើអ្វីបន្ទាប់មកទៀតនោះទេ។

នៅអូសឈ្វិច ពេលខ្លះខ្ញុំគិតដោយក្តីអស់សង្ឃឹម «មិនអាចមានថ្ងៃមួយទៀតបានទេ ថ្ងៃស្អែកខ្ញុំនឹងលោតចូលបន្ទាលួសអគ្គិសនី» ប៉ុន្តែក៏មានគំនិតថ្មីមួយទៀតលេចឡើងថា «ការសម្លាប់ខ្លួននោះនឹងធ្វើឲ្យសមចិត្តពួកណាហ្ស៊ី ព្រោះអ្វីដែលពួកគេចង់បានគឺការកម្ចាត់យើងចោល។»

អ្វីដែលការពារខ្ញុំពីគំនិតដ៏អាប់អួទាំងនេះ គឺប្អូនស្រីរបស់ខ្ញុំ។ ភាពទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមកធ្វើឲ្យមានអត្ថន័យចំពោះជីវិតដែលគ្មានន័យរបស់យើង ប្រសិនបើប្អូនស្រីរបស់ខ្ញុំបាក់ទឹកចិត្ត ខ្ញុំជួយផ្តល់កម្លាំងចិត្តដល់នាង។ ប្រសិនបើខ្ញុំ មិនសប្បាយចិត្ត ប្អូនស្រីរបស់ខ្ញុំនិយាយកំប្លែងឲ្យខ្ញុំស្តាប់។ ប្រសិនបើយើងគ្មានគ្នាពីរនាក់ចាំជួយគ្នាទៅវិញទៅមកនោះទេ យើងប្រាកដជាមិនអាចរស់រានមានជីវិតបានឡើយ។

ភាពសាមគ្គី និងវង្សមិត្តភក្តិរបស់ខ្ញុំនៅក្នុងក្រុមក៏មានអត្ថន័យយ៉ាងខ្លាំងណាស់ដែរ។ នៅពេលល្ងាច យើងអង្គុយជុំគ្នា ដើម្បីព្យាយាមបំបាត់គំនិតមិនល្អដោយនិយាយអំពីរឿងចាស់ និងថ្មីអំពីកំណាព្យ និងរូបមន្តធ្វើម្ហូប។ យើងព្យាយាមបំបាត់ភាពស្រេកឃ្លានដោយ «ធ្វើម្ហូប» ដែលជាការពន្យល់ឲ្យបានក្បោះក្បាយអំពីរបៀបធ្វើម្ហូបរហូតទាល់តែយើងសឹងតែអាចធុំក្លិនស្តែញាត់សាច់ជ្រូកចិញ្ច្រាំ និងប្រហិត។

មានរឿងផ្សេងៗជាច្រើនទៀត ដែលមានសារសំខាន់ដល់ការរស់រានមានជីវិតរបស់យើងទាំងអស់គ្នា ដែលមកពីប្រទេស ហុងគ្រី។ អ្វីដែលសំខាន់នោះ គឺយើងមិនត្រូវបានចាប់ខ្លួនឲ្យក្លាយទៅជាអ្នកទោសរហូតដល់ឆ្នាំ១៩៤៤។ វាមានន័យថា យើងបានចំណាយពេលមិនដល់១ឆ្នាំផងនៅក្នុងជំរំ ដែលមិនដូចអ្នកដទៃទៀតដែលរងទុក្ខវេទនាអស់រយៈពេលជាច្រើនឆ្នាំ។

ការខិតខំត្រដររស់ដើម្បីប្រាប់អំពីរឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើងចំពោះយើងគ្រប់គ្នា បន្ទាប់ពីសង្គ្រាមបានរលត់ទៅ តែងតែមាននៅក្នុងផ្នត់គំនិតរបស់យើងជានិច្ច។ ប៉ុន្តែនៅពេលនោះ យើងទាំងអស់គ្នាបានសង្ស័យថា គ្មាននរណាម្នាក់ចង់ស្តាប់រឿងរ៉ាវរបស់យើងទេ។

## "តើនៅក្នុងជំរំមានសាមគ្គីភាពគ្នាដែរឬទេ?"

អ្នកប្រហែលជាគិតថា ពីព្រោះតែជោគវាសនាដែលដូចគ្នារបស់យើងនឹងអាចធ្វើឲ្យយើងចេះសាមគ្គីគ្នា។ ប៉ុន្តែការពិតអ្វីៗដែលបានកើតឡើង គឺមិនមែនជាការសាមគ្គីគ្នានោះទេ។

ជាញឹកញាប់នៅពេលដែលក្រុមការងារមួយបានបង្កើតឡើង ក្រុមតូចៗនៅក្នុងនោះក៏បានបង្កើតឡើងដែរ។ ក្មេងស្រីៗដែលមកពីប្រទេសដូចគ្នារស់នៅជាមួយគ្នាយ៉ាងជិតស្និទ្ធ ហើយក៏មានការរើសអើងគ្នាដែរ។ ក្មេងស្រីជនជាតិជ្វីហ្វ-ប៉ូឡូញ បានចាត់ទុកថាខ្លួនឯងល្អជាងជនជាតិហុងគ្រី ហើយជនជាតិ ហុងគ្រី គិតថាខ្លួនឯងខ្ពង់ខ្ពស់ជាងជនជាតិប៉ូឡូញ។ នៅក្នុងក្រុមដែលមកពីប្រទេសហុងគ្រី ក៏មានការប្រកាន់បក្សពួក ដោយសារតែអ្នកដែលមកពីទីក្រុងដូចគ្នា គឺរាប់អានតែជាមួយអ្នកដែលមកពីទីក្រុងដូចគ្នាតែប៉ុណ្ណោះ។

អ្នកដែលមកពីទីកន្លែងដូចគ្នា ឬនៅលើទូរថភ្លើងដូចគ្នា ជួយយកអាសាគ្នាទៅវិញទៅមក ដោយអស់ពីចិត្ត។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ត្រូវបានចាត់តាំងឲ្យធ្វើការងារ ដូចជា នៅក្នុងផ្ទះបាយ គឺអាចធ្វើឲ្យអ្នកទាំងនោះចែករបបអាហារច្រើនទៅមិត្តភក្តិរបស់ខ្លួន។ ក្មេងស្រីៗទាំងនោះចែករំលែកអត្ថប្រយោជន៍ ជាមួយក្រុមរបស់ខ្លួន និងតែងតែឲ្យអាទិភាពគ្នាទៅវិញទៅមក។ នៅពេលដែលទទួលរបបអាហារ គឺសំខាន់ណាស់ចំពោះការទទួលបានទឹកស៊ុបដែលដួសមកពីបាតឆ្នាំង ព្រោះនេះគឺជាផ្នែកដែលមានបន្លែ ជួនពេលខ្លះ មានកម្ទេចសាច់ទៀតផង។ យើងទាំងអស់គ្នាដែលឈរតម្រង់ជួរចាំទឹកស៊ុបសម្លឹងមើលទៅកាន់វែក ដួសដោយក្តីប្រណែន។ តើវែកដួសសម្លនោះបានទម្លាក់ចុះទៅដល់បាតឆ្នាំងដែរឬទេ? ឬក៏វែកដួសសម្លនោះ ដួសបានត្រឹមតែទឹកស៊ុបទេសម្រាប់ថ្ងៃនេះ? ប្រធានក្រុមចាត់ចែងនីមួយៗចង់បង្ហាញអំពីភាពស្មើគ្នា នៅពេលដែលចែកទឹកស៊ុប ដូច្នេះហើយទើបប្រធានក្រុម ទាំងនោះមិនងើយមើលមុខអ្នកដែលឈរតម្រង់ជួរទេ ដើម្បីបង្ហាញថាវែកដួសសម្លនឹងទម្លាក់ឲ្យទៅដល់បាតឆ្នាំងសម្រាប់អ្នករាល់គ្នាដែរ។ ប៉ុន្តែប្រធានក្រុម ទាំងនោះបានដឹងច្បាស់ថា ក្រុមរបស់ខ្លួនឈរនៅត្រង់កន្លែងណាមិនថា ជួរមុខ កណ្តាល ឬចុងក្រោយគេ។ នៅពេលដែលដល់វេនក្រុមរបស់ខ្លួន នោះវែកដួសសម្លនឹងទម្លាក់ចុះ ដល់បាតឆ្នាំង។

ការចង់មានជីវិតរស់នៅបន្ត គឺខ្លាំងក្លារហូតដល់អាចធ្វើឲ្យអ្នកខ្លះលួចនំប៉័ងពីសាច់ញាតិរបស់ខ្លួន កូនលួចពីម្តាយ រីឯបងប្អូនលួចពីគ្នាទៅវិញទៅមក។ មានអ្នកខ្លះទៀតលះបង់អាហារខ្លួនទៅឲ្យអ្នកដទៃ ប៉ុន្តែហេតុការណ៍នេះមិនសូវកើតឡើងជាញឹកញាប់នោះទេ។ នៅក្នុងក្រុមរបស់ខ្ញុំ មានមនុស្សស្រីម្នាក់ត្រូវបានគេស្គាល់ថា គឺជាមនុស្សដែលមានចិត្តកំណាញ់ និងអាត្មានិយម។ ប៉ុន្តែនាងបានប្រែទៅជាមនុស្សដែលចេះលះបង់ និងមានសណ្តានចិត្តល្អ។ នាងតែងតែជួយឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ហើយក៏លះបង់អត្ថប្រយោជន៍របស់នាងទៅអ្នកដែលមានសេចក្តីត្រូវការខ្លាំងជាង។

ការប្តឹង និងរិះគន់ដោយចំហ មិនមែនជារឿងដែលកម្រកើតមានឡើងនោះទេ។ ដើម្បីបានអត្ថប្រយោជន៍បន្ថែម គឺមានអ្នកខ្លះហ៊ានរាយការណ៍ប្រាប់ពីមិត្តភក្តិរបស់ខ្លួន។ រឿងរ៉ាវទាំងនេះ បានកើតឡើងមកលើរូបខ្ញុំផ្ទាល់។ ខ្ញុំគឺជាអ្នកដែលនៅក្នុងចំណោមមនុស្សមួយចំនួនដែលចេះភាសាអាល្លឺម៉ង់ ហើយក៏មានកម្ពស់ខ្ពស់ជាងអ្នកដទៃទៀត។ ដូច្នេះ ពេលដែលយើងទៅធ្វើការនៅ អេដេលស្តេត ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាកាប៉ូ។ នៅពេលក្លាយខ្លួនទៅជាកាប៉ូ គឺមានន័យថា យើងគឺជាដៃជើងរបស់កងការពារណាហ្ស៊ី ហើយមានតួនាទីក្នុងការមើលខុសត្រូវថា តើ




*រូបថតជនរងគ្រោះ នៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ ជនរងគ្រោះចំនួន៦០០០០០នាក់ បានបាត់បង់ជីវិតនៅក្នុងជំរំនេះ ដែលក្នុងចំណោមនោះមាន ២៨០០០នាក់ គឺជាជនជាតិជ្វីហ្វ។ ថតនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩*
*(សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

សមាជិកនៅក្នុងក្រុមបានខិតខំប្រឹងប្រែងធ្វើការងារដែរឬទេ។ ការងារនេះធ្វើឲ្យយើងទទួលបានទឹកស៊ុបបន្ថែមមួយចានទៀត។ យើងមិនអាចបដិសេធការតែងតាំងនេះបានទេ ប៉ុន្តែយើងអាចបំផ្លាញការងារនេះបាន។ បន្ទាប់ពីធ្វើដំណើរបានបន្តិច យើងបានមកដល់រោងចក្រទ្រុឌទ្រោមមួយដែលការងាររបស់យើង គឺត្រូវសម្អាតកម្ទេចថ្ម។ យើងត្រូវឈរជាជួរៗ ហើយហុចថ្មទៅម្នាក់ទៀតដើម្បីដាក់ជាគំនរឲ្យមានរបៀប។ កាតព្វកិច្ចរបស់ខ្ញុំគឺត្រូវមើលក្មេងស្រីៗទាំងនោះឲ្យធ្វើការងារឲ្យអស់ពីសមត្ថភាព ប៉ុន្តែផ្ទុយទៅវិញខ្ញុំបែរជាជួយឃ្លាំមើល និងចាំប្រាប់ក្មេងស្រីៗទាំងនោះ នៅពេលណាដែលកងការពារណាហ្ស៊ីដើរមកក្បែរ។ក្មេងស្រីៗទាំងនោះ អាចធ្វើការបានតាមសម្រួល រហូតទាល់តែខ្ញុំឲ្យសញ្ញាទើបអ្នកទាំងនោះចាប់ផ្តើមខិតខំធ្វើការងារវិញ។

ពីរថ្ងៃមិនទាន់បានរំលងផុតទៅផង ខ្ញុំក៏ត្រូវបានរាយការណ៍ដោយក្មេងស្រីជនជាតិប៉ូឡូញម្នាក់។ ចំពោះក្មេងស្រីម្នាក់នោះត្រឹមតែទឹកស៊ុបបន្ថែមមួយចានសោះ គឺអាចធ្វើឲ្យនាងហ៊ានធ្វើបែបនេះបាន។

## “តើក្នុងនាមជាស្ត្រីម្នាក់ដែលរស់នៅក្នុងជំរំមានលក្ខណៈបែបណាដែរ?”

នៅពេលដែលនិយាយអំពីទង្វើដែលបានប្រព្រឹត្តិទៅលើអ្នកទោស គឺគ្មានភាពខុសគ្នារវាងស្ត្រី និងបុរសទេ។ ស្ត្រីក៏ត្រូវបានប្រើឲ្យធ្វើការងារធ្ងន់ ហើយក៏ត្រូវបានដាក់ទោសយ៉ាងធ្ងន់ធ្ងរដូចគ្នាដែរ។ កងការពារណាហ្ស៊ីមិនបានចាត់ទុកយើងជាស្ត្រីនោះទេ គឺយើងគ្រាន់តែជាវត្ថុដែលត្រូវបានប្រើប្រាស់ឲ្យធ្វើការងារតែប៉ុណ្ណោះ។ ស្ត្រីជាពិសេស ស្ត្រីវ័យក្មេងបានព្យាយាមរក្សាភាពជា







*បន្ទប់ងូតទឹករួមរបស់អ្នកទោសនៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ ថតនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩។*
*(សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្ត្រីរបស់ខ្លួន សូម្បីតែនៅក្នុងស្ថានភាពដែលស្ទើរតែមិនអាចទ្រាំទ្របានយ៉ាងណាក៏ដោយ។ នៅពេលដែលយើងទៅដល់ជំរំពលកម្ម ហើយបានជួបអ្នកទោសសង្គ្រាមបារាំងដែលធ្វើការនៅកន្លែងជាមួយគ្នា យើងបានព្យាយាមស្វែងរកក្រែមលាបមាត់ឬម្សៅលាបមុខនៅតាមសំណង់បាក់បែក។ យើងចាប់ផ្តើមចង់តុបតែងខ្លួនសារជាថ្មីម្តងទៀត ហើយយើងចង់ធ្វើឲ្យខ្លួនយើងមានភាពទាក់ទាញចំពោះបុរសវ័យក្មេងដ៏ស្រស់សង្ហាទាំងនោះ។ រឿងរ៉ាវស្នេហាដែលបរិសុទ្ធក៏បានកើតឡើង មិនយូរប៉ុន្មានក្មេងស្រីនៅទីនោះ ក៏ចាប់ផ្តើមមានបុរស បារាំងដែលជា «របស់នាង»។

យើងត្រូវបានហាមផ្តាច់មិនឲ្យមានទំនាក់ទំនងជាមួយគ្នា ប៉ុន្តែក្នុងពេលដែលគ្មានអ្នកណាត្រួតពិនិត្យមើល បុរសបារាំងទាំងនោះនឹង «ទម្លាក់» កាដូតូចមួយនៅមុខក្មេងស្រីដែលខ្លួនចាប់អារម្មណ៍ខណៈពេលដែលនាងដើរឆ្លងកាត់ ហើយក្មេងស្រីនោះនឹង «ទម្លាក់» សំបុត្រដែលមានពាក្យអរគុណពីរ ឬបីម៉ាត់ត្រឡប់ទៅវិញ។ យើងត្រូវតែប្រុងប្រយ័ត្នថានឹងគ្មានកងការពារណាហ្ស៊ីនៅជិតនៅពេលណាដែលយើងធ្វើរឿងបែបនោះឡើង ពីព្រោះទង្វើបែបនេះនឹងត្រូវបានដាក់ទោសយ៉ាងធ្ងន់ធ្ងរ។ ការដាក់ទោសយ៉ាងធ្ងន់ធ្ងរក៏អាចអនុវត្តនៅពេលណាដែលបុរស និងនារីត្រូវចាប់បានថានៅជាមួយគ្នាដែរ។ ប៉ុន្តែតាមអ្វីដែលខ្ញុំចាំបានហេតុការណ៍ទាំងនេះ គឺមិនបានកើតឡើងនៅជំរំដែលខ្ញុំរស់នៅទេ។ ដោយឡែកហេតុការណ៍ទាំងនេះបានកើតឡើងនៅអូសឈ្វិច។

នៅអូសឈ្វិច យើងរស់នៅក្នុងជំរំធំ ដែលមានមនុស្សចំនួន ៥០០នាក់។ យើងត្រូវបានត្រួតត្រាដោយមេក្រុមម្នាក់ឈ្មោះថា អ៊ីតកា ដែលជាក្មេងស្រីជនជាតិប៉ូឡូញម្នាក់។ នាងមានជំនួយការដែលត្រូវជាប្អូនស្រីរបស់នាងមានឈ្មោះថា អេលសា។ ក្មេងស្រីទាំងពីរនាក់នេះមកពីប្រទេសប៉ូឡូញ ហើយបានរស់នៅក្នុងអូសឈ្វិចអស់រយៈពេលពីរឆ្នាំមកហើយ។ ពួកគេទាំងពីរ គឺមាន

មុខមាត់ស្រស់ស្អាតណាស់ និងមានរបបអាហារបរិភោគគ្រប់គ្រាន់ៗ អ្នកទាំងពីរក៏ត្រូវបានអនុញ្ញាតឲ្យរក្សាសក់ដ៏ស្រស់ស្អាតរបស់ខ្លួន ថែមទាំងមានសម្លៀកបំពាក់ធម្មតា និងទទួលបានរបបអាហារច្រើនជាងអ្នកដទៃ។ មានថ្ងៃមួយ យើងមិនឃើញ អេលសាទេ ហើយនៅពេលដែលនាងបង្ហាញខ្លួន សក់ក្បាលរបស់នាងត្រូវបានកោរ ហើយភ្នែកនាងហើមស្តីង។ យើងឆ្ងល់ ថាតើមានរឿងអ្វីបានកើតឡើងចំពោះនាង។ ក្រោយមកនាងក៏បានប្រាប់យើងទាំងអស់គ្នាអំពីដំណាលរឿងថា មានបុរសម្នាក់ដែលធ្វើការងារនៅក្នុងឈាបនដ្ឋានបានទៅរកនាងដោយសម្ងាត់ ហើយប្រគល់ឲ្យនាងនូវវត្ថុចាំបាច់មួយចំនួន។ ជាធម្មតា អារម្មណ៍ផ្លូវភេទក៏បានកើតឡើងរវាងអ្នកទាំងពីរ។ អេលសា បានធ្លាក់ក្នុងអន្លង់ស្នេហ៍បុរសម្នាក់នោះ។ ខ្ញុំមិនបានដឹងទេថា រឿងរ៉ាវបានបន្តរហូតដល់ពេលណា ប៉ុន្តែ ថ្ងៃមួយគូស្នេហ៍មួយគូនេះ ត្រូវចាប់បានដោយកងការពារណាហ្ស៊ី។ អេលសា ត្រូវបានកងការពារណាហ្ស៊ីវាយដំ និងកោរសក់ក្បាល ហើយអត្ថប្រយោជន៍បន្ថែមរបស់នាងក៏ត្រូវបានដកហូត។ បុរសម្នាក់នោះ ត្រូវបានគេវាយ និងទំនងជាមិនអាចនឹងរួចផុតជីវិតនោះទេ។

## “តើយ៉ាងដូចម្តេចទៅនៅពេលដែលអ្នកមានរដូវ?”

ស្ត្រីៗបានយកសំឡីអនាម័យទៅតាមខ្លួននៅពេលចេញដំណើរ ដោយមិនបានសង្ស័យថា នឹងមិនត្រូវបានអនុញ្ញាតឲ្យយកអីវ៉ាន់ ឬក៏សំឡីអនាម័យទាំងនោះតាមខ្លួនទេ។ ប៉ុន្តែជាក់ស្តែងសំឡីទាំងនោះគ្មានប្រយោជន៍អ្វីសម្រាប់យើងទេ។ ខ្ញុំមានរដូវបានប្រហែលជាមួយឬពីរដងប៉ុណ្ណោះ ហើយក្នុងពេលនោះគឺពិតជាលំបាកខ្លាំងណាស់។ គ្មានអ្វីដែលអាចទប់ឈាមរបស់យើងបាននោះទេ។ ប្រសិនបើយើងសំណាងល្អ ក្មេងស្រីដែលជាមេក្រុមរបស់យើងអាចនឹងឲ្យក្រណាត់កន្ទបមកខ្លះ។ ពេលខ្លះយើងប្រថុយប្រថាននឹងការដាក់ទោស ដោយហែកសម្លៀកបំពាក់ដែលនៅនឹងខ្លួនយកទៅប្រើប្រាស់ ប៉ុន្តែជារឿយៗ យើងត្រូវដើរទៅណាមកណាដោយមានឈាមប្រឡាក់ ឬមានឈាមហូរតាមជើង។ នៅពេលនោះ គឺសំខាន់ណាស់ដែលយើងមិនដើរជួបជាមួយកងការពារណាហ្ស៊ី បើមិនដូច្នេះពួកគេនឹងជេរប្រទេចយើងថា DRECKIGE JUDESAU (ជ្រិចហ្គីគី យូដេសោ) ដែលមានន័យថា ជ្រូកជ្វីហ្វមោកគ្រោក ដែលមិនចេះថែរក្សាអនាម័យខ្លួនឯង ហើយក៏វាយយើងរហូតដល់ជាំពេញខ្លួន។ នៅថ្ងៃមួយ មិត្តភក្តិរបស់ខ្ញុំឈ្មោះ ដូរ៉ាបានកត់សម្គាល់ថា នាងគួរតែមានរដូវតាំងពីបីថ្ងៃមុនមកម្ល៉េះ។ នាងគិតថា វាពិតជាចម្លែកណាស់ ព្រោះនាងមិនដែលបាន នៅជាមួយបុរសណាម្នាក់នោះទេ។ បន្ទាប់មកគ្នាយើងជាច្រើននាក់ទៀតក៏ចាប់ផ្តើមជួបរឿងបែបនេះដែរ។ មានមនុស្សស្រីតែប៉ុន្មាននាក់ប៉ុណ្ណោះ ដែលមានរដូវបន្ទាប់ពីមកដល់ជំរំប្រមូលផ្តុំបានប៉ុន្មានសប្តាហ៍។ ក្មេងស្រីមួយចំនួនគិតថាខ្លួនមានផ្ទៃពោះប៉ុន្តែ បន្តិចក្រោយមកទើបយើងដឹងថាវ៉ាមិនមែនជាសញ្ញាដែលមាន ផ្ទៃពោះនោះទេ។ ការមានរដូវ គឺបានឈប់ដោយឯកឯង។

មានពាក្យចចាមអារ៉ាមថា នេះ គឺដោយសារតែសារធាតុប្រូមីនដែលមាននៅក្នុងនំប៉័ង ប៉ុន្តែរឿងនេះមិនត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់នោះទេ។ វាគឺជាការពិតដែលរដូវអាចឈប់ដោយសារតែរបបអាហារមិនល្អដូចគ្នាទៅ នឹងអ្នកដែលមានជំងឺធុញនឹងអាហារ ប៉ុន្តែមូលហេតុនេះមិនអាចយកមកពន្យល់នៅក្នុងករណីរបស់យើងបានទេ។ យើងប្រាកដជា ត្រូវបានឲ្យអ្វីដែលអាចប៉ះពាល់ដល់អរម៉ូនរបស់យើងជាក់ជាមិនខាន។

យើងទាំងអស់គ្នាខ្លាចថារដូវនឹងមិនមកម្តងទៀតទេ ហើយនៅពេលអនាគត យើងនឹងមិនអាចមានកូនបានទេ។ ប៉ុន្តែសំណាងល្អដែលរឿងនេះមិនបានកើតឡើង។ រដូវបានមកទៀងទាត់វិញនៅពេលដែលយើងទទួលបានរបបអាហារគ្រប់គ្រាន់។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់មានស្ត្រីមួយចំនួនសម្រេចចិត្តមិនយកកូន ពីព្រោះភាពភ័យខ្លាចរបស់អ្នកទាំងនោះដែលបានគិតថាអ្វីៗ គ្រប់យ៉ាងដែលខ្លួនបានឆ្លងកាត់អាចនឹងកើតមានឡើងម្តងទៀត។ ប៉ុន្តែបន្ទាប់មក នៅពេលដែលស្ត្រីទាំងនោះមានវ័យចំណាស់ទៅពួកគេបានសោកស្តាយ ដែលមិនមានក្រុមគ្រួសារសម្រាប់ខ្លួនឯង។ អ្នកទាំងនោះមានអារម្មណ៍ឯកោយ៉ាងខ្លាំង។





## “តើអ្នកត្រូវបានចាប់រំលោភដែរឬទេ?”

អំពើរំលោភសេពសន្ថវៈ តែងតែត្រូវបានប្រើជាវិធីសាស្ត្រមួយសម្រាប់ភាគីម្ខាងក្នុងការបំពានលើ “ទ្រព្យសម្បត្តិ” របស់ភាគីម្ខាងទៀត ដែលក្នុងករណីនេះគឺសំដៅទៅលើមនុស្សស្រី។ នៅអាល្លឺម៉ង់ ហេតុការណ៍នេះ មិនបានកើតឡើងទេ។ សម្រាប់ពួក ណាហ្ស៊ី រំលោភសេពសន្ថវៈ ត្រូវបានដាក់ចូលក្នុងគោលការណ៍ហាមឃាត់ពីព្រោះទំនាក់ទំនងរវាងជាតិសាសន៍ខុសគ្នា គឺត្រូវបានហាមឃាត់ដោយច្បាប់។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង គឺមានភាពខុសគ្នាទាំងស្រុង។ សំណាងល្អដែលគ្មាននរណាម្នាក់នៅក្នុងក្រុមរបស់ខ្ញុំត្រូវបានគេចាប់រំលោភ ហើយអស់រយៈពេលជាយូរ ខ្ញុំមិនបានដឹងថារឿងនេះបានកើតឡើងនៅក្នុងជំរំផ្សេងទៀតនោះទេ។ ខ្ញុំបានដឹងអំពីរឿងនេះបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ។ ខ្ញុំបានជួបនារីម្នាក់ដែលបានប្រាប់រឿងរ៉ាវអាក្រក់ទាំងនេះមកខ្ញុំ។ ដើម្បីការពារសីលធម៌ក្នុងចំណោមទាហានណាហ្ស៊ី ផ្ទះបនត្រូវបានបង្កើតឡើងដែលមានដូចជាផ្ទះបនសម្រាប់មន្ត្រីជាន់ខ្ពស់ និងផ្ទះបនសម្រាប់នាយទាហាន។ ក្មេងស្រីជនជាតិជ្វីហ្វត្រូវបានបញ្ជូនទៅទីនោះ ហើយប្រសិនបើយើងចង់មានជីវិតរស់ យើងត្រូវតែស្តាប់បញ្ជា។ បន្ទាប់ពីធ្វើការងារដែលលំបាកអស់រយៈពេលពេញមួយថ្ងៃ ក្មេងស្រីដែលមានរូបរាងស្រស់ស្អាតត្រូវបានគេមកយកទៅផ្ទះបននៅពេលល្ងាច ហើយនឹងបញ្ជូនត្រឡប់មកធ្វើការវិញនៅពេលព្រឹក។

ឯអ្នកខ្លះទៀតត្រូវចាំបម្រើនៅទីនោះគ្រប់ពេលវេលា។ ក្មេងស្រីទាំងនោះមិនអាចមានជីវិតរស់នៅបានយូរនោះទេ។ ប៉ុន្តែមានក្មេងស្រីដែលមានសំណាងល្អមួយចំនួនបានធ្វើឲ្យទាហានអាល្លឺម៉ង់ធ្លាក់ក្នុងអន្លង់ស្នេហ៍ ហើយក្មេងស្រីនោះនឹងរស់នៅក្នុងជីវិតដែលសមរម្យជាមួយទាហានរបស់នាង។ ជាពិសេស ប្រសិនបើទាហាននោះមានតំណែងខ្ពស់នៅក្នុងជំរំ។

កងការពារ ណាហ្ស៊ី ដែលមានតំណែងខ្ពស់អាចជ្រើសរើសក្មេងស្រីដើម្បីគ្រប់គ្រងកិច្ចការផ្ទះរបស់ខ្លួនបានហើយនាងនឹងត្រូវបានលើកលែងមិនឲ្យធ្វើការងារធ្ងន់នៅខាងក្រៅផ្ទះឡើយ។ ប៉ុន្តែទោះបីជានៅក្នុងលក្ខខណ្ឌនោះក៏ដោយក៏មិនអាចធានាបានដែរថាក្មេងស្រីនោះនឹងអាចរួចជីវិតនៅក្នុងពិភពលោក ដែលមិនច្បាស់លាស់ និងខ្វះវិចារណញ្ញាណរបស់ពួកណាហ្ស៊ីនោះទេ។



បន្ទប់ផ្សែងពុល នៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្គ៍ នៃប្រទេសប៉ូឡូញ។ ថតនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩។ (សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

(តនៅលេខក្រោយ)

# មុខរបរដំដែកនៅស្រុកអន្លង់វែង

## ស្គួត វិចិត្រ



ម៉ាត់ និងកូនជាង ដែលត្រូវជាសាច់ញាតិ កំពុងដំដែកធ្វើកាំបិត នៅរោងសិប្បកម្ម ស្ថិតនៅក្នុងភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ស្គួត វិចិត្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មុខរបរដំដែក គឺជាមុខរបរដ៏ពេញនិយមមួយរបស់បងប្អូនខ្មែរអ៊ីស្លាម នៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ បងប្អូនខ្មែរអ៊ីស្លាមកំពុងប្រកបរបរនេះចំនួន ៤កន្លែង នៅក្នុងស្រុកអន្លង់វែង។

ឡោះ សា អាយុ៦២ឆ្នាំ រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បាននិយាយថា៖ «មុខរបរដំដែក គឺជាមុខរបរមួយក្នុងចំណោមមុខរបរជាច្រើនដែលផ្សារភ្ជាប់ទៅនឹងសាសនា និងទំនៀមទម្លាប់របស់បងប្អូនខ្មែរអ៊ីស្លាម។ ខ្ញុំបានប្រកបមុខរបរនេះដំបូងជាមួយឪពុករបស់ខ្ញុំ នៅឯខេត្តកំពង់ចាម ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។ នៅក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ការងាររដំដែករបស់ខ្ញុំត្រូវបានផ្អាក។ នៅឆ្នាំ១៩៧៩ ខ្ញុំចាប់ផ្តើមការងារនេះឡើងវិញ។

ចាប់តាំងពីឆ្នាំ២០០៣ ខ្ញុំបានមករស់ក្នុងស្រុកអន្លង់វែងជាមួយប្រពន្ធ និងកូនៗរបស់ខ្ញុំ។ ខ្ញុំគិតថា មុខរបរដំដែកស្ទើតែហួសសម័យទៅហើយសម្រាប់







ទ្រនាប់ដែក និងឡសម្រាប់ដុតដែក ធ្វើកាំបិត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ។ (ស្គួត វិចិត្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ដែកចាស់ៗនៅរោងសិប្បកម្មរបស់ អ៊ីត ដែលត្រូវបានប្រមូលទុកសម្រាប់ផលិតកាំបិត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ។ (ស្គួត វិចិត្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពេលបច្ចុប្បន្ននេះ។ ប៉ុន្តែ ដោយសារបងប្អូនខ្មែរអ៊ីស្លាមជាទូទៅត្រូវប្រកាន់ខ្ជាប់ខ្ជួនទៅនឹងសាសនា ខ្ញុំក៏ដូចជាបងប្អូនខ្មែរអ៊ីស្លាមដទៃទៀតដែរ តែងតែជ្រើសយកមុខរបរណាដែលនៅជិតផ្ទះ ដើម្បីងាយស្រួលក្នុងការគោរពប្រណិប័តជំនឿសាសនារបស់ខ្លួនយ៉ាងពេញលេញ។ ខ្ញុំនឹងបន្តមុខរបរដំដែកនេះ»។

អ៊ិត អាយុ៦០ឆ្នាំ ដែលបានមករស់នៅក្នុងស្រុកអន្លង់វែង ចាប់តាំងពីឆ្នាំ១៩៩៨មកម្ល៉េះ បាននិយាយថា៖ «ខ្ញុំបានមកដល់ទីនេះដំបូង អន្លង់វែង គឺជាតំបន់ព្រៃ។ មុខរបរដំដែកនេះធ្វើឲ្យខ្ញុំមមាញឹកខ្លាំងណាស់ នាពេលនោះ។ ខ្ញុំស្ទើរតែគ្មានពេលសម្រាក ពីព្រោះអតីតខ្មែរក្រហមភាគច្រើនត្រូវការកាំបិត ពូថៅ ដើម្បីកាប់ឆ្ការព្រៃ។ នៅពេលនោះ មុខរបរដំដែកផ្តល់ភាពកក់ក្តៅខ្លាំង ដែលអាចធ្វើឲ្យខ្ញុំមានលទ្ធភាពចិញ្ចឹមប្រពន្ធ និងកូនៗរបស់ខ្ញុំចំនួនប្រាំនាក់យ៉ាងសុខដុមរមនា។ អតីតខ្មែរក្រហមភាគច្រើនចូលចិត្តរាប់អានខ្ញុំណាស់ ដោយមិនគិតពីជាតិសាសន៍ ឬសាសនាឡើយ»។

# យិន នាន ចែករំលែកបទពិសោធន៍

## ឆ្លងកាត់របបខ្មែរក្រហម និងបទពិសោធន៍ការងារស្តីពីការចងក្រងឯកសារខ្មែរក្រហម

**ស៊ាង ចិន្តា**

នៅរសៀលថ្ងៃអង្គារ ទី១០ ខែមីនា ឆ្នាំ២០២០ អ្នកស្រាវជ្រាវវ័យក្មេងចំនួន៥០នាក់ បានចូលរួមវេទិកាពិភាក្សាពីកិច្ចការស្រាវជ្រាវលើប្រធានបទស្តីពី«ជីវភាពរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ វេទិកានេះ ត្រូវបានរៀបចំឡើងដើម្បីបង្កើនការយល់ដឹងបន្ថែមពីបទពិសោធន៍របស់ជនរងគ្រោះដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ លោក យិន នានជាអ្នកជំនាញផ្នែកឯកសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហម បានចែករំលែករឿងរ៉ាវជីវិតផ្ទាល់ខ្លួនឆ្លងកាត់របបខ្មែរក្រហម និងបទពិសោធន៍ការងារជាច្រើនឆ្នាំទាក់ទងនឹងការចងក្រងនិងថែរក្សាឯកសារខ្មែរក្រហម ដើម្បីការយល់ដឹង និងការចងចាំជាសាកលពីប្រវត្តិសាស្ត្រនេះ។ ទាក់ទងនឹងជីវិតឆ្លងកាត់របបខ្មែរក្រហម លោក យិន នាន បានរៀបរាប់ទៅកាន់អ្នកស្រាវជ្រាវវ័យក្មេងទាំងអស់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលខ្មែរក្រហមចូលកាន់កាប់ភូមិកំណើតរបស់គាត់ដំបូង និងព្រឹត្តិការណ៍ជម្លៀសប្រជាជនដោយបង្ខំទ្រង់ទ្រាយធំពីភូមិភាគបូព៌ាទៅកាន់ភាគខាងលិចប្រទេស ព្រមទាំងជីវិតតស៊ូឆ្លងកាត់ការលំបាកនានាពេញមួយរបបខ្មែរក្រហម។ ការរៀបរាប់ទាំងអម្បាលមាណនេះ គឺជាការចងចាំដែលពុំអាចបំភ្លេចបាន និងជាមេរៀនដ៏មានសារសំខាន់បំផុតសម្រាប់ផ្តល់នូវចំណេះដឹងបន្ថែមទៀតដល់អ្នកស្រាវជ្រាវទាំងអស់ ក្នុងការកសាងមូលដ្ឋានគ្រឹះនៃការសិក្សាស្រាវជ្រាវ



យិន នាន បង្ហាញឯកសារនៅក្នុងរបបខ្មែរក្រហមដល់ក្រុមនិស្សិតផ្នែកប្រវត្តិសាស្ត្រមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់ខ្លួននាពេលអនាគត។ ជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អ្នកស្រាវជ្រាវវ័យក្មេងទាំងឡាយ លោក យិន នានបានបង្ហាញ និងផ្តល់ឯកសារខ្មែរក្រហមជាច្រើនទំព័រសម្រាប់អ្នកទាំងនោះ យកធ្វើជាឯកសារយោងដ៏មានខ្លឹមសារ សម្រាប់ដាក់ក្នុងសំណេរស្រាវជ្រាវដែលប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។ បន្ទាប់ពីការធ្វើបទបង្ហាញបានបញ្ចប់ អ្នកស្រាវជ្រាវទាំងឡាយបានសួរសំណួរប្រកបទៅដោយការត្រិះរិះពិចារណាស៊ីជម្រៅមួយចំនួន ផ្តោតលើមូលហេតុជាច្រើនដែលបណ្តាលឲ្យមានព្រឹត្តិការណ៍ខក្រិដ្ឋនានាកើតឡើងក្នុងរបបខ្មែរក្រហម ដូចជា៖

១) ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនភូមិភាគបូព៌ា?

២) តើនរណាជាអ្នកជម្លៀសប្រជាជនភូមិភាគបូព៌ា? ៣) តើលោកអ៊ំខ្លាចសង្គ្រាមដែរឬទេ?

៤) ហេតុអ្វីបានខ្មែរក្រហមលុបបំបាត់សាសនា?

៥) ហេតុអ្វីបានជា(ប្រជាជន)មានការអត់ឃ្លានក្នុងរបបខ្មែរក្រហម?



និស្សិតផ្នែកប្រវត្តិសាស្ត្រមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញកំពុងស្តាប់ យិន នាន ធ្វើបទបង្ហាញអំពីវិធីសាស្ត្រស្វែងរកឯកសារខ្មែរក្រហម និងរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



យិន នាន កំពុងរៀបរាប់ពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម និងបទពិសោធន៍ការងារស្តីពីការចងក្រងឯកសារខ្មែរក្រហម ប្រាប់ក្រុមនិស្សិតផ្នែកប្រវត្តិសាស្ត្រមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឡុង អួន ចែករំលែកបទពិសោធន៍
## ឆ្លងកាត់របបខ្មែរក្រហម និងជីវិតជាក្មេងកំព្រា

*ស៊ាង ចិន្តា*



ឡុង អួន បង្ហាញឯកសារកំណត់ហេតុអង្គប្រជុំនៅក្នុងរបបខ្មែរក្រហមដល់ក្រុមនិស្សិតផ្នែកប្រវត្តិសាស្រ្តមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលកំពុងស្រាវជ្រាវលើប្រធានបទទាក់ទងនឹងរបបខ្មែរក្រហម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

"បន្ទាប់ពីខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំ ខ្ញុំក្លាយទៅជាក្មេងកំព្រា" គឺជាពាក្យលើកឡើងដំបូងរបស់គាត់ទៅកាន់និស្សិតមួយក្រុមក្នុងវេទិកាស្រាវជ្រាវមួយ។ ជាអ្នកនៅរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ឡុង អួនបានរៀបរាប់ពីពេលវេលាដ៏លំបាកបំផុតនៅពេលដែលខ្មែរក្រហមបានយកឪពុករបស់គាត់ទៅសម្លាប់ នៅពេលដែលគាត់បានខិតខំព្យាយាមបន្តជីវិតរស់នៅក្នុងរបបខ្មែរក្រហម និងនៅពេលដែលគាត់ចាប់ផ្តើមកសាងជីវិតថ្មីឡើងវិញ។

"ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ នៅចុងឆ្នាំ១៩៧៣។ នេះ គឺជាពេលវេលាដ៏លំបាកសម្រាប់ខ្ញុំ។ នៅពេលខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ទៅកាន់ខេត្តព្រៃវែង ដែលជាភូមិកំណើតរបស់ឪពុកខ្ញុំ។ ខ្ញុំ និងគ្រួសារ បានធ្វើដំណើរថ្មើរជើងអស់រយៈពេលជិត ២ ខែ ទៅកាន់ភូមិកាលី ឃុំស្តី ស្រុកបាភ្នំ ខេត្តព្រៃវែង"។

នៅពេលទៅដល់ទិសដៅ គាត់ត្រូវបានខ្មែរក្រហមដាក់នៅក្នុងកងកុមារ បែកចេញពី ឪពុកនិងបងប្អូនរបស់គាត់។ នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ឪពុករបស់គាត់យកទៅសម្លាប់។ គាត់បានបញ្ជាក់ថា "បន្ទាប់ពីដឹងថាខ្មែរក្រហមបានចាប់ឪពុកខ្ញុំយកទៅសម្លាប់ ខ្ញុំមានអារម្មណ៍ថាគ្មានសេសសល់អ្វីទៀតឡើយនៅក្នុងជីវិត។"

នៅក្នុងកងកុមារ ខ្មែរក្រហមបានឲ្យគាត់ធ្វើការងារដូចជា ប្រមូលអាចម៍គោ និងធ្វើជីអាចម៍គោជាដើម។ ជីវិតកុមារភាពក្នុងរបបខ្មែរក្រហម ពោរពេញទៅដោយភាពបែកបាក់ពីក្រុមគ្រួសារ សេចក្តីអស់សង្ឃឹម និងភាពអត់ឃ្លានអស់រយៈពេលជាច្រើនឆ្នាំ។ នៅពេលដែល



ស្វែងរកការពិត-ផ្នែកប្រវត្តិសាស្រ្ត និងការស្រាវជ្រាវ លេខ២៤៣ ខែមីនា ឆ្នាំ២០២០



ឡុង អួន កំពុងធ្វើបទបង្ហាញដល់ក្រុមនិស្សិតផ្នែកប្រវត្តិសាស្រ្តមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អំពីវិធីសាស្រ្តរកឯកសារក្នុងរបបខ្មែរក្រហមដែលរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ឡុង អួន កំពុងធ្វើបទបង្ហាញដល់ក្រុមនិស្សិតផ្នែកប្រវត្តិសាស្រ្តមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អំពីវិធីសាស្រ្តរកឯកសារក្នុងរបបខ្មែរក្រហមដែលរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

របបខ្មែរក្រហមបានដួលរលំនៅដើមឆ្នាំ១៩៧៩ កុមារា ឡុង អួន រួមជាមួយកុមារជាច្រើនទៀតដែលបានបាត់បង់ឪពុកម្តាយចាប់ផ្តើមជីវិតថ្មីនៅក្នុងមណ្ឌលកុមារកំព្រាកុលាប២។

ជាចុងក្រោយ គាត់បានផ្តាំនិស្សិតទាំងអស់ថា៖ "នេះគឺជារឿងរ៉ាវជីវិត ដែលមិនអាចបំភ្លេចបានរបស់ខ្ញុំក្នុងរបបខ្មែរក្រហម ហើយអ្នកទាំងអស់គ្នាត្រូវតែបន្តស្វែងយល់បន្ថែមទៀតពីប្រវត្តិសាស្រ្តខ្មែរក្រហម"។











# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!















# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

*(តពីលេខមុន)*



*នួន ជា កំពុងអានសុន្ទរកថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

**២.៤.៦.៦.** *សិទ្ធិរបស់មេធាវីការពារក្តី នួន ជា ក្នុងការតទល់នឹងភស្តុតាង និងរៀបចំការពារក្តី*

**៩៣.** មេធាវីការពារក្តី នួន ជា សន្និដ្ឋាននៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលមិនពន្យារកាលបរិច្ឆេទកំណត់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល រហូតដល់ក្រោយពេលបញ្ចប់ការផ្សារកែតម្រូវប្រតិចារឹក បានប៉ះពាល់ទៅលើសិទ្ធិរបស់ នួន ជា ក្នុងការដេញដោលតទល់ជាមួយនឹងភស្តុតាង និងការរៀបចំការពារក្តីរបស់គាត់ប្រកបដោយប្រសិទ្ធភាព។ មេធាវីការពារក្តីសន្និដ្ឋានថា នៅក្នុងអំឡុងពេលសវនាការ និងក្នុងអំឡុងពេលរៀបចំសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងដំណាក់កាលដំបូង មេធាវីការពារក្តីទំនងជាមិនបានដឹងអំពីកង្វះចន្លោះនៅក្នុងការបកប្រែផ្ទាល់មាត់ជាភាសាអង់គ្លេសនោះទេ ហើយដោយសារមានការកែតម្រូវប្រតិចារិកច្រើនដងខ្លួនពុំអាចដឹងថា នៅពេលណាប្រតិចារឹកត្រូវបានកែតម្រូវរួចរាល់ចុងក្រោយនោះទេ ដែលនេះជាការដកហូតឱកាសពី នួន ជា ក្នុងការដាក់សារណាបឋមរបស់គាត់ដោយមានលទ្ធភាពពិនិត្យមើលភស្តុតាងទាំងអស់។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ខ្លួនត្រូវបានកត់សម្គាល់ថា ខ្លួនមានបំណងដាក់សំណៅកំណែសារណារបស់ខ្លួន ហើយអាចស្នើសុំបើកសវនាការឡើងវិញក្រោយពេលប្រតិចារឹកទាំងអស់ត្រូវបានពិនិត្យចប់សព្វគ្រប់។ មេធាវីការពារ

ក្ដីកត់សម្គាល់ឃើញថា ខ្លួនត្រូវបានបង្ខំឲ្យធ្វើការងាររបស់ខ្លួនបន្ថែមប៉ុន្មានខែក្នុងការរៀបចំ និងដាក់កំណែសារណារបស់ខ្លួន។

៩៤. អង្គជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍នេះរបស់មេធាវីការពារក្ដីសមហេតុផលនោះទេ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងអំឡុងពេលជំនុំជម្រះ មេធាវីការពារក្ដីបានបង្ហាញជំហរមួយផ្សេង ដោយបានជំទាស់គ្រប់ពេលទៅនឹងការពន្យារកាលបរិច្ឆេទកំណត់នៃការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ សំណើសុំដែលមេធាវីការពារក្ដី នួន ជា បានធ្វើឡើងពាក់ព័ន្ធនឹងការពិនិត្យប្រតិចារឹកឡើងវិញ ត្រូវបានអង្គជំនុំជម្រះយល់ស្របតាម។ ជាពិសេសមេធាវីការពារក្ដីត្រូវបានផ្ដល់ឱកាសឲ្យដាក់កំណែសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល នៅក្រោយពេលបញ្ចប់ការងារកែតម្រូវប្រតិចារឹក និងការដាក់ការជំទាស់មានកម្រិតទៅនឹងកំណែសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីផ្សេងទៀតនៅក្នុងដំណាក់កាលចុងក្រោយ។ សំណើសុំព័ត៌មានបន្ថែមទៀតអំពីស្ថានភាពនៃកំណែតម្រូវប្រតិចារឹកត្រូវបានអង្គភាពប្រតិចារឹកអនុវត្តតាម។ម្យ៉ាងវិញទៀតអង្គជំនុំជម្រះបានបញ្ជូនសំណើរបស់មេធាវីការពារក្ដី ដែលសុំធនធានបន្ថែមទៅឲ្យការិយាល័យរដ្ឋបាល ការិយាល័យក៏បានយល់ព្រមតាមសំណើនេះ។ អង្គជំនុំជម្រះឃើញថាវិធានការទាំងនេះបានការពារយ៉ាងសមស្របដល់លទ្ធភាពរបស់ នួន ជា ក្នុងការពិនិត្យភ័ស្តុតាង និងការរៀបចំការពារក្ដីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

៩៥. អង្គជំនុំជម្រះបានដឹងអំពីការលំបាកដោយសារកំណែប្រតិចារឹកនៅក្នុងអំឡុងពេលរៀបចំសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងរៀបចំសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល និងរៀបចំសេចក្ដីសន្និដ្ឋានដាក់បញ្ចប់កិច្ចពិភាក្សាដេញដោល។ ទោះបីជាយ៉ាងណាអង្គជំនុំជម្រះសូមរំឭកថាភាគីទាំងអស់មានបុគ្គលិកដែលមានសមត្ថភាពភាសា អាចអានប្រតិចារឹកជាភាសាដើមរបស់ភាគីដែលបានឡើងថ្លែងការណ៍បាន។ ប្រតិចារឹកនៃភាសាដើមបង្ហាញពាក្យពេចន៍ដើម ដែលបានលើកឡើងនៅក្នុងតុលាការនឹងមិនប៉ះពាល់ដោយសារតែកំហុសនៃការបកប្រែផ្ទាល់មាត់នោះទេ។ ក្នុងករណីមានបញ្ហាចោទណាមួយទាក់ទងនឹងភាពត្រឹមត្រូវនៃប្រតិចារឹក អង្គជំនុំជម្រះក៏បានសំអាងទៅលើប្រតិចារឹកភាសាដើមផងដែរ។ ទោះបីជាអាចចំណាយពេលច្រើនជាងមុនក្ដី ក៏អង្គជំនុំជម្រះយល់ថា ការដែលមានប្រតិចារឹកជាភាសាដើម និងខ្សែអាត់សំឡេង/រូបភាព រួមជាមួយនឹងសមត្ថភាពក្រុមនីមួយៗលើភាសាផ្លូវការរបស់ អ.វ.ត.ក. នោះវាអាចជួយដោះស្រាយបញ្ហានៃការជំនុំជម្រះប្រកបដោយយុត្តិធម៌លើបញ្ហានេះបាន។

៩៦. ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី នួន ជា ដែលថា ដំណើរការពិនិត្យប្រតិចារឹកឡើងវិញបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ នួន ជា ក្នុងការតទល់ និងភ័ស្តុតាងនិងការរៀបចំការពារក្ដីរបស់គាត់ប្រកបដោយប្រសិទ្ធភាព។

## ២.៤.៧. ការយល់ឃើញពាក់ព័ន្ធនឹងសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ

### ២.៤.៧.១. ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន

៩៧. មេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន សន្និដ្ឋានថាសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ត្រូវតែច្រានចោលដោយសារសក្ខីកម្មនេះពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ហើយមេធាវីការពារក្ដីពុំមានឱកាសពិនិត្យលើភ័ស្តុតាងរបស់គាត់តាមរយៈការដេញដោលឡើយ។ សហព្រះរាជអាជ្ញាមិនបានលើកសេចក្ដីសន្និដ្ឋានលើករណីនេះ និងមិនបានសំអាងលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ពួកគេ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានសំអាងលើភ័ស្តុតាងរបស់ ស សារិន នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល គាត់នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ឬសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ពួកគេនោះឡើយ។

៩៨. អង្គជំនុំជម្រះរំឭកថា ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ហើយត្រូវបានសួរដេញដោលដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅពេលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវឆ្លើយសំណួរបន្តទៀត គាត់បានអះអាងថាមិនស្រួលខ្លួន និងត្រូវបាននាំទៅកាន់បន្ទប់ព្យាបាលជំងឺ។ ទោះបីជាលទ្ធផលនៃការតាមដានសុខភាពមិនបានបង្ហាញភ័ស្តុតាងអំពីបញ្ហាសុខភាពណាមួយក៏ដោយ ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីបានទទូចថាគាត់ត្រូវការសម្រាក ហេតុដូច្នេះគាត់ត្រូវបានដឹកត្រឡប់ទៅផ្ទះរបស់គាត់វិញ។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានរាយការណ៍ថា ស សារិន ពុំបានភ័យខ្លាចក្នុងការផ្ដល់សេចក្ដីថ្លែងរបស់គាត់នៅ អ.វ.ត.ក. នោះទេ ប៉ុន្តែគាត់នឹងត្រឡប់មកបញ្ចប់ការសួរដេញដោលគាត់វិញក្រោមលក្ខខណ្ឌថា គាត់ត្រូវតែបានផ្លាស់ទីលំនៅទៅសហរដ្ឋអាមេរិក ឬប្រទេសអូស្ត្រាលី។

៩៩. ដោយសារចំណុចមិនស៊ីចង្វាក់គ្នាមួយចំនួនជាពិសេស ការព្រួយបារម្ភដែលបានលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អាកប្បកិរិយារបស់គាត់ និងសំណើសុំរបស់គាត់ឲ្យផ្លាស់ទីលំនៅរបស់គាត់រួមទាំងគ្រួសារគាត់ទៅប្រទេសទីបីនោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានជូនដំណឹងដល់អង្គជំនុំជម្រះថា ខ្លួនពុំបានបង្ហាញមូលដ្ឋានសត្យានុម័តណាមួយចំពោះការភ័យខ្លាចក្នុងការផ្ដល់ភ័ស្តុតាងនោះទេ ហើយពុំបានផ្ដល់អនុសាសន៍ឲ្យផ្ដល់វិធានការការពារផងដែរ។ ហេតុដូច្នេះអង្គជំនុំជម្រះបានច្រានចោលសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិនឲ្យផ្លាស់ទីលំនៅគាត់ទៅកាន់ប្រទេសទីបីនោះ។ ទោះបីជាយ៉ាងនេះក្ដី ដោយយល់ឃើញថាគាត់គឺជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ ហើយមិនអាចត្រូវចាប់បង្ខំឲ្យផ្ដល់សក្ខីកម្មនោះ អង្គជំនុំជម្រះបានសម្រេចដកឈ្មោះរបស់គាត់ចេញពីក្នុងបញ្ជីបុគ្គលដែលត្រូវផ្ដល់សក្ខីកម្ម។

១០០. លើសពីនេះទៀត អង្គជំនុំជម្រះរំឭកថា ស សារិន ធ្លាប់ត្រូវបានសួរដេញដោលក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០១។ នៅក្នុងសំណុំរឿង ០០២/០២ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានស្នើសុំវិធានការការពារជាក់លាក់ ក្នុងនោះរួមមានការការពារអស់រយៈពេលមួយជីវិត ធ្វើជាលក្ខខណ្ឌនូវនឹងការផ្ដល់ភ័ស្តុតាងបន្ត។ សំណើសុំនេះត្រូវបានអង្គជំនុំជម្រះច្រានចោល ដោយសារតែវាមិនមានមូលហេតុសមហេតុសមផល និងមិនត្រឹមត្រូវ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីបានបដិសេធក្នុងការផ្ដល់សក្ខីកម្មបន្ត។ ហេតុដូច្នេះគាត់ពុំត្រូវបានក្រុមមេធាវីការពារក្ដីសួរដេញដោលនោះឡើយ។

១០១. អង្គជំនុំជម្រះពិចារណាឃើញថា ស សារិន បានព្យាយាមទាញផលប្រយោជន៍ជាបុគ្គលពីការផ្ដល់សក្ខីកម្មរបស់គាត់នៅក្នុងតុលាការ ដែលនេះប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់គាត់។ បន្ថែមពីនេះទៀត នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទមិនមានឱកាសសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនោះទេ ក្រោយពេលដែលសហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាសួរដេញដោលជាបឋមរួចមកហើយនោះ។ បញ្ហានត្ថិភាពនៃឱកាសសម្រាប់រាល់គ្រប់ភាគី នៅក្នុងសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានរារាំងអង្គជំនុំជម្រះក្នុងការប្រើប្រាស់ភ័ស្តុតាងរបស់ ស សារិន ដើម្បីបង្ហាញពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ។

ស្វែងរកការពិត-ផ្នែកច្បាប់ លេខ២៤៣ ខែមីនា ឆ្នាំ២០២០



ខៀវ សំផន កំពុងអានសុន្ទរកថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ២.៤.៧.២. អ្នកជំនាញ Henri LOCARD

**១០២.** មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា សន្និដ្ឋានថា Henri LOCARD មិនមែនជាអ្នកជំនាញដែលគួរឲ្យទុកចិត្តបាននោះទេ ដោយបានកត់សម្គាល់យ៉ាងជាក់លាក់អំពីការចោទប្រកាន់ពីភាពលម្អៀង ដែលអ្នកជំនាញរូបនេះបានបង្ហាញតាមរយៈមតិយោបល់របស់គាត់ ទៅលើមេធាវីការពារក្តីនៅក្នុង និងនៅក្រៅបន្ទប់សវនាការ។ មេធាវីការពារក្តី ខៀវ សំផន សន្និដ្ឋានថា គ្មានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ណាមួយរបស់ Henri LOCARD អំពី ខៀវ សំផន អាចត្រូវបានប្រើប្រាស់ជាភស្តុតាងនោះទេ ដោយសារសេចក្តីប្រកាសនេះខ្វះអព្យាក្រឹត្យភាព និងភាពសក្យានុម័ត។ មេធាវីការពារក្តី ខៀវ សំផន ក៏បានសន្និដ្ឋានថា សេចក្តីថ្លែងរបស់ Henri LOCARD ពុំស្របគ្នាទៅនឹងប្រភពដែលគាត់យកមកអះអាងទេ កាលណាយកប្រភពទាំងនោះមកផ្ទៀងផ្ទាត់។ មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា អង្គជំនុំជម្រះគួរកុំពិចារណាទៅលើភស្តុតាងរបស់ LOCARD ទាំងស្រុងតែម្តង ដោយបានចោទសួរអំពីនីត្យានុកូលភាព និងវិធីសាស្ត្រ ព្រមទាំងកង្វះលទ្ធភាពក្នុងការពិនិត្យប្រភពសក្ខីកម្មរបស់គាត់។ សហព្រះរាជអាជ្ញាបានសំអាងលើសំណេរ និងសក្ខីកម្មរបស់ LOCARD នៅក្នុងសារណារបស់ពួកគេ ប៉ុន្តែពុំបានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីនោះទេ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានសំអាងភស្តុតាងរបស់ LOCARD ឬឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីនោះឡើយ។

**១០៣.** អង្គជំនុំជម្រះរំឭកថា ខ្លួនបានកំណត់លោក Henri LOCARD ថាជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០២ ដោយផ្អែកសំខាន់លើបទពិសោធន៍របស់គាត់ជាច្រើនទសវត្សរ៍ដែលធ្វើការស្រាវជ្រាវអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ហើយនឹងបទបង្ហាញ និងការបោះពុម្ពផ្សាយរបស់គាត់លើប្រធានបទនេះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាលោក LOCARD បានបំពេញការងារឲ្យការិយាល័យសហព្រះរាជអាជ្ញាក្នុងការចងក្រងរបាយការណ៍ស្តីពីមន្ទីរសន្តិសុខ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏ដោយ ប៉ុន្តែការបារម្ភណាមួយអំពីលទ្ធភាពលម្អៀងនឹងត្រូវបានចាត់ទុកជាបញ្ហាពាក់ព័ន្ធនឹងការវាយតម្លៃភស្តុតាង។ អង្គជំនុំជម្រះក៏បានរំឭកថា អ្នកជំនាញដែលត្រូវបានតែងតាំងត្រូវជួយតុលាការ «ដោយស្មោះត្រង់» និង «ឲ្យអស់ពីលទ្ធភាពរបស់ខ្លួន» ហើយត្រូវបានរំពឹងថា នឹងផ្តល់សក្ខីកម្មដោយអព្យាក្រឹត្យបំផុត និងដោយមិនលម្អៀងតាមបែបវិទ្យាសាស្ត្រ។ បើសិនខ្វះចំណុចនេះ ភាពគួរឲ្យទុកចិត្តបាននៃការសន្និដ្ឋានទស្សនៈ ការបកស្រាយ ឬសេចក្តីសន្និដ្ឋានរបស់ពួកគេនឹងចោទជាបញ្ហា ដោយសារតែវាអាចត្រូវបានមើលឃើញថា មានភាពលម្អៀង ឬការលេចឡើងនូវភាពលម្អៀង។

**១០៤.** នៅក្នុងសំណុំរឿង ០០២/០២ លោក LOCARD បានផ្តល់សក្ខីកម្មក្នុងរយៈពេលបួនថ្ងៃ ក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០១៦។ នៅពេលផ្តល់សក្ខីកម្មថ្ងៃចុងក្រោយ លោក LOCARD បានឆ្លើយទៅនឹងសំណួរពីមេធាវីការពារក្តី ខៀវ សំផន ដោយបានលើកឡើងថា «ខ្ញុំប្រហែលជាពិបាកឆ្លើយនឹងសំណួររបស់លោកស្រីហើយ ពីព្រោះថាកាលពីម្សិលមិញនោះលោកស្រីបានដាក់ទារុណកម្មត្រជាក់មកលើខ្ញុំ។ ឥឡូវនេះខ្ញុំដឹងថា តើទារុណកម្មត្រជាក់ហ្នឹងវាយ៉ាងណាហើយ»។ នៅពេលកាសែតក្នុងស្រុកមួយបានទាក់ទងគាត់សុំយោបល់នាពេលក្រោយមក លោក LOCARD ត្រូវបានគេរាយការណ៍ថា គាត់បាននិយាយថា «មនុស្សទាំងនេះ [មេធាវីរបស់ជនជាប់ចោទ] គឺជាឧក្រិដ្ឋជន ដោយសារពួកគេធ្វើឲ្យសាលាក្តីកំពុងខាតពេលជាច្រើនម៉ោង សប្តាហ៍ ថ្ងៃ និងខែ» «ហើយ [វា] [សាលាក្តី] ពុំគួរមានរយៈពេលលើសពីបីឆ្នាំទេ ដោយសារពួកនេះសាកសមនឹងមនុស្សដែលយើងហៅថា ពួកប្រកែក ពួកបដិសេធ ពោលគឺពួកគេប្រកែកការពិត»។

**១០៥.** អង្គជំនុំជម្រះពិចារណាឃើញថា តាមរយៈសេចក្តីថ្លែងនេះ លោក LOCARD បានបង្ហាញយ៉ាងច្បាស់ថា គាត់ពុំមានលទ្ធភាពក្នុងការជួយអង្គជំនុំជម្រះតាមរយៈការផ្តល់នូវសក្ខីកម្ម ដោយអព្យាក្រឹត្យ និងមិនលម្អៀងដែលអង្គជំនុំជម្រះបានរំពឹងពីអ្នកជំនាញនៅក្នុងរឿងក្តីនេះទេ។ ផ្អែកលើហេតុផលនេះ អង្គជំនុំជម្រះច្រានចោលទស្សនៈអ្នកជំនាញដែលបានផ្តល់ដោយ លោក LOCARD ជូនអង្គជំនុំជម្រះនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម។

**១០៦.** លោក LOCARD គឺជាអ្នកនិពន្ធឯកសារភស្តុតាងជាច្រើនដែលមាននៅក្នុងសំណុំរឿងរួមទាំងសៀវភៅចំនួនពីរក្បាល និក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ និងរបាយការណ៍ចំនួន ១១ ស្តីពីមន្ទីរសន្តិសុខតំបន់ដែលសហព្រះរាជអាជ្ញាបានឲ្យគាត់រៀបចំ។ អង្គជំនុំជម្រះរកឃើញថា ស្នាដៃជាច្រើនបានសំអាងលើប្រភពអនាមិក ឬកិច្ចសម្ភាសន៍ជាមួយនឹងសាក្សី ដែលភាគច្រើនបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ហើយជានិច្ចកាលពុំអាចរកសេចក្តីថ្លែងរបស់ពួកគេបាន ឬនៅពេលរកបានយើងឃើញមានចំណុចមួយចំនួនដែលខុសពីការអះអាងរបស់លោក LOCARD។ ហេតុដូច្នេះ លើកលែងតែពេលយើងអាចពិនិត្យមើលសម្ភារជាក់លាក់ណាមួយច្បាស់លាស់ និងអាចទុកចិត្តបាន ហើយមានការគាំទ្រការសន្និដ្ឋានរបស់គាត់ នោះទើបអង្គជំនុំជម្រះផ្តល់តម្លៃជាភស្តុតាងតិចតួចលើស្នាដៃនានាដែលនិពន្ធដោយលោក LOCARD។

### ២.៤.៧.៣. អ្នកជំនាញ អ៊ីសា ឧស្មាន និង Alexander HINTON

**១០៧.** មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងភាពគួរឲ្យទុកចិត្តបាននៃសក្ខីកម្មរបស់អ្នកជំនាញ អ៊ីសា ឧស្មាន និង Alexander HINTON។ អង្គជំនុំជម្រះឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានទាំងនេះដូចខាងក្រោម តាមបរិបទនៃអង្គហេតុដែលអ្នកជំនាញនីមួយៗបានផ្តល់សក្ខីកម្ម។

### ២.៤.៧.៤ សាក្សី សួយ សៅ និង សែម អំ

**១០៨.** មេធាវីការពារក្តី នួន ជា សន្និដ្ឋានមានហេតុផលគួរឲ្យជឿជាក់បានថា មានការព្យាយាមរំខានសាក្សី សួយ សៅ និង សែម អំ ដែលអាចជាការជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការ។ មេធាវីការពារក្តីបានលើកឡើងអំពី «ការប្រែប្រួល» នៅក្នុងសក្ខីកម្មរបស់ សួយ សៅ ដែលចាប់ផ្តើមក្រោយពេលសម្រាកអាហារថ្ងៃត្រង់ នៅក្នុងអំឡុងពេលដែលគាត់ផ្តល់

សក្ខីកម្ម និងការដែលអង្គជំនុំជម្រះបានសម្រេចធ្វើសវនាការជាសាធារណៈ ដើម្បីសួរដេញដោលសាក្សីរូបនេះ។ ជាមួយគ្នានេះ មេធាវីការពារក្តីក៏បានលើកឡើងពីភាពផ្ទុយគ្នារវាងចម្លើយរបស់ សែម អ៊ំ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (ខ្សែអាត់សំឡេងដែលត្រូវបានចាក់ស្តាប់នៅក្នុងសវនាការ) និងសក្ខីកម្មរបស់គាត់។ ផ្អែកលើវិធីសាស្ត្ររបស់តុលាការ ICTY កិច្ចសម្ភាសន៍របស់សាក្សីជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាគួរទទួលយក ប៉ុន្តែត្រូវដកចេញត្រង់ផ្នែកខ្លះនៃសក្ខីកម្មរបស់ពួកគេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សក្ខីកម្មរបស់សាក្សីទាំងពីរនាក់នេះមិនមានភាពស៊ីចង្វាក់ និងផ្ទុយគ្នា ប៉ុន្តែចំណុចផ្ទុយគ្នាទាំងនេះបង្ហាញពីកិច្ចប្រឹងប្រែងរបស់ ប.ក.ក. ក្នុងការបោកបញ្ឆោតកងទ័ពនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានចាក់ផ្សាយចម្លើយសារភាពនៅមន្ទីរសន្តិសុខស-២១ របស់អតីតមេបញ្ជាការពួកគេឲ្យពួកគេស្តាប់។

**១០៩.** អង្គជំនុំជម្រះកត់សម្គាល់ថា នៅពេលសួរដេញដោលក្នុងសវនាការជាអសាធារណៈ សាក្សី សួយ សៅ បានផ្តល់សក្ខីកម្មថាមិនមាននរណាទៅទាក់ទងគាត់ឲ្យកែប្រែសក្ខីកម្មរបស់គាត់នៅពេលសម្រាកអាហារថ្ងៃត្រង់នោះទេ ហើយគាត់ក៏មិនអាចភ័យខ្លាចពីសុវត្ថិភាពរបស់គាត់ដែរ។ ចំពោះ សែម អ៊ំ វិញ មេធាវីការពារក្តី នួន ជា ពុំបានបង្ហាញភ័ស្តុតាងណាមួយដែលបង្ហាញអំពីការជ្រៀតជ្រែក ដែលជាការព្យាយាមកែប្រែសក្ខីកម្មរបស់សាក្សីនោះឡើយ។ ហេតុដូច្នេះ គ្មានហេតុផលណាមួយត្រូវជំនួសសក្ខីកម្មផ្ទាល់របស់សាក្សីទាំងនេះ ដោយចម្លើយពីមុនរបស់ពួកគេជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ លើសពីនេះទៀត មេធាវីការពារក្តី នួន ជា ខកខានមិនបានបង្ហាញយុត្តិសាស្ត្រណាមួយ ដែលអាចគាំទ្រការទទួលយកដោយអន្លើនូវផ្នែកនៃចម្លើយរបស់សាក្សីជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាផង និងផ្នែកនៃសក្ខីកម្មរបស់គាត់នៅក្នុងតុលាការផងទៅតាមការចង់បានរបស់មេធាវីការពារក្តីនោះទេ។ ហេតុដូច្នេះ សំណើសុំនេះត្រូវបដិសេធចោល។

### ២.៥. សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌

### ២.៥.១. សេចក្តីផ្តើម

**១១០.** នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នួន ជា និង ខៀវ សំផន បានចោទប្រកាន់ថាសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ពួកគាត់ត្រូវបានរងការរំលោភបំពាន។ អង្គជំនុំជម្រះបានពិនិត្យលើការចោទប្រកាន់ទាំងនេះទៅតាមករណីជាក់ស្តែងនីមួយៗ និងផ្តល់ជាដំណោះស្រាយក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវដូច្នេះ។ ជនជាប់ចោទបានបន្តលើកឡើងអំពីបញ្ហាទាំងនេះនៅក្នុងសារណាបញ្ចប់ពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន និងបានស្នើសុំឲ្យអង្គជំនុំជម្រះច្រានចោលភ័ស្តុតាងពាក់ព័ន្ធ និងអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពសំណុំរឿង ០០២/០២ ដោយស្នើសុំឲ្យពិចារណាឡើងវិញទៅលើសេចក្តីសម្រេចដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ និងពិចារណាទៅលើការចោទប្រកាន់អំពីការរំលោភសិទ្ធទាំងនេះនៅក្នុងការវាយតម្លៃលើភ័ស្តុតាងចុងក្រោយ។

**១១១.** អង្គជំនុំជម្រះនឹងសម្រេចលើសំណើទាំងនេះនៅក្នុងផ្នែកខាងក្រោមនេះ ហើយសេចក្តីសម្រេចនេះ គឺធ្វើឡើងដើម្បីបំពេញបន្ថែមទៅលើរាល់សេចក្តីសម្រេចដែលបានចេញនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ។ អង្គជំនុំជម្រះនឹងពិនិត្យមើលផងដែរថា តើកំហុសផ្នែកនីតិវិធី (ប្រសិនបើមាននោះ) មានផលប៉ះពាល់ជារួមអ្វីខ្លះទៅលើការជំនុំជម្រះក្តីដោយយុត្តិធម៌។

**(តនៅលេខក្រោយ)**





# សិស្សានុសិស្សនៅវិទ្យាល័យព្រៃញ្ញៅទទួលចំណេះដឹង ពីប្រវត្តិសាស្ត្រខ្មែរក្រហម

***មីន សាណាស់***



លោក ផេង ពង្សរ៉ាស៊ី ធ្វើបទបង្ហាញទាក់ទងនឹងការជម្លៀសប្រជាជនក្នុងរបបខ្មែរក្រហមប្រាប់ដល់សិស្សានុសិស្សថ្នាក់ទី១២ នៃវិទ្យាល័យព្រៃញ្ញៅ នៅអំឡុងពេលធ្វើវេទិកាថ្នាក់រៀន។ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សប្រុសស្រីចំនួន៦៣នាក់ នៃវិទ្យាល័យព្រៃញ្ញៅ បានទទួលចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្វែងយល់ស៊ីជម្រៅពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ និងវិធីទប់ស្កាត់អំពើនេះជាលក្ខណៈបុគ្គល គ្រួសារឬសហគមន៍ និងប្រទេសជាតិតាមរយៈវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ វេទិកានេះទទួលបានការសហការពីក្រសួងអប់រំ យុវជន និងកីឡា និងមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ។

វិទ្យាល័យព្រៃញ្ញៅ មានទីតាំងស្ថិតនៅភូមិព្រៃញ្ញៅ ឃុំព្រៃញ្ញៅ ស្រុកពារាំង ខេត្តព្រៃវែង មានចម្ងាយ៧៤ គីឡូម៉ែត្រពីទីក្រុងភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៨។ នៅក្នុងឆ្នាំ១៩៨៧ សាលារៀនព្រៃញ្ញៅបានកកើតឡើងក្រោមការផ្តួចផ្តើមគំនិតពីព្រះចៅអធិការវត្តព្រៃញ្ញៅខាងជើង ព្រះនាម សួស ប៊ុត។ មួយឆ្នាំក្រោយមក សាលា

ដែលទើបកសាងថ្មីនេះ បានចាប់ផ្តើមទទួលសិស្សឲ្យចូលរៀន។ ចាប់ពីឆ្នាំ២០០៧មក សាលារៀននេះបានប្រែក្លាយទៅជាវិទ្យាល័យព្រៃញ្ញោវរហូតមក។

## ដំណើរការវេទិកាថ្នាក់រៀន

មជ្ឈមណ្ឌលឯកសារកម្ពុជា បានអនុវត្តវេទិកាថ្នាក់រៀនលើកទី៨៤របស់ខ្លួន តាមការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដូចឆ្នាំមុនៗ ដើម្បីពង្រឹងចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការយល់ដឹងពីអត្ថន័យនៃពាក្យអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើនេះនាពេលអនាគត។ វេទិកាថ្នាក់រៀន គឺជាធាតុផ្សំមួយដ៏សំខាន់ក្នុងកម្មវិធីស្រាវជ្រាវ និងអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងមានគោលបំណងបង្ហាញឲ្យឃើញពីតម្លៃនៃការសិក្សាប្រវត្តិសាស្ត្រ ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយសម្រាប់ការផ្លាស់ប្តូរនាពេលអនាគត។

ជាមួយនឹងការស្វាគមន៍ដ៏រាក់ទាក់ពីសំណាក់លោកនាយក និងគ្រូបង្រៀននៃវិទ្យាល័យនេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានអនុវត្តយ៉ាងពេញលេញនូវកម្មវិធីមួយចំនួននៃវេទិកាថ្នាក់រៀននេះ ដូចដែលបានគ្រោងទុក។ សិស្សានុសិស្សម្នាក់ៗ មានជំនឿចិត្តថាខ្លួននឹងបានទទួលចំណេះដឹងបន្ថែមពីវេទិកានេះ ហើយសង្ឃឹមយ៉ាងមុតមាំថា ខ្លួននឹងអាចមានលទ្ធភាពឆ្លើយសំណួរជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើមុខវិជ្ជាប្រវត្តិវិទ្យាត្រូវបានជ្រើសរើសដាក់បញ្ចូលក្នុងការប្រឡងបញ្ចប់ចំណេះដឹងទូទៅថ្នាក់ជាតិនាពេលខាងមុខ ហើយក្នុងនោះមានសំណួរមួយចំនួនគឺជាសំណួរដែលទាក់ទងនឹងប្រវត្តិសាស្ត្រនេះ។

សិស្សានុសិស្សដែលបានចូលរួមនៅក្នុងកម្មវិធីវេទិកានេះ បានទទួលនូវចំណេះដឹងបន្ថែមពីបុព្វហេតុ និងមូលហេតុនៃៈ ១) ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា។ ២) ការបំបាត់ទីផ្សារ និងរូបិយវត្ថុ។ ៣) ការកម្ទេចវត្តអារាម និងផ្សឹកព្រះសង្ឃ។ ៤) ការបិទសាលារៀន និងគ្រឹះស្ថានសិក្សា។ ៥) ការ



បរិវេណវិទ្យាល័យព្រៃញ្ញោវ។ វិទ្យាល័យនេះស្ថិតនៅភូមិព្រៃញ្ញោវ ឃុំព្រៃញ្ញោវ ស្រុកពារាំង ខេត្តព្រៃវែង។
(ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)





សម្លាប់បញ្ញវន្ត មន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់។ ៦) ការបង្កើតសហករណ៍នៅទូទាំងប្រទេស។ ៧) ការផ្តាច់ទំនាក់ទំនង និងបំបែកបំបាក់ក្រុមគ្រួសារ និង ៨) ការបណ្តេញជនជាតិវៀតណាម និងការធ្វើសង្គ្រាមជាមួយវៀតណាម។

លើសពីនេះទៀត ការធ្វើបទបង្ហាញពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ ដែលបានផ្តោតលើការពន្យល់ពីធាតុផ្សំទាំងឡាយដែលនាំកើតមានអំពើប្រល័យពូជសាសន៍ និងពីវិធីទប់ស្កាត់អំពើប្រល័យពូជសាសន៍ជាបុគ្គល សហគមន៍ក្រុមគ្រួសារ និងប្រទេសជាតិទាំងមូល ត្រូវបានពន្យល់យ៉ាងក្បោះក្បាយទៅកាន់សិស្សានុសិស្សក្នុងន័យតម្រង់ទិសយុវវ័យជំនាន់ក្រោយ កុំឲ្យដើរជាន់ដានចាស់ដែលជាដានអាក្រក់ និងបង្កវិនាសកម្មធ្ងន់ធ្ងរដល់សង្គមជាតិ។

ជាភ័ស្តុតាងជាក់ស្តែងស្តីអំពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម ក្រុមការងារបានចាក់បញ្ចាំងខ្សែភាពយន្តឯកសារមួយស្តីអំពីជីវិតកុមារ និងលទ្ធផលដ៏សោកសង្រេងរបស់កុមារទាំងនោះ បន្ទាប់ពីបានឆ្លងកាត់និងរួចរស់ជីវិតពីរបបខ្មែរក្រហម។

មុនពេលបញ្ចប់វេទិកាថ្នាក់រៀន ការសាកល្បងចំណេះដឹងរបស់សិស្សតាមរយៈការបំពេញទម្រង់គារវាងស្ទាបស្ទង់មតិមួយត្រូវបានធ្វើឡើងភ្លាមៗ។ ការសាកល្បងនេះ គឺជាវិធីសាស្ត្រមួយក្នុងការបង្កើនការចងចាំទុកដង និងជាការលើកទឹកចិត្តសិស្សឲ្យមានបទពិសោធន៍ក្នុងការឆ្លើយទៅនឹងសំណួរជាច្រើនទាក់ទងនឹងរបបខ្មែរក្រហម។ បន្ថែមពីនេះទៀត ការសាកល្បងនេះក៏ជាផ្នែកដ៏មានសារសំខាន់មួយក្នុងការទម្លាប់ឲ្យសិស្សចេះគិតគូរយ៉ាងស៊ីជម្រៅពាក់ព័ន្ធនឹងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។ បន្ទាប់មក សិស្សានុសិស្សទាំងអស់ទទួលបានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងសៀវភៅ «អត្តសញ្ញាណជនជាតិចាមនៅក្នុងយុគសម័យសកលភាវូបនីយកម្ម» ម្នាក់ ២ក្បាល ដើម្បីទុកជាឯកសារមេរៀនបន្ថែមសម្រាប់ការអភិវឌ្ឍន៍ចំណេះដឹងរបស់ខ្លួន។

ដើម្បីស្វែងរកការអភិវឌ្ឍន៍កម្មវិធីវេទិកាថ្នាក់រៀនលើកក្រោយៗទៀត និងដើម្បីចង់ដឹងពីអារម្មណ៍ និងការយល់ឃើញរបស់សិស្សក្នុងការចូលរួមនៅក្នុងវេទិកាថ្នាក់រៀននេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបសម្ភាសន៍ជាមួយសិស្សានុសិស្សមួយចំនួន ដែលលទ្ធផលនៃការសម្ភាសន៍នេះត្រូវបានបង្ហាញដូចតទៅ៖

សិស្សានុសិស្សថ្នាក់ទី១២ នៅវិទ្យាល័យព្រៃញ្ញោវកំពុងបំពេញកម្រងសំណួរស្ទាបស្ទង់មតិទាក់ទងនឹងចំណេះដឹងពីរបបខ្មែរក្រហម មុនពេលវេទិកាថ្នាក់រៀនចាប់ផ្តើម។ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ស៊ិន ប៊ុនលួត ភេទប្រុស អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកសង្គមវិទ្យា ផ្តល់បទសម្ភាសន៍ទាក់ទងនឹងវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់ មីន សាណាស់ បុគ្គលិកគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

«ការរៀនប្រវត្តិសាស្រ្តខ្មែរក្រហម បានផ្តល់ចំណេះដឹងដល់រូបខ្ញុំ និងពង្រីកចំណេះដឹងរបស់សិស្សានុសិស្សទាំងអស់នៅវិទ្យាល័យព្រៃញ្ញៅ។ មុនពេលមានវេទិកានេះ ខ្ញុំបានដឹងពីប្រវត្តិសាស្រ្តខ្មែរក្រហមតិចតួច ហើយក៏មិនសូវយល់ច្បាស់ដែរ។ ក្នុងពេលចូលរួមវេទិកានេះ ខ្ញុំចាប់អារម្មណ៍ជាងគេគឺអំពើប្រល័យពូជសាសន៍មកលើប្រជាជនក្នុងសម័យនោះ ការប្រើកុមារឲ្យធ្វើពលកម្មហួសកម្លាំង និងការបំបែកគ្រួសារមិនឲ្យរស់នៅជុំគ្នា។ ខ្ញុំចង់ឲ្យខាងក្រុមការងារ វេទិកាថ្នាក់រៀននេះបង្រៀនប្រវត្តិសាស្រ្តខ្មែរក្រហមឲ្យច្រើនជាងនេះទៀត»។



ម៉េង ស្រីណិត ភេទស្រី អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្រ្តសង្គម ផ្តល់បទសម្ភាសន៍ទាក់ទងនឹងវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់ មីន សាណាស់ បុគ្គលិកគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបានយល់ដឹងពីប្រវត្តិសាស្រ្តខ្មែរក្រហមបានជាងមុន ពេលបានចូលរួមវេទិកាថ្នាក់រៀននេះ។ ខ្ញុំមានអារម្មណ៍សោកសៅនៅពេលបានមើលវីដេអូរឿង «កុមារកម្ពុជា» ថតក្រោយរបបខ្មែរក្រហម។ ក្មេងៗមិនទាន់គ្រប់អាយុត្រូវឃ្លាតឆ្ងាយពីឪពុកម្តាយ បែកបាក់គ្រួសារ ដើរដោយគ្មានគោលដៅ មិនទទួលបានការអប់រំ និងប្រឈមនឹងជំងឺផ្សេងៗ»។







គាត ហួយ ភេទប្រុស អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកសង្គមវិទ្យា ផ្តល់បទសម្ភាសន៍ទាក់ទងនឹងវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជា-ធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់ មីន សាណាស់ បុគ្គលិកគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

«វេទិកាថ្នាក់រៀននេះពិតជាល្អ ព្រោះអាចធ្វើឲ្យខ្ញុំយល់ដឹងបន្ថែមពីប្រវត្តិសាស្រ្តខ្មែរក្រហម។ ខ្ញុំធ្លាប់បានឮឪពុកម្តាយខ្ញុំ និយាយថា របបខ្មែរក្រហមប្រើមនុស្សឲ្យធ្វើការធ្ងន់ហួសកម្លាំង និងផ្តល់របបអាហារតិចតួចឲ្យហូប។ ក្នុងការធ្វើបទបង្ហាញ ខ្ញុំចាប់អារម្មណ៍គោលនយោបាយបំបាត់សាលារៀន និងគ្រឹះស្ថានសិក្សាផ្សេងៗរបស់ខ្មែរក្រហម។ ខ្ញុំយល់ថាការធ្វើបែបនេះមិនត្រឹមត្រូវទាល់តែសោះ ដោយសារមនុស្សម្នាក់ៗត្រូវការចំណេះដឹងដើម្បីឲ្យជីវិតរស់នៅបានប្រសើរ។ ខ្ញុំគិតថាដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺត្រូវទប់ស្កាត់អំពើហិង្សាផ្សេងៗ ចេះជួយគ្នាទៅវិញទៅមកនៅក្នុងសហគមន៍»។



ផន់ ស្រីពេជ្រ ភេទស្រី អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្រ្តសង្គម ផ្តល់បទសម្ភាសន៍ទាក់ទងនឹងវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់ មីន សាណាស់ បុគ្គលិកគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

«វេទិកាថ្ងៃនេះធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងច្រើនអំពីប្រទេសកម្ពុជាក្រោមការត្រួតត្រារបស់ខ្មែរក្រហម។ ខ្ញុំចាប់អារម្មណ៍ចំណុចដែលខ្មែរក្រហមបែងចែកប្រជាជនឲ្យរស់នៅដាច់ដោយឡែកពីគ្នា។ ខ្ញុំគិតថាការលុបបំបាត់សាលារៀន គឺជារឿងមិនត្រឹមត្រូវ ព្រោះសិស្សត្រូវការចំណេះ និងការសិក្សាដើម្បីធ្វើឲ្យអនាគតរុងរឿង និងប្រទេសជាតិរីកចម្រើន។ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ យើងត្រូវលើកទឹកចិត្តប្រជាជនកុំឲ្យមានការរើសអើង និងអប់រំឲ្យប្រជាជនគោរព និងស្រឡាញ់គ្នា»។

«ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# គង់ ចំរើន ៖ បុគ្គលិកប្រៃសណីយ៍

បន្ទាប់ពីខ្ញុំបានបញ្ចប់ថ្នាក់ទី៥ "ថ្នាក់ទី៥នាសម័យកាលនោះស្មើនឹងថ្នាក់ទី៧ នៅក្នុងបស្ចិមប្រទេស" ខ្ញុំបានផ្លាស់ទីលំនៅពីខេត្តកណ្តាល ទៅក្រុងភ្នំពេញ។ ដូច្នេះខ្ញុំអាចចូលរៀននៅវិទ្យាល័យបាន។ ខ្ញុំបានប្រឡងចូលបម្រើការងារផ្នែកសេវាកម្មប្រៃសណីយ៍។ ខ្ញុំបានប្រឡងជាប់ និងចាប់ផ្តើមធ្វើការនៅការិយាល័យប្រៃសណីយ៍ នៅក្នុងឆ្នាំ១៩៦១។

ខ្ញុំបានចាប់ចិត្តស្រឡាញ់នារីម្នាក់ឈ្មោះ សាយ ងឹម នៅពេលនាងកាត់សក់ និងធ្វើម៉ាស្សាក្បាលឲ្យខ្ញុំនៅក្នុងហាងកាត់សក់មួយ ដែលនាងបានជួលនៅតាមដងផ្លូវកម្ពុជាក្រោម។ យើងបានរៀបការនៅឆ្នាំ១៩៦៣ និងមានកូនបួននាក់។ គ្រួសារយើងមានវណ្ណៈភាពមធ្យម និងមានសុភមង្គល។ យ៉ាងណាក៏ដោយសុភមង្គលរបស់យើងមិនបានស្ថិតស្ថិរដល់ទីបំផុតទេ គឺបានត្រឹមពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ប៉ុណ្ណោះ។

ខ្មែរក្រហមបាននិយាយប្រាប់យើងឲ្យចាកចេញពីទីក្រុងតែរយៈពេលបីថ្ងៃប៉ុណ្ណោះ ពីព្រោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក។ យើងបានយករបស់របរប្រើប្រាស់ផ្ទាល់ខ្លួនមួយចំនួនដាក់នៅលើម៉ូតូ និងចាកចេញទៅ។ យើងចំណាយពេល១៥ថ្ងៃដើម្បីធ្វើដំណើរទៅភូមិកំណើត។



គង់ ចំរើន ជាមួយនឹងមីងៗ របស់គាត់ នូ ថា (អង្គុយខាងឆ្វេង) និង នូ ប៉ាត និងក្មួយស្រី (អង្គុយខាងមុខ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភ្លាមៗបន្ទាប់ពីយើងបានទៅដល់ភូមិកំណើត ខ្ញុំត្រូវបានសួរនាំពីប្រវត្តិរូប។ អ្នកស្រុកនៅក្នុងភូមិបានដឹងថាខ្ញុំធ្លាប់បានធ្វើការងារនៅទីក្រុងភ្នំពេញ ដូច្នេះវាមិនមែនជាការងាយស្រួលសម្រាប់ខ្ញុំក្នុងការនិយាយកុហកឡើយ។

ការរស់នៅបានក្លាយជាសុបិនអាក្រក់មួយ។ ខ្ញុំមានការព្រួយបារម្ភថា ថ្ងៃណាមួយ ខ្ញុំនឹងត្រូវចាប់ខ្លួនយកចេញពីភូមិ ដូចមន្ត្រីរដ្ឋការជាច្រើនអ្នកផ្សេងទៀតដែរ។ មិត្តភក្តិម្នាក់ក្នុងចំណោមមិត្តភក្តិជាច្រើនរបស់ខ្ញុំ ដែលធ្លាប់ធ្វើជាទាហាន លន់ នល់ ត្រូវបានបញ្ជូនទៅសម្លាប់ បន្ទាប់ពីគាត់បានមកដល់ស្រុកកំណើតបានមួយថ្ងៃ។

ប្រជាជនថ្មីនៅក្នុងភូមិ មានចំនួនពាក់កណ្តាល។ ខណៈខ្ញុំត្រូវបានចាត់ទុកជាប្រជាជាជនថ្មីម្នាក់ រីឯសាច់ញាតិរបស់ខ្ញុំនៅក្នុងភូមិជាប្រជាជនមូលដ្ឋាន។ គេបានគ្រប់គ្រងយើង និងចាត់ចែងយើងឲ្យធ្វើការងារ។ ខ្ញុំបានដឹកប្រឡាយជាច្រើន ហើយប្រពន្ធរបស់ខ្ញុំក្លាយជាកសិករម្នាក់។ ការងារធ្ងន់ធ្ងរណាស់ក្នុងមួយថ្ងៃខ្ញុំត្រូវដឹកប្រឡាយឲ្យបានប្រាំម៉ែត្រការ៉េ ហើយយើងបានទទួលរបបអាហារហូបតិចតួចបំផុត។

ជាសំណាងល្អខ្ញុំបានជួបគណៈតំបន់កោះធំគាត់ជាគ្រូគណិតវិទ្យារបស់ខ្ញុំ។ ពេលមួយនោះ ខ្ញុំបានហៅគាត់ថា "លោកគ្រូ" ប៉ុន្តែគាត់បានប្រាប់ខ្ញុំឲ្យហៅគាត់ថា "សមមិត្ត" ជំនួសវិញ។ គាត់បានប្រាប់ខ្ញុំឲ្យគោរពតាមវិន័យរបស់អង្គការជានិច្ច។ ខ្ញុំបាននិយាយប្រាប់គាត់ដោយស្មោះត្រង់ថា ប្រជាជននៅក្នុងភូមិត្រូវបានសម្លាប់ ខ្ញុំមានការព្រួយបារម្ភថាខ្ញុំនឹងត្រូវគេសម្លាប់នៅថ្ងៃណាមួយមិនខាន។ ដូច្នេះគាត់បានសរសេរលិខិតផ្លូវការមួយឲ្យទៅសមមិត្តអនុប្រធានរបស់គាត់ ដោយត្រូវផ្ទេរខ្ញុំទៅខេត្តបាត់ដំបងនៅចុងឆ្នាំ១៩៧៦។ លិខិតនោះបានចាត់ខ្ញុំឲ្យធ្វើដំណើរតាមរទេះភ្លើងជើងទីបី។ ខ្ញុំដឹងថា ប្រជាជនទាំងអស់ដែលបានធ្វើដំណើរតាមរថភ្លើងជើងទីមួយនិងជើងទីពីរត្រូវបានសម្លាប់ចោល។

នៅខេត្តបាត់ដំបង អង្គការបានសួរអំពីប្រវត្តិរបស់យើងទៀត។ ខ្ញុំបានប្រាប់អង្គការថា ខ្ញុំជាជាងកាត់សក់ម្នាក់។ ទោះបីជាខ្ញុំមិនចេះកាត់សក់សោះក៏ដោយ ក៏ខ្ញុំត្រូវបានអង្គការឲ្យធ្វើជាជាងកាត់សក់ដែរ ។ ប្រពន្ធរបស់ខ្ញុំក៏ធ្វើការងារជាជាងកាត់សក់ដែរ ខណៈដែលកូនទាំងបីរបស់យើងត្រូវបានបញ្ជូនទៅនៅអង្គភាពកុមារ។ កូនប្រុសរបស់យើងមានអាយុប្រាំពីរខែ បានរស់នៅជាមួយប្រពន្ធខ្ញុំ។

នៅពេលដែលអង្គការប្រគល់កន្ត្រៃកាត់សក់ឲ្យខ្ញុំជាលើកដំបូង ខ្ញុំមានការភ័យព្រួយណាស់ ប្រសិនបើខ្ញុំកាត់សក់ឲ្យយោធាម្នាក់មិនបានសមរម្យទេ ខ្ញុំនឹងមានបញ្ហាធំ។ ទោះជាយ៉ាងណាក៏ដោយខ្ញុំត្រូវតែធ្វើ។ ខ្ញុំគ្មានការស្ទាក់ស្ទើរក្នុងការធ្វើការងារនេះឡើយ។ ខ្ញុំបានក្លាយទៅជាជាងកាត់សក់ជំនាញម្នាក់។ ប្រជាជនជាច្រើនបានតម្រង់ជួរចូលមកកាត់សក់។ ជើងរបស់ខ្ញុំបានហើមមកពីការឈរជាច្រើនម៉ោងនៅពេលនោះ។ គណៈតំបន់ មានសមានចិត្តល្អចំពោះខ្ញុំ និងប្រាប់ខ្ញុំឲ្យទៅសម្រាកក្នុងអង្រឹងមួយ ហើយលើកជើងខ្ពស់ឡើងលើ។ ទោះជាយ៉ាងណាក៏ដោយ ការលើកជើងនេះមិនបានជួយអ្វីដល់ខ្ញុំទេ ពីព្រោះជើងរបស់ខ្ញុំហើមដោយសារកង្វះអាហាររូបត្ថម្ភ។ គ្រូពេទ្យបានឲ្យទឹកត្នោតផ្អែមខ្ញុំផឹកជាច្រើន បន្ទាប់មកខ្ញុំបានរាករូសជាខ្លាំង។ ក្នុងរយៈពេលបីថ្ងៃ ជើងរបស់ខ្ញុំបានស្រកហើម ប៉ុន្តែរូបរាងកាយរបស់ខ្ញុំដូចគ្រោងឆ្អឹងអីចឹង។

នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ខ្មែរក្រហមបានឲ្យយើងហូបតាមចិត្ត។ ខ្ញុំមិនបានហូបច្រើនទេ ព្រោះក្រពះរបស់ខ្ញុំមានទម្លាប់ទទួលអាហារតិចតួច រីឯប្អូនប្រុសរបស់ខ្ញុំវិញស្ទើរតែស្លាប់ដោយសារហូបច្រើនជ្រុល។ នៅពេលដែលខ្ញុំចាប់ផ្តើមឡើងទម្ងន់បន្តិច គណៈតំបន់បាននិយាយថា "ខ្ញុំចង់ឲ្យអ្នកឯងស្លាប់ ប៉ុន្តែអ្នកឯងនៅមានជីវិតនៅឡើយ"។ ខ្ញុំបាននិយាយថា វាមិនទាន់ដល់ពេលសម្រាប់ខ្ញុំត្រូវស្លាប់ទេ។

នៅចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ ប្រពន្ធរបស់ខ្ញុំបានធ្វើជាប្រធានក្រុមនៅរោងកិនស្រូវ។ នាងបានរាយការណ៍ទៅគណៈឃុំថា មានប្រជាជនមូលដ្ឋានខ្លះបានចូលមកលួចស្រូវអង្ករពីរោងកិនស្រូវ។ ទោះជាយ៉ាងណាក៏ដោយ គណៈឃុំនោះជាមិត្តចាស់របស់ចោរម្នាក់នៅក្នុងចំណោមចោរផ្សេងៗទៀត។ ដូច្នេះគាត់បានបញ្ជូនប្រពន្ធ និងកូនប្រុសរបស់ខ្ញុំអាយុប្រាំពីរខែឈ្មោះ សំបូរ ចូលទៅក្រុងដើម្បីសម្លាប់។

ខ្ញុំបានសួរប្រធានអង្គភាពម្នាក់ដែលគាត់ស្គាល់ប្រពន្ធ និងកូនប្រុសរបស់ខ្ញុំ។ គាត់ ធ្លាប់រែកទឹកឲ្យគ្រួសារចិនមួយនៅមុនរបបខ្មែរក្រហម។ គាត់មិនចេះអាន និងសរសេរអក្សរទេ ប៉ុន្តែឥឡូវនេះគាត់មានតួនាទីខ្ពស់នៅក្នុងរបបនេះ។ គាត់បានប្រាប់ខ្ញុំថា ប្រពន្ធរបស់ខ្ញុំត្រូវបានវាយសម្លាប់ពីក្រោយរួចរុញចូលក្នុងរណ្តៅសាកសព ខណៈដែលកូនប្រុសរបស់ខ្ញុំត្រូវបានសម្លាប់ដោយបោកផ្ទប់នឹងដើមដូង។ ខ្ញុំបានស្រែកយំខ្លាំងៗ នៅពេលដែលបានដឹងរឿងនេះ។ ខ្ញុំក្លាយទៅជាបុរសពោះម៉ាយ មើលថែរក្សាចិញ្ចឹមកូនបីនាក់។

បន្ទាប់ពីការស្លាប់របស់ប្រពន្ធខ្ញុំ អង្គការចង់ឲ្យខ្ញុំរៀបការជាមួយនារីកម្មាភិបាលខ្មែរក្រហមម្នាក់។ ខ្ញុំបានប្រកែកទោះជាខ្ញុំដឹងថា វាមានគ្រោះថ្នាក់សម្រាប់ខ្ញុំក៏ដោយ។ ខ្ញុំមានការព្រួយបារម្ភថា នាងនឹងសម្លាប់កូនៗរបស់ខ្ញុំ។ ពីរបីថ្ងៃបន្ទាប់មករបបខ្មែរក្រហមត្រូវបានផ្តួលរំលំ។

ខ្ញុំមានមុខជំនួញល្អមួយនៅសៀមរាប។ ខ្ញុំបានរស់នៅទៅទីនោះ ព្រោះចង់ឃើញប្រាសាទអង្គរវត្តមុនពេលខ្ញុំស្លាប់។ ប្រពន្ធទីពីររបស់ខ្ញុំឈ្មោះ ពុធ ម៉ារី។ ប្តីរបស់នាងជានាយទាហានជាន់ខ្ពស់ម្នាក់នៅក្នុងរបប លន់ នល់ ត្រូវបានសម្លាប់ និងកូនរបស់នាងពីរនាក់ទៀតបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ យើងបានចាប់ផ្តើមកសាងគ្រួសារមួយ និងមានកូនប្រាំនាក់។ ឥឡូវនេះខ្ញុំរស់នៅពោរពេញទៅដោយសុខសន្តិភាព។

ប៉ាង ពីច័ន្ទ និង ទេរី ខករហ្គោរៀល

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ឌឿ គីមសៀ ៖ វរសេនីយ៍ទោ

**កូនស្រីរបស់ ឌឿ គីមសៀ ឈ្មោះ ឌឿ សេរីឡែន បានរៀបរាប់ពីរឿងរ៉ាវរបស់ឪពុកប្រាប់ថា៖**



ឌឿ គីមសៀ (នៅខាងឆ្វេង) និងសាច់ញាតិ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឪពុករបស់ខ្ញុំជាបុរសសង្ហាម្នាក់។ បន្ទាប់ពីគាត់បានចាប់ចិត្តស្រឡាញ់ម្តាយរបស់ខ្ញុំឈ្មោះ ម៉ាក់ ង៉ុយ មក គាត់ប្រឹងប្រែងធ្វើការ ផ្គាប់ចិត្តឪពុកម្តាយរបស់ម្តាយខ្ញុំ ដើម្បីឲ្យពួកគាត់យល់ព្រមតាមការស្នើសុំរៀបមង្គលការរបស់គាត់។ បងប្រុសរបស់ឪពុកខ្ញុំបានឃើញម្តាយរបស់ខ្ញុំមុន និងមានចិត្តស្រឡាញ់ម្តាយខ្ញុំដែរ។ យ៉ាងណាក៏ដោយ ពូរបស់ខ្ញុំជាមនុស្សដែលមានសន្តានចិត្តល្អ គាត់យល់ថា ប្រសិនបើអ្នកណាមួយក្នុងចំណោមគាត់ទាំងពីរ បានរៀបការជាមួយម្តាយរបស់ខ្ញុំ ម្តាយរបស់ខ្ញុំនឹងក្លាយជាសាច់ឈាមក្នុងគ្រួសាររបស់គាត់។ ដំបូងឡើយ ម្តាយរបស់ខ្ញុំមិនបានស្រឡាញ់ឪពុករបស់ខ្ញុំទេ ព្រោះអីគាត់តែងតែលេងម្តាយរបស់ខ្ញុំ។ នៅពេលនោះឪពុករបស់ខ្ញុំជាអនុសេនីយ៍ទោ។ ម្តាយរបស់ខ្ញុំមិនចូលចិត្តទាហានទេ ព្រោះអីគាត់គិតថាគាត់ នឹងក្លាយទៅជាស្ត្រីមេម៉ាយប្រសិនបើរៀបការជាមួយទាហាន។

ម្តាយរបស់ខ្ញុំមិនបានសិក្សារៀនសូត្រទេ។ ម្តាយរបស់ម្តាយខ្ញុំមិនចង់ឲ្យគាត់រៀនសូត្រទេ ដោយគិតថាស្ត្រីមិនត្រូវការសាលារៀនឡើយ។ ស្ត្រីទាំងអស់នឹងប្រើប្រាស់ចំណេះដឹងនេះ ដើម្បីសរសេរសំបុត្រទាក់ទងស្នេហាទៅមិត្តប្រុសរបស់ពួកគេ។

បន្ទាប់ពីឪពុកម្តាយរបស់ខ្ញុំរៀបការរួចមក គាត់ទាំងពីរនាក់បានជួលផ្ទះមួយនៅក្រុងភ្នំពេញ។ ក្រោយមក ឪពុករបស់ខ្ញុំបានឡើងឋានន្តរស័ក្តិជាអនុសេនីយ៍ឯក ហើយរដ្ឋាភិបាលបានឲ្យផ្ទះមួយធ្វើពីឥដ្ឋនៅជិតការិយាល័យរបស់គាត់។

ឪពុករបស់ខ្ញុំបានទៅប្រយុទ្ធនៅសមរភូមិជាច្រើន ប៉ុន្តែគាត់មិនដែលរងរបួសធ្ងន់ធ្ងរទេ។ ពេលមួយនោះ មានមនុស្សម្នាក់បានប្រាប់ម្តាយខ្ញុំថា ឪពុករបស់ខ្ញុំមានស្នេហាថ្មីទៀតហើយ គាត់បានយកស្ត្រីនោះទៅសមរភូមិជាមួយ។ ហេតុដូច្នេះ ម្តាយរបស់ខ្ញុំបានសុំការអនុញ្ញាតទៅសមរភូមិមុខជាមួយឪពុកខ្ញុំដែរ ដើម្បីគាត់អាចដឹងថា តើឪពុករបស់ខ្ញុំមានស្នេហាថ្មីទៀតឬយ៉ាងណា។ ម្តាយខ្ញុំបានស្នាក់នៅជាមួយឪពុកខ្ញុំប្រាំមួយខែ ប៉ុន្តែគាត់មិនដែលឃើញស្ត្រីផ្សេងទេ។ នៅពេលណាឪពុកខ្ញុំទៅសមរភូមិ ម្តាយរបស់ខ្ញុំក៏ទៅដែរ។ អ្នកក្រោមបង្គាប់របស់ឪពុកខ្ញុំពីរបីនាក់ បានការពារម្តាយខ្ញុំរាល់លើក។ ពេលមួយនោះ នៅក្នុងសមរភូមិប្រយុទ្ធ ម្តាយរបស់ខ្ញុំបានដួល ទាហានច្រើននាក់បានជាន់សង្កត់គាត់បាក់ឆ្អឹងត្រគាក។ គាត់ទាំងពីរនាក់បានឡើងយន្តហោះដើងទីមួយត្រឡប់មកផ្ទះវិញ។ ពេលមកដល់ផ្ទះ ម្តាយរបស់ខ្ញុំស្លៀកពាក់ឯកសណ្ឋានយោធាដែលមានស្នាមប្រឡាក់ឈាម។ ចាប់តាំងពីពេលនោះមក គាត់មិនអាចដើរត្រង់បានទេ។

ក្រោយមក ឪពុករបស់ខ្ញុំត្រូវបញ្ជូនទៅបណ្តុះបណ្តាលនៅប្រទេសវៀតណាម។ ពេលគាត់ត្រឡប់មកវិញ គាត់ បានធ្វើការនៅការិយាល័យគណនេយ្យមួយនៅក្នុងទីក្រុង។ ពេលនោះយើងរស់នៅក្នុងស្ថានភាពហ៊ឹហា ដោយគ្រួសាររបស់យើងមានរថយន្តមែរសីដែសមួយគ្រឿង រថយន្តហាំប៊ើស្ព័រមួយគ្រឿង រថយន្តអូស្តាំងមួយគ្រឿង និងរថយន្តមួយគ្រឿងទៀតរដ្ឋាភិបាលបានឲ្យឪពុកខ្ញុំប្រើប្រាស់។ យើងមានអ្នកបំរើច្រើននាក់ អ្នកបើកបរច្រើននាក់ដែលបើកបរជូនក្មេងៗ៩នាក់នៅក្នុងគ្រួសាររបស់យើង ទៅទីណាដែលយើងចង់ទៅ។

នៅពេលដែលបងៗស្រីរបស់ខ្ញុំនិងខ្ញុំកំពុងរៀបចំពិធីចូលឆ្នាំថ្មីឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំមានការព្រួយបារម្ភជាខ្លាំង គាត់បានសុំឪពុករបស់ខ្ញុំឲ្យគ្រួសារយើងចាកចេញពីប្រទេស។ ឪពុកមាររបស់ខ្ញុំធ្វើការនៅស្ថានទូតជប៉ុនបានផ្ញើទូរសារមកឪពុកខ្ញុំ ដោយបានប្រាប់ថាយើងត្រូវតែចាកចេញពីប្រទេសកម្ពុជាឆាប់ៗនេះបើអាច ព្រោះអីប្រទេសកម្ពុជានឹងអនុវត្តលទ្ធិកុម្មុយនីស្តក្នុងពេលឆាប់ៗនេះ។ ប៉ុន្តែឪពុករបស់ខ្ញុំ ដែលធ្លាប់បានធ្វើដំណើរទៅប្រទេសផ្សេងៗ និងបានឃើញអ្វីៗដែលគេចូលចិត្ត បាននិយាយថា "មិនមានប្រទេសណាដែលងាយស្រួលរស់នៅជាងប្រទេសកម្ពុជាឡើយ។ ប្រសិនបើអ្នកចង់ចេញទៅក្រៅប្រទេស អ្នកត្រូវតែរៀបការជាមួយប្តីបរទេស"។

នៅថ្ងៃ១៧ មេសា គ្រួសាររបស់យើងនិងមិត្តភក្តិទាំងអស់មានចំនួន ២៥ នាក់បានធ្វើដំណើរទៅខេត្តកណ្តាល។ នៅតាមផ្លូវយើងជាក្មេងៗមានសេចក្តីស្រេកឃ្លាន និងស្រែកយំ ព្រោះអីម្តាយរបស់ខ្ញុំមិនបានយកស្បៀងអាហារមកជាមួយច្រើនទេ។ ជីដូនរបស់ខ្ញុំបានចាកចេញពីរថយន្តទៅសុំអង្ករ ប៉ុន្តែមានហ្វូងមនុស្សណែនណាន់តាន់តាប់ដែលធ្វើឲ្យគាត់វង្វេងបាត់។ យើងមិនបានឃើញគាត់ទៀតឡើយ។ ឪពុករបស់ខ្ញុំខឹងខ្លាំងណាស់ ហើយបានប្រាប់យើងឲ្យនៅកៀកគ្នាពីម្នាក់ទៅម្នាក់ និងមិនឲ្យចាកចេញពីរថយន្ត ទោះបីជាយើងមានសេចក្តីស្រេកឃ្លានយ៉ាងណាក៏ដោយ។ យើងបានរុញរថយន្តបីគ្រឿងរបស់យើងចេញពីទីនោះ។ យោធាខ្មែរក្រហមបានត្រួតពិនិត្យរថយន្តរបស់យើង និងចំអកឲ្យយើង ព្រោះអីគេមិនបានរកឃើញអ្វីសោះ ក្រៅពីឆ្នាំងដាំបាយពីរ និងកំសៀវដាំទឹកមួយ។

ម្តាយរបស់ខ្ញុំខឹងឪពុកខ្ញុំ ព្រោះឪពុកខ្ញុំមិនស្តាប់គាត់។ ម្តាយខ្ញុំមិនបាននិយាយអ្វីឡើយ គាត់គិតតែពីយំ។ ឪពុកខ្ញុំបាននិយាយលួងលោមម្តាយខ្ញុំថា "សង្គមបដិវត្តន៍មិនសម្លាប់ជាតិខ្លួនទេ នៅទីបំផុតវានឹងមានភាពស្មើគ្នារវាងអ្នកមាននិងអ្នកក្រ។ យើងមានរថយន្តពីរបីគ្រឿង អង្គការ និងចាត់ចែងរបស់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់យើងដាច់



ឌឿ សេរីឡែន នៅកណ្តាល (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឌឿ សេរីឡេន (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឌឿ សេរីឡេន (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយឡែក និងទុកឲ្យយើងតែផ្ទះមួយ និងរថយន្តមួយគ្រឿងប៉ុណ្ណោះ។

ឪពុករបស់ខ្ញុំបាននិយាយថា យើងត្រូវតែធ្វើដំណើរនៅឲ្យជិតប្រភពទឹក ព្រោះមានទឹកផឹកគ្រប់គ្រាន់ប្រសើរជាងអត់បាយ។ យើងឈប់សំចតនៅវត្តមួយ ព្រោះអីយើងមិនមានទឹកផ្ទៃផ្ទាល់ខ្លួនដែលត្រូវទៅទេ។ យើងបានរង់ចាំស្តាប់ដំណឹង នៅពេលណាយើងអាចត្រឡប់ទៅភ្នំពេញវិញ។ ឪពុករបស់ខ្ញុំបានជួយលីសែងអង្ករ និងបាវថ្នាំជក់ឲ្យអ្នកផ្សេងទៀត ដើម្បីដោះដូរយកស្បៀងអាហារ។ គាត់បានប្រាប់គេថា គាត់ជាគ្រូបង្ហាត់បាល់ទះ។

ថ្ងៃមួយគណៈភូមិបាននិយាយជាមួយមិត្តភក្តិរបស់ឪពុកខ្ញុំដែលមកជាមួយយើងពីភ្នំពេញ។ គណៈភូមិបានប្រាប់ថា ប្រសិនបើឪពុកខ្ញុំជាអ្នកជំនួញគាត់ជាថៅកែធំ ប្រសិនបើឪពុកខ្ញុំធ្វើការឲ្យរដ្ឋាភិបាល គាត់យ៉ាងហោចណាស់ជាវរសេនីយ៍ទោ។ មិត្តភក្តិរបស់ឪពុកខ្ញុំបានឆ្លើយថា "បងប្រុស បងឯងវិនិច្ឆ័យប្រជាជនល្អណាស់។ គាត់ជាវរសេនីយ៍ទោ!"។ បងស្រីរបស់ខ្ញុំបានស្តាប់ឮពួកគេនិយាយ រួចរត់ទៅប្រាប់ឪពុកម្តាយរបស់ខ្ញុំ។ ម្តាយរបស់ខ្ញុំ ភ័យតក់ស្លុតជាខ្លាំង ហើយបានអង្វរឪពុកខ្ញុំឲ្យជិះទូកទៅប្រទេសវៀតណាម។ ប៉ុន្តែឪពុកខ្ញុំបានបដិសេធ និងបាននិយាយថា អង្គការប្រហែលជាគ្រាន់តែយកគាត់ទៅរៀនសូត្រសារឡើងវិញប៉ុណ្ណោះ។

ពីរបីថ្ងៃបន្ទាប់មក កម្មាភិបាលបានចាប់ឪពុកខ្ញុំយកទៅ និងសួរចម្លើយគាត់ពេញមួយយប់។ នៅពេលដែលគាត់ត្រឡប់មកវិញ គាត់បានប្រាប់ម្តាយខ្ញុំថា គេបានសួរគាត់តែមួយសំនួរអំពីការងាររបស់គាត់កាលពីមុន។ ឪពុកខ្ញុំមានការធុញថប់ទៅនឹងសំនួរជាច្រើនរបស់កម្មាភិបាលខ្មែរក្រហម ហើយបាននិយាយប្រាប់ថា "តើវាមានបញ្ហាអីដល់អ្នក បើខ្ញុំជាវរសេនីយ៍ឯក ឬជាគ្រូបង្ហាត់បាល់ទះ?"។ ជាថ្មីម្តងទៀត ម្តាយរបស់ខ្ញុំបានអង្វរគាត់ឲ្យចាកចេញពីប្រទេស ឪពុកខ្ញុំបានបដិសេធទៀត។ គាត់មានការជឿជាក់នូវអ្វីដែលខ្មែរក្រហមបាននិយាយប្រាប់គាត់ឲ្យរង់ចាំត្រឡប់ទៅភ្នំពេញ និងបន្តធ្វើការងារចាស់របស់គាត់វិញ។ ឪពុកខ្ញុំបាននិយាយថា "មិនមានអ្នកណាសម្លាប់ជនជាតិខ្លួនឯងទេ យ៉ាងច្រើនយកទៅរៀនសូត្រ"។

មួយខែក្រោយមក ខ្មែរក្រហមបាននាំឪពុកខ្ញុំចេញទៅរៀនសូត្រ។ ម្តាយរបស់ខ្ញុំបានឲ្យចិញ្ចៀនរបស់គាត់ទៅគណៈភូមិ ដើម្បីសុំការអនុញ្ញាតពីគាត់ឲ្យបងប្រុសខ្ញុំទៅសួរសុខទុក្ខឪពុកខ្ញុំ។ នៅពេលដែលបងប្រុសខ្ញុំត្រឡប់មកវិញ គាត់បានប្រាប់ម្តាយខ្ញុំថា ឪពុកយើងនៅក្នុងមន្ទីរស្រុកជាមួយប្រជាជន៥០នាក់ផ្សេងទៀត មានគ្រូបង្រៀន វេជ្ជបណ្ឌិត មន្ត្រីរដ្ឋការជាន់ខ្ពស់។ នៅពេលដឹងដូច្នេះ ម្តាយខ្ញុំបានធូរស្រាលបន្តិច។ បងប្រុសរបស់ខ្ញុំបានសុំម្តាយខ្ញុំ វិលត្រឡប់ទៅមន្ទីរស្រុកជាមួយឪពុករបស់យើង។ បន្ទាប់មកអ្នកទាំងពីរបានបាត់ខ្លួន។ ក្រោយមកយើងបានដឹងថា អង្គការបានប្រឡំឪពុកខ្ញុំទៅនឹងបងប្រុសរបស់គាត់ឈ្មោះ ឌឿ គឹមសាន ដែលជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសជប៉ុន។

បីអាទិត្យក្រោយមក យោធាខ្មែរក្រហមបានមកជាមួយទូកបួនគ្រឿង ហើយបានប្រកាសថា ខ្លួនមកយកប្រជាជនត្រឡប់ទៅទីក្រុងវិញ។ ម្តាយខ្ញុំបានសម្រេចចិត្តថា យើងគួរតែទៅ និងផ្តាំផ្ញើអ្នកស្រុកថា ប្រសិនបើឪពុក និងបងប្រុសរបស់ខ្ញុំត្រឡប់មកវិញ សូមប្រាប់ពួកគាត់ថាយើងនៅក្រុងភ្នំពេញ។ ប៉ុន្តែ ជំនួសឲ្យការធ្វើដំណើរទៅទីក្រុងភ្នំពេញ ទូកបានឈប់សំចតនៅកំពង់ឆ្នាំង។ មានរថយន្តច្រើនគ្រឿង និងរទេះភ្លើងបានដឹកជញ្ជូនយើងទៅខេត្តបាត់ដំបង។

បងប្អូនប្រុសស្រីរបស់ខ្ញុំ ត្រូវបានបញ្ជូនទៅអង្គភាពការងារ។ ដោយសារខ្ញុំនៅក្មេងជាងគេក្នុងចំណោមកូនៗទាំងប្រាំបួននាក់នៅក្នុងគ្រួសារ ខ្ញុំបានធ្វើការនៅវាលស្រែក្បែរភូមិ និងបានរៀនមនោគមន៍វិជ្ជារបស់ខ្មែរក្រហមជាមួយក្មេងៗដទៃទៀត។ ខ្មែរក្រហមបានបង្រៀនថា យើងត្រូវចាត់ទុកថាអង្គការជាឪពុកម្តាយរបស់យើង ហើយឪពុកម្តាយបង្កើតរបស់យើងជាសត្រូវ។ អង្គការបានប្រាប់យើងឲ្យយកព័ត៌មានពីគ្រួសាររបស់យើង។ ក្មេងៗខ្លះ បានរាយការណ៍ប្រាប់ខ្មែរក្រហមអំពីគ្រួសាររបស់ខ្លួន។ គ្រួសារទាំងនោះត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រ ឬសម្លាប់ចោល។ ខ្ញុំមិនដែលប្រាប់អង្គការពីម្តាយរបស់ខ្ញុំទេ។

បងស្រីរបស់ខ្ញុំម្នាក់មានរូបរាងស្គមស្គាំងដោយសារជំងឺរាកមួល។ មុនពេលគាត់ស្លាប់ គាត់បាននិយាយខ្សឹបៗថា នាងចង់ហូបពងទាលាយជាមួយបន្លែម្រះណាស់។ បងប្អូនប្រុសៗប្រាំនាក់របស់ខ្ញុំបានស្លាប់នៅក្នុងខែតែមួយ នៅចុងឆ្នាំ១៩៧៧។ ប្អូនប្រុសម្នាក់បានបញ្ជូនត្រឡប់មកវិញ ជើងរបស់វាត្រូវបានកាត់បន្ទាប់មកវាក៏ស្លាប់បាត់ទៅ។ បងប្អូនប្រុសផ្សេងទៀតមានដំបៅក្បាល និងស្លាប់ដោយសារអត់បាយ។ ទោះបីជាទៅមន្ទីរពេទ្យក៏ដោយ ការព្យាបាលបានត្រឹមតែលេបថ្នាំគ្រាប់អាចម៍ទន្សាយប៉ុណ្ណោះ។ បេះដូងម្តាយរបស់ខ្ញុំត្រូវខ្ទេចខ្ទាំ គ្រាំគ្រានៅពេលបាត់បង់កូនជាច្រើននាក់។ ប្រសិនបើខ្ញុំមិនបាននៅក្បែរគាត់ទេ ម្តាយខ្ញុំនឹងវង្វេងស្មារតីបាត់ទៅហើយ។

ថ្ងៃមួយនោះ ម្តាយរបស់ខ្ញុំបានយកគ្រឿងអលង្ការ ដូរជាសាច់មាន់។ គាត់បានចែករំលែកសាច់ខ្លះឲ្យទៅអ្នកផ្សេងនៅក្នុងផ្ទះ និងទុកភ្លៅមាន់សម្រាប់ខ្ញុំ និងខ្លួនគាត់។ នៅពេលដែលខ្ញុំហូបមិនឆ្អែត ខ្ញុំចាប់ផ្តើមឈ្លោះជាមួយគាត់ ម្តាយខ្ញុំបានក្តិចមួលទាល់តែខ្ញុំស្រែកយំ។ អ្នកស៊ើបការណ៍ប្រចាំភូមិបានឮខ្ញុំស្រែកយំ ហើយគេបាននាំម្តាយខ្ញុំចូលទៅក្នុងព្រៃ។ អ្នកទាំងអស់គ្នានៅក្នុងផ្ទះបានបន្ទោសខ្ញុំ និងនិយាយថាខ្ញុំបានបង្កហេតុឲ្យគាត់ស្លាប់។ ខ្ញុំមានការភ័យខ្លាចជាខ្លាំង ហើយរត់ចេញទៅរកម្តាយខ្ញុំ ប៉ុន្តែមិនខ្ញុំមិនបានឃើញគាត់ឡើយ។ ខ្ញុំបានស្រែកយំរហូតដល់ដេកលក់។ នៅពេលដែលខ្ញុំភ្ញាក់ឡើង ម្តាយខ្ញុំបានយំនិងអោបខ្ញុំ។ ខ្ញុំរំភើបចិត្តយ៉ាងខ្លាំង និងមានអារម្មណ៍ថាខ្ញុំបានកើតម្តងទៀត។

នៅពេលម្តាយរបស់ខ្ញុំមិនអាចទ្រាំទ្រភាពអត់ឃ្លាននៅក្នុងភូមិតទៅទៀត គាត់បានប្រាប់ខ្ញុំឲ្យរត់ចេញទៅជាមួយក្មេងមូលដ្ឋានម្នាក់ឈ្មោះ គួរ។ យើងបានវង្វេងនៅក្នុងព្រៃពីរថ្ងៃ និងហូបតែអ្វីដែលយើងអាចរកបាន។ នៅពេលយប់នោះ ខ្ញុំបានឡើងដើមឈើមួយ ហើយបានឃើញពន្លឺភ្លើងសំដៅមករកយើង ខ្ញុំគិតថាជាខ្មោចលង។ ប៉ុន្តែវាជាភ្លើងចន្លុះចេញពីរទេះគោមួយដែលបានបរដោយគណៈភូមិល្បាក់ព្រៃ។ គាត់មានសន្តានចិត្តល្អបាននាំ គួរ និងខ្ញុំត្រឡប់ទៅរស់នៅជាមួយគ្រួសាររបស់គាត់។ ប្អូនប្រុសរបស់គ្រួសារគាត់បានទុកខ្ញុំជាកូនចិញ្ចឹម។ គាត់ស្រឡាញ់ខ្ញុំ និងឲ្យអាហារខ្ញុំហូបជាច្រើន ។

នៅថ្ងៃរំដោះក្នុងឆ្នាំ១៩៧៩ ខ្ញុំចង់ទៅរកម្តាយខ្ញុំ ប៉ុន្តែមិនដឹងថាគាត់នៅទីណា។ ថ្ងៃមួយនោះ ខ្ញុំបានឮមនុស្សម្នាក់ហៅឈ្មោះខ្ញុំ។ គណៈភូមិបានប្រាប់ខ្ញុំថាម្តាយរបស់ខ្ញុំបានមករកខ្ញុំ។ ខ្ញុំមានការភ័យតក់ស្លុត ព្រោះអីខ្ញុំបានឮគេថា ម្តាយរបស់ខ្ញុំបានស្លាប់ហើយ។ ខ្ញុំភ័យខ្លាច ព្រោះខ្ញុំជាប្រជាជន១៧មេសាម្នាក់ នឹងត្រូវសម្លាប់។ ប៉ុន្តែសម្លេងនោះជាសម្លេងរបស់ម្តាយខ្ញុំ គាត់បានមកសុំខ្ញុំត្រឡប់ទៅភ្នំពេញវិញជាមួយគាត់។ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងណាទេ។ អ្នកនៅក្នុងគ្រួសារដែលបានចិញ្ចឹមខ្ញុំនោះ មិនចង់ឲ្យខ្ញុំចាកចេញទេ។ ខ្ញុំមានការភ័យខ្លាចខ្មែរក្រហមនឹងធ្វើអ្វីចំពោះខ្ញុំប្រសិនបើខ្ញុំចាកចេញ។ ខ្ញុំបានហូបគ្រប់គ្រាន់នៅក្នុងភូមិនេះ។ ប៉ុន្តែម្តាយរបស់ខ្ញុំបាននិយាយប្រាប់គេថា គាត់បានបាត់បង់កូនរបស់គាត់ទាំងអស់ លើកលែងតែខ្ញុំម្នាក់។ គ្រួសារចិញ្ចឹមខ្ញុំបានយល់ព្រមនឹងឲ្យខ្ញុំទៅផ្ទះជាមួយម្តាយខ្ញុំវិញ។

ការចងចាំរបស់ខ្ញុំអំពីរបបខ្មែរក្រហម បានដកជាប់នឹងខ្ញុំរាល់ថ្ងៃ វាជាស្រមោលដ៏អាក្រក់មួយ។

**ប៊ាង ពីរ័ន្ត និង ខេនី ខកហ្គៀល**

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# យស់ ព្រឹម ៖ វរសេនីយ៍ឯក

**ឈ្មោះ ចាប ស៊ីថា ត្រូវជាប្រពន្ធរបស់ យស់ ព្រឹម បាននិយាយរៀបរាប់ប្រាប់ថា៖**



យស់ ព្រឹម ថតឆ្នាំ១៩៧២ នៅភ្នំពេញ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*ដំបូងឡើយប្តីរបស់ខ្ញុំឈ្មោះ យស់ ព្រឹម បានឃើញខ្ញុំនៅឆ្នាំ ១៩៥២ ហើយ បានស្នើសុំឪពុកម្តាយរបស់ខ្ញុំរៀបការជាមួយខ្ញុំ។ បន្ទាប់ពីគាត់បានបញ្ចប់វិទ្យាល័យ គាត់បានចូលរៀនសាលាបណ្ឌិតសភាយោធា និងបានតម្លើងឋានន្តរស័ក្តិជាលំដាប់។ គាត់ជាវរសេនីយ៍ឯក នៅក្នុងរបប លន់ នល់ នាឆ្នាំ១៩៧០។ មុនឆ្នាំ១៩៧៥ ខ្ញុំយល់ឃើញថា ប្រទេសរបស់ខ្ញុំវាអស្ថេរភាពយ៉ាងខ្លាំង ហើយខ្ញុំបានសួរ ព្រឹម ថា តើវាជាគំនិតល្អទេ បើយើងត្រូវភៀសខ្លួនទៅប្រទេសថៃមួយរយៈ។ គាត់ឆ្លើយថា ទេ គាត់ជាអ្នកស្នេហាជាតិម្នាក់ ប្រសិនបើគាត់ចាកចេញទៅ គាត់មានអារម្មណ៍ថា ក្បត់ប្រទេសរបស់គាត់។ ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា ខ្ញុំអាចទៅម្នាក់ឯងបាន។ ខ្ញុំមិនអាចចាកចោលគាត់បានទេ ដូច្នេះខ្ញុំបានសម្រេចចិត្តស្នាក់នៅក្នុងក្រុងភ្នំពេញជាមួយគាត់និងកូនៗរបស់យើងទាំងប្រាំបីនាក់។*

*នៅឆ្នាំ១៩៧៥ យើងត្រូវបានជម្លៀសទៅខេត្តកណ្តាល។ ខ្ញុំចង់ធ្វើដំណើរទៅស្រុកកំណើតរបស់ប្តីខ្ញុំនៅក្នុងខេត្តស្វាយរៀង ប៉ុន្តែមានប្រជាជនច្រើនពេកកំពុងធ្វើដំណើរតាមទិសដៅនោះ។ នៅពេលដែលអង្គការសួរអំពីជីវប្រវត្តិរបស់យើង ខ្ញុំបានកុហកនិងប្រាប់ថា ប្តីរបស់ខ្ញុំជាអ្នកលក់ដូរ។ អង្គការបានឲ្យយើងដាំបន្លែ និងធ្វើស្រែ។ រាល់ព្រឹកខ្ញុំបានរែកទឹក៨០ធុងស្រោចដំណាំ។ ព្រឹម ធ្វើស្រែ លើកទំនប់និងរែកដី ខណៈដែលកូនៗរបស់យើងត្រូវបញ្ចូលក្នុងកងចល័ត។*

*នៅវេលាយប់មួយម៉ោង៩ កម្មាភិបាលខ្មែរក្រហមបាននិយាយថា ប្តីរបស់ខ្ញុំត្រូវទៅរៀនសូត្រ និងសន្យាថាគាត់នឹងត្រឡប់មកវិញបន្ទាប់ពីរៀនចប់។ កម្មាភិបាលដែលយកប្តីខ្ញុំទៅនោះឈ្មោះ ខា ឡុក បាននិយាយថា "កុំបារម្ភអី អង្គការចង់ជួបគាត់នៅផ្ទះរបស់ស្ត្រីចំណាស់ម្នាក់ឈ្មោះ ភី ។ វាមិនយូរទេ"។ ខ្ញុំបានរង់ចាំ ព្រឹម ប៉ុន្តែគាត់មិនត្រឡប់មកវិញឡើយ។ បន្ទាប់មក ភី និយាយថា "កុំរង់ចាំគាត់អី។ សូមប្រយ័ត្នប្រយែងនៅពេលដែលអ្នកនិយាយស្តី បើមិនអញ្ចឹងទេគ្រួសាររបស់អ្នកនឹងត្រូវបញ្ជូនទៅសម្លាប់។ ខ្ញុំប្រាប់អ្នកឯងដូច្នេះ ពីព្រោះអីប្តីរបស់អ្នកមានជីវប្រវត្តិមិនល្អ"។*

*ពីរខែក្រោយមក អង្គការបានស្នើខ្ញុំនិងគ្រួសាររបស់ខ្ញុំផ្លាស់ទីលំនៅទៅទីក្រុងភ្នំពេញ។ ប៉ុន្តែអង្គការបានដាក់យើងក្នុងរទេះភ្លើងទៅខេត្តបាត់ដំបងវិញ និងឲ្យយើងរស់នៅក្នុងខុមរយោគមួយ។ បន្ទាប់មកអង្គការបានចាប់ផ្តើមបំបែកគ្រួសាររបស់ខ្ញុំ។ កូនស្រីរបស់ខ្ញុំអាយុ៦ឆ្នាំ តែមួយគត់អាចរស់នៅជាមួយខ្ញុំ។ កូនៗរបស់ខ្ញុំផ្សេងទៀតត្រូវបានបញ្ជូនទៅលើកទំនប់ និងជីកស្រះនៅឆ្ងាយពីផ្ទះ ៤០ គីឡូម៉ែត្រ។*

*កូនប្រុសរបស់ខ្ញុំអាយុ១៧ឆ្នាំ បានស្លាប់ដោយសារជំងឺនិងការអត់ឃ្លាន។ វាសម្រាកក្នុងមន្ទីរពេទ្យតែម្នាក់ឯងមុនពេលខ្ញុំទៅដល់មើលថែទាំវា។ វាបានស្លាប់នៅយប់បន្ទាប់ ក្រោយពីខ្ញុំទៅដល់។ វាបាននិយាយថា "ម៉ាក់ ខ្ញុំឃ្លានខ្លាំងណាស់។ ជីវិតរបស់ខ្ញុំពេលនេះវាពិបាកខ្លាំងជាងសត្វធាតុទៅទៀត។ ខ្ញុំចង់ស្លាប់ ហើយនិងអាចកើតម្តងទៀត។ ជីវិតអីក៏វេទនាម្ល៉េះ?" បន្ទាប់មកកូនប្រុសរបស់ខ្ញុំបួននាក់ និងកូនស្រីច្បងបានស្លាប់។ កូនខ្ញុំស្លាប់បន្តគ្នាក្នុងរយៈពេលពីបួនទៅដប់ថ្ងៃ។ កូនខ្លះស្លាប់ដោយសារជំងឺកូនខ្លះទៀតត្រូវបានគេសម្លាប់។ កូនស្រីច្បងបង្អស់របស់ខ្ញុំបានរៀបការជាមួយចៅហ្វាយខេត្ត។ អង្គការបានយកនាងជាមួយប្តី និងកូនៗពីរនាក់ទៀតចេញទៅ។ ចាប់ពីពេលនោះមក យើងមិនដែលឃើញពួកគេឡើយ។*

*បន្ទាប់ពីនោះមក ស៊ុម គណៈភូមិបានបង្គាប់ខ្ញុំឲ្យប្រគល់ទ្រព្យសម្បត្តិដែលកម្មសិទ្ធិទាំងអស់របស់ខ្ញុំ។ គាត់និយាយថា ខ្ញុំមិនមែនជាពលរដ្ឋកម្ពុជាសាមញ្ញទេ។ យ៉ាងហោចណាស់ ខ្ញុំជាអ្នកដែលមានឋានៈខ្ពស់ និងមានងារជា "លោកស្រី" ឬ "លោកជំទាវ"។ ខ្ញុំប្រហែលជាភរិយារបស់អ្នកជំនួញ ហើយខ្ញុំពិតណាស់ជាចៅហ្វាយស្រី។ ស៊ុម បានបញ្ជាខ្ញុំឲ្យយកលាមកចេញពីបង្គន់។ វាគួរឲ្យខ្ពើមរអើមណាស់ ដែលពេលខ្លះធ្វើឲ្យខ្ញុំវិលមុខខ្យល់ចាប់។ ប្រជាជនថ្មីតែងតែជួយខ្ញុំ នៅពេលដែលហេតុការណ៍នេះបានកើតឡើង។ អ្នកទាំងនោះបាននិយាយថាកម្មាភិបាលឲ្យខ្ញុំធ្វើការងារនេះ ដោយសង្ឃឹមថាខ្ញុំនឹងឆាប់ស្លាប់។*

*នៅពេលដែលវៀតណាមបានចូលមកប្រទេសកម្ពុជានៅឆ្នាំ ១៩៧៩ ខ្ញុំបានសម្រេចចិត្តដើរត្រឡប់ទៅភ្នំពេញវិញជាមួយកូនៗ។ ទៅដល់ទីក្រុង ខ្ញុំបានរស់នៅជាមួយសាច់ញាតិ និងខិតខំធ្វើការទាំងថ្ងៃទាំងយប់ ដូច្នេះហើយកូនៗរបស់ខ្ញុំបានរៀនសូត្រ។ គ្មានអ្វីសំខាន់ជាងទទួលបានការរៀនសូត្រឡើយ។*

*ខ្ញុំមានសំណាងណាស់ដែលនៅសល់សមាជិកគ្រួសារខ្លះបន្ទាប់ពីឆ្នាំ១៩៧៩។ នៅទីបញ្ចប់របស់របបខ្មែរក្រហម ខ្ញុំបាត់បង់ប្តី បាត់បង់កូនប្រុសបួននាក់ កូនស្រីម្នាក់ ចៅពីរនាក់ និងម្តាយក្មេករបស់ខ្ញុំដែលខ្ញុំស្រឡាញ់ដូចជាម្តាយបង្កើតរបស់ខ្ញុំអ៊ីចឹង។ សាច់ញាតិរបស់ខ្ញុំម្នាក់បានទៅទស្សនាគុកទួលស្លែង គាត់បានឃើញឈ្មោះប្តីរបស់ខ្ញុំនៅក្នុងបញ្ជីនៅទីនោះ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់បានប្រាប់ខ្ញុំថា អ្នកទោសទួលស្លែងជាច្រើន ត្រូវបានបញ្ជូនទៅសម្លាប់នៅបឹងជើងឯក។ រៀងរាល់ថ្ងៃបុណ្យសាសនាខ្ញុំបានយកម្ហូបចំណីទៅវាលពិឃាត និងបានឧទ្ទិសបុណ្យកុសលទៅឲ្យប្តីរបស់ខ្ញុំ។*

**ប៉ាំង ពីច័ន្ទ និង ទេរី ខករហ្គៀល**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់
## នៅក្នុងរបបខ្មែរក្រហម ចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

***ម៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី***

(តពីលេខមុន)

***ដាំ អេង*** ហៅ ម៉េង លី មានអាយុ៣៩ឆ្នាំ ក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ ដាំ សាវ និង ជី ហៀកហួយ មានប្រពន្ធឈ្មោះ លឹម លៀងស៊ីម មានកូនប្រុស ២នាក់និងស្រី ៥នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅចំបក់ ខេត្តតាកែវ។ ខ្មែរក្រហមចាប់បញ្ជូន ដាំ អេង ឬ ដាំ ម៉េង ឬ ដាំ ម៉េងលី ហៅ អេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៥ ថ្ងៃ។

***ដាំ ម៉ាន់ភួរ*** មានអាយុ៤៤ឆ្នាំ ក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ ដាំង វ៉ាន់យិន និង ហិញ ធីញូង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកោះរ៉ៃ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

***ដុក យឿន*** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ដុក យឿន ទៅដល់គុកទួលស្លែង នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោល នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១៣ ថ្ងៃ។

***ដុំ ហៀម*** ហៅ ស្រ៊ាន់ មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅចំការលើ ខេត្តកំពង់ចាម ជាកូនរបស់ ពត ដុំ និង លឹម ហែ មានប្តីឈ្មោះ អ៊ុន សឿន ហៅ វ៉ាន់ មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៤។ ខ្មែរក្រហមសម្លាប់ ដុំ ហៀម នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៨ ថ្ងៃ។

***ដូ ហ្វេ*** មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញ ឪពុកម្តាយឈ្មោះ ដូ កាំ និង វ៉ាង ហ៊ុង យាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញ ត-១ ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ដូ ហ្វេ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

***ដួង ធី*** មានអាយុ២៩ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទឹកផុស ខេត្តកំពង់ឆ្នាំង ជាកូនរបស់ ដួង ទូ និង សយ មានប្រពន្ធឈ្មោះ ទិត យុត មានកូនស្រី ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅវត្តកោគជាន់ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ០២ បន្ទប់តូច ១០ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង មាន២ខុសគ្នា មួយនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៥ និងមួយទៀតនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦។

***ដួង ស្រេង*** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៥០២ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ដួង ស្រេង នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦។

***ដួង ញ៉*** ហៅ ធី មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ ដួង អាម និង អោក ជេន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់ធំ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ដួង ញ៉ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៨១ ថ្ងៃ។

***ដួង ជី*** ហៅ ជីវ មានអាយុ៣៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅក្រឡាញ់ ខេត្តសៀមរាប ជាកូនរបស់ ដួង អឿន និង នឹម អែម មានប្រពន្ធឈ្មោះ ឡៅ គឹមសុខ មានកូនប្រុស១នាក់ (ស្លាប់) ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកភ្នំស្រុក ថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់ធំ ១៤។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

***ដួង ជាវុធ*** មានអាយុ៣៩ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបាកាន ខេត្តពោធិ៍សាត់ ជាកូនរបស់ ដួង ឃិន និង ម៉ម សាត មានប្រពន្ធឈ្មោះ និល វ៉ាន់ស៊ី មានកូនប្រុស ២នាក់ និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងខែសីហា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៤ បន្ទប់ធំ ៤ បន្ទប់តូច ៤។ ខ្មែរក្រហមចាប់បញ្ជូន ដួង ជាវុធ ទៅដល់គុកទួលស្លែងនៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១២៥ ថ្ងៃ។

***ដួង នួន*** មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១៥៤ (ស្រុកកណ្តាលស្ទឹង) ខេត្តកណ្តាល ជាកូនរបស់ ដួង នៅ និង ពិន ស្តើង មានប្រពន្ធឈ្មោះ ខ្ចីង ឡាយ មានកូនប្រុស ១នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រែកហូរ ថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០២ បន្ទប់ធំ ៩។ ខ្មែរក្រហមចាប់បញ្ជូន ដួង នួន ទៅដល់គុកទួលស្លែងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦។

***ដួង ផាន*** មានអាយុ២១ឆ្នាំ ក្នុងឆ្នាំ១៩៧(៥) មានស្រុកកំណើតនៅសន្ទុក ខេត្តកំពង់ធំ ជាកូនរបស់ ជុត និង ហ៊ីប ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកជើងព្រៃ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧(៥) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៥ បន្ទប់ធំ ១១។ ខ្មែរក្រហមចាប់បញ្ជូន ដួង ផាន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៦ ឬ ១៧ ខែមីនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

***ដួង ម៉ុន*** មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅមេសាង ខេត្តព្រៃវែង ជាកូនរបស់ ដួង គង់ និង ភួង អ៊ុំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ១៧០ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់បញ្ជូន ដួង ម៉ុន ទៅដល់គុកទួលស្លែង នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ និងសម្លាប់នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥៨ ថ្ងៃ។

***ដួង វ៉ន*** មានអាយុ៣៨ឆ្នាំ ក្នុងឆ្នាំ១៩៧(៦) មានស្រុកកំណើតនៅមេសាង ខេត្តព្រៃវែង ជាកូនរបស់ ទង យិន និង វ៉ាន់ រស់ មានប្រពន្ធឈ្មោះ ម៉ៅ ប្រុក ហៅ សឿន មានកូនប្រុស ១នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកមេសា ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧(៦)។ ខ្មែរក្រហមសម្លាប់ ដួង វ៉ន នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។

***ដួង សាខន*** មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧(៦) មានស្រុកកំណើតនៅទួលគោក ខេត្តកណ្តាល ជាកូនរបស់ ដួង សុក និង ហែម យាប់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនស្រុកស្រែអំបិល ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧(៦) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ៨ បន្ទប់តូច ៧។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង មាន២ខុសគ្នា មួយនៅថ្ងៃទី២៤ និងមួយទៀតនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ដួថ សាខន នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៦។

***ដួង សាម*** មានអាយុ៣០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅអង្គស្នួល ខេត្តកណ្តាល ជាកូនរបស់ ដួង សុក និង ម៉ា ជាត់ មានប្រពន្ធឈ្មោះ ចំរើន ហៅ ធីម មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបន្ទីរយោធា តំបន់១៥ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ៧។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន៣ខុសគ្នា មួយនៅថ្ងៃទី១, នៅថ្ងៃទី៤ និងមួយទៀតនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៦។

ខ្មែរក្រហមសម្លាប់ ដួង សាម នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

**ដួង សុខសាន** អាយុ៣៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ អតីតវិស្វករ មានស្រុកកំណើតនៅលើកដែក ខេត្តកណ្តាល ជាកូនរបស់ ដួង ហេង និង នាង ធីសាំ មានប្រពន្ធឈ្មោះ មិន ទីស៊ាន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៦ នៅផ្ទះប្រធានភូមិ តំបន់២២។ ខ្មែរក្រហមសម្លាប់ ដួង សុខសាន នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩០ ថ្ងៃ។

**ដឿ រ៉ន** ហៅ ដឿ រុម មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសន្ទុក ខេត្តកំពង់ធំ ជាកូនរបស់ ដឿ រ៉េង និង ដាន់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព-៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៣ បន្ទប់តូច ១១។ ខ្មែរក្រហមសម្លាប់ ដឿ រ៉ន នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១២៧ ថ្ងៃ។

**ដៀង ភីការ** ហៅ រិន មានអាយុ៤១ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រែកត្រគួន ខេត្តឃ្លាំងកម្ពុជាក្រោម ឪពុកម្តាយឈ្មោះ ដៀង យឹម និង នាង ឈីវ មានប្រពន្ធឈ្មោះ គួន ហៅ យា មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ២៦ រោងពុម្ពរដ្ឋ ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ដៀង ភីការ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

**ដៀប យ៉ន** មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក២០(ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់ គង់ ដៀប និង អួង យិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅទួលតា(ទំ)ពូង ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ១០។ ខ្មែរក្រហមចាប់បញ្ជូន ដៀប យ៉ន ពីស-២១យ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥២ ថ្ងៃ។

**ដេត គីមណានី** ជាប្រពន្ធរបស់ អ៊ុច ម៉ឹងហ៊ិង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅស-២១យ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ដេត គីមណានី នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

**ឌី ឆន** ហៅ ខាន់ មានអាយុ៣២ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ ឌី ជុន និង អ៊ុច យ៉ែម មានប្រពន្ធឈ្មោះ គីម ស៊ាន ហៅ ហុង មានកូនប្រុស ១នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅខត្តរ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់បញ្ជូន ឌី ឆន ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៦។

**ឌី វ៉ែន** មានអាយុ៣៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក២០(ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់ មី ឌី និង អុង ទឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ឌី វ៉ែន នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៤០ ថ្ងៃ។

**ឌី សារម៉េត** អាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់ ឌី ហ៊ុយ និង កង សាមឿន មានប្រពន្ធឈ្មោះ ឌឹម សុខេន ហៅ យ៉ុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញត-៥ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់ធំ ១៣។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់ទួលស្លែង និងការសម្លាប់នៅឡើយ។

**ឌី សាយ** ជាកូនសិស្ស ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្វាយរៀង ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ឌី សាយ ទៅដល់គុកទួលស្លែង នៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧ ថ្ងៃ។

**ឌី សំអាត** អាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទឹកផុស ខេត្តកំពង់ឆ្នាំង ជាកូនរបស់ ចក់ មី និង ហុង ណាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកទឹកផុស តំបន់៣១ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៣ បន្ទប់តូច ៥។ (គ្មានក្នុងបញ្ជី)។





**ឌឹម ថា** ហៅ វណ្ណ មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនឌឹម ម៉ុង និង ហាក់ មានប្រពន្ធឈ្មោះ ហ៊ឹម ហៅ គ្រាន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឃ្លាំងរដ្ឋ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៧។ (គ្មានក្នុងបញ្ជី)។

**ឌុច មាញ** ហៅ ផាន មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅអង្គស្នួល ខេត្តកណ្តាល ជាកូនរបស់ គាំ ឌុច និង វ៉ាយ មួច ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរកាត់ដេរ ៧៥ ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ០៣ បន្ទប់តូច ១៦។ ខ្មែរក្រហមសម្លាប់ ឌុច មាញ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៣០ ថ្ងៃ។

**ណន ខ្លាក់** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ណន ខ្លាក់ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៣ ថ្ងៃ។

**ណន ឆាង** ហៅ អេង មាស មានអាយុ៥៦ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅអង្គរជ័យ ខេត្តកំពត ជាកូនរបស់ អេង ណន និង តឹក ទន មានប្រពន្ធឈ្មោះ នូ នី ហៅ សាវ៉ា មានកូនប្រុស ៣នាក់និងស្រី ៧នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៥ នៅភូមិព្រែកតាគង់ សង្កាត់ព្រែកតាសេក តំបន់ ២៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់ធំ ៣។ ខ្មែរក្រហមចាប់បញ្ជូន ណន ឆាង ហៅ អេង មាស ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៥ ថ្ងៃ។

**ណន ប៊ូ** ហៅ វឿន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅអគ្គីសនីចាក់អង្រែ ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

**ណាង ជាទ** មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុកស្រុកសាវ ឪពុកម្តាយឈ្មោះ ធីត ម៉ាវ និង ណាង បាង មានប្តីឈ្មោះ ខាំម៉ាយ ចិរស៊ិក ហៅ ច្រឹងសុខ មានកូនប្រុស ៥នាក់និងស្រី ១នាក់ ចាប់ខ្លួនថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ៤។ កាលបរិច្ឆេទនៃការសម្លាប់មានខុសៗគ្នា ដូចជា ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៦, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦ និងថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦។

**ណាង រិត** ហៅ អួន មានអាយុ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសន្ទុក ខេត្តកំពង់ធំ ជាកូនរបស់ ឈាង ណាល់ និង ពិន អាំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព-៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ណាង រិត នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៦០ថ្ងៃ។

**ណារិន ម៉ា** ហៅ ចេវ មានអាយុ៥៣ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅគីរីវង្ស ខេត្តតាកែវ ជាកូនរបស់ ម៉ា កែម និង យ៉ែម មានប្រពន្ធឈ្មោះ សឿ យ៉ន ហៅ មឿន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រះវិហារ តំបន់១០៣ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ០១ បន្ទប់តូច ១៤។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ណាវ កេវ** កើតនៅវៀងចាន់ មានប្តីឈ្មោះ ខាំ ភាវ ជាប់ឃុំឃាំងក្នុងផ្ទះលេខ ០៤។ ខ្មែរក្រហមចាប់បញ្ជូន ណាវ កេវ ទៅដល់គុកទួលស្លែងនៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៦ ឬ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦។

**ណី ណែម** មានអាយុ៥១ឆ្នាំ ក្នុងឆ្នាំ១៩៧៥ អតីតគ្រូបង្រៀន មានស្រុកកំណើតនៅកោះអណ្តែត ខេត្តតាកែវ ជាកូនរបស់ ប្រាក់ ឯល និង ខ្មៅ អ៊ុម មានប្រពន្ធឈ្មោះ ជីវ អេង មានកូនប្រុស ៦នាក់ និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផ្ទះភូមិរដ្ឋការទី ២ តំបន់ ៣៣ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៨ បន្ទប់ធំ ២០។ ខ្មែរក្រហមចាប់បញ្ជូន ណី ណែម ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅ

*ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៨៩ ថ្ងៃ។*

**ណុប ខេម** *គ្រូខ្មែរ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១៩ និងមួយទៀតនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ណុប ខេម ឬ ណុប ខែម នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។*

**ណុប ឃុន** *ហៅ ភាព អាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសន្ទុក ខេត្តកំពង់ធំ ជាកូនរបស់ ឃន ឃុន និង មព សិន មានប្រពន្ធឈ្មោះ វឿន ងឿន ហៅ ភាព លាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់ធំ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមានខុសៗគ្នា ដូចជា នៅថ្ងៃទី៨ ឬ៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ឬនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ណុប ឃុន នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៦។*

**ណុប គុប** *មានអាយុ៦១ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់ អ៊ុក ណុប និង ង៉ែត ទូច មានប្រពន្ធឈ្មោះ គង់ វ៉ុត មានកូនប្រុស ២នាក់ និងស្រី ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកកោះធំ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ០៨ បន្ទប់តូច ៨។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី១០ និងមួយទៀតនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ណុប គុប នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៧៦។*

**ណុប ស៊ី** *ហៅ ខៀវរដ្ឋ ប្រពន្ធរបស់ យិន ណែម ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅរទេះភ្លើង ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ណុប ស៊ី ឬ ណុម ស៊ី ឬ ម៉ែរ ស៊ី ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៨ ឬ ២៩ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦។ រីឯប្តីឈ្មោះ យិន ណែម ត្រូវបានខ្មែរក្រហមចាប់ខ្លួនទំនងជាមួយប្រពន្ធនៅថ្ងៃទី២៨ ឬ ២៩ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣០ ជាមួយគ្នា។*

**ណុប សារ៉ន** *ហៅ ណុប ពោត មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសំរោង ខេត្តតាកែវ ជាកូនរបស់ ណុប យ៉ា និង ប៊ុត សោ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់លេខ ២។ (គ្មានក្នុងបញ្ជី)។*

**ណុប សាលួត** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៥០២ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ណុប សាលួត នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦។*

**ណុប សុផល** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរ៉ោរមាស កំពង់ឆ្នាំង ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ណុប សុផល ឬ នុប សុផល ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៣ ថ្ងៃ។*

**ណុប សារ៉ុម** *ហៅ ប្រឹម មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់ ណុម សួន និង ឱម ខាត់ មានប្តីឈ្មោះ ចាប ជា មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រ ត-៥ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់ធំ ៨។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន ២ខុសគ្នា មួយនៅថ្ងៃទី៥ និងមួយទៀតនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ណុប សារ៉ុម នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦។*

**ណូង គីម** *ហៅ កម្ម មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ ណូង ហិយ និង ប៉ាំង ស៊ីហុង មានប្រពន្ធឈ្មោះ អុច គីមហេង មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រ ត-៣ ក្នុងឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់បញ្ជូន ណូង គីម ឬ នង គីម ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៩ ខែមករាឆ្នាំ១៩៧៧ និងសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០៤ ថ្ងៃ។*





**ណោត សុគុណា** *ហៅ ណោត ចិត្ត មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ពូ ឡុង ណោត និងមីង ជា ណៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរពេទ្យកងពល៣១០ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ២ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ ណោត សាគុណ ឬ នេត សាគុណ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦។*

**ណែម ឈឿន** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦។ កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន២ខុសគ្នា មួយនៅថ្ងៃទី៣១ ខែសីហា និងមួយទៀតនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ណែម ឈឿន នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។*

**ណៃ ណាន** *មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១៥៤ ខេត្តកណ្តាល ជាកូនរបស់ ណៃ ហ៊ី និង មួង អាន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរពេទ្យ ព-៩៨ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៥ បន្ទប់តូច ៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**ណៃ យ៉ុន** *ហៅ នឿន មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ ខៀវ ធុន និង ព្រុំ រិទ្ធ មានប្រពន្ធឈ្មោះ ឈួន សឿនហៅ វឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្ម ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ៥ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ ណៃ យ៉ុន នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១១៦ ថ្ងៃ។*

**ណៃ ណយ** *ហៅ ណៃ ស៊ីនួន មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់ នៅ ណៃ នឹង កោះ ថាត់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ ប-៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៣ បន្ទប់តូច ១២។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**ណៃ សា** *ហៅ វ៉ាត មានអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ ហ៊ុន ឡេង និង ណៃ សួន ត្រូវបានខ្មែរក្រហមចាប់ខ្លួនកងពល ៣១០ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**ណោ ស៊ីណា** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ១៧០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ណោ ស៊ីណា ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០ ថ្ងៃ។*

**តាង គីមថា** *ប្អូន តាន់ គីមហៀង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ ស-២១យ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ នៅថ្ងៃបន្ទាប់ ខ្មែរក្រហមសម្លាប់ តាង គីមថា ឬ តាន់ គីមថា។ តាន់ គីមហៀង មានប្រពន្ធឈ្មោះ មួង យូតិច ត្រូវបានខ្មែរក្រហមចាប់ និងសម្លាប់នៅថ្ងៃជាមួយនឹងប្អូនស្រី។ ចំណែកឯឈ្មោះ មួង យូតិច ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៦ ឬ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦ តែពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**(តនៅលេខក្រោយ)**

**ការបោះពុម្ពផ្សាយរឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ**

*ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាប្រជាជនកម្ពុជាគ្រប់រូប និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅ អំពីរឿងរ៉ាវពិតផ្ទាល់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ហើយមានបំណងផ្សព្វផ្សាយ សូមផ្ញើមកទស្សនាវដ្តីស្វែងរកការពិតតាមអាសយដ្ឋាន ៖*
*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។*
*ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ឬ (៨៥៥) ១២ ៩៩៦ ៧៥០*
*អ៊ីម៉ែល៖* truthbunthorn.s@dccam.org - *គេហទំព័រ៖* www.dccam.org

*រូបថតក្របមុខ៖ គង់ ចំរើន*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*
*រូបថតក្របក្រោយ៖ កុមារកំពុងរវៃអំបោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*
DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 243, March 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.